ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ម៉ូឌុលទី ១ ខ្ញុំ និងបរិស្ថានជុំវិញខ្ញុំ



## កម្មវិធីសិក្សា Gap Inc. P.A.C.E.

## សម្រាប់សិស្សវ័យជំទង់ ( អាយុ១១ ដល់ ១៣ឆ្នាំ )

គាំទ្រដោយក្រុមហ៊ុន Gap Inc.

រៀបចំដោយ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប)

# កម្មវិធីសិក្សា Gap Inc. P.A.C.E.

## ការដាក់ទុនលើជំនាញថ្មីដើម្បីអនាគត

Personal Advancement and Career Enhancement

## កម្មវិធីសម្រាប់ក្មេងស្រីវ័យជំទង់
( អាយុ១១ ដល់ ១៣ឆ្នាំ )

សៀវភៅណែនាំសម្រាប់គ្រូបង្រៀន

# មាតិកា


សេចក្តីណែនាំស្តីពីការប្រើប្រាស់សៀវភៅ ........ i

ម៉ូឌុលទី១ - ខ្ញុំ និងបរិស្ថានជុំវិញខ្ញុំ ........ 1

ជំពូកទី១ ៖ អត្តសញ្ញាណ ........ 2

មេរៀនទី១ ៖ ខ្ញុំ និងខ្លួនរបស់ខ្ញុំ ........ 3

មេរៀនទី២ ៖ ខ្ញុំ និងអ្នកដទៃ ........ 9

ជំពូកទី២ ៖ យេនឌ័រ ........ 15

មេរៀនទី៣ ៖ ការយល់ដឹងពីយេនឌ័រ ........ 17

មេរៀនទី៤ ៖ តើតួនាទីយេនឌ័រគឺជាអ្វី? ........ 22

មេរៀនទី៥ ៖ តើអំណាចជាអ្វី? ........ 28

មេរៀនទី ៦ ៖ អំណាច និងបិតាធិបតេយ្យ ........ 32

មេរៀនទី៧ ៖ ភាពជាក្មេងស្រី ........ 36

មេរៀនទី៨ ៖ ការចរចាពីតួនាទីយេនឌ័រ ........ 40

ជំពូកទី៣ ៖ យេនឌ័រ និងការប្រាស្រ័យទាក់ទង ........ 53

មេរៀនទី៩ ៖ តើការប្រាស្រ័យទាក់ទងជាពាក្យសម្តីគឺជាអ្វី? ........ 54

មេរៀនទី១០ ៖ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ........ 60

មេរៀនទី១១ ៖ ការប្រាស្រ័យទាក់ទងដោយកាយវិការ ........ 64

មេរៀនទី១២ ៖ យេនឌ័រ និងការប្រាស្រ័យទាក់ទង ........ 68

ឧបសម្ព័ន្ធទី១៖ សន្លឹកកិច្ចការសិស្ស ........ 75

ឧបសម្ព័ន្ធទី២៖ ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន ........ 86

# សេចក្តីណែនាំស្តីពីការប្រើប្រាស់សៀវភៅ

## ១. សេចក្តីផ្តើម

សៀវភៅម៉ូឌុលទី១សម្រាប់ក្មេងស្រីវ័យជំទង់ (អាយុពី១១-១៣ឆ្នាំ) មានគោលបំណងឱ្យសិស្សសិក្សាស្វែងយល់ពីខ្លួនឯង និងអ្នកដទៃដែលនៅជុំវិញខ្លួនគេ។ ម៉ូឌុលនេះចែកចេញជា៣ជំពូកគឺៈ ១) អត្តសញ្ញាណ ២) យេនឌ័រ និង៣) យេនឌ័រ និងការប្រាស្រ័យទាក់ទង ដោយជំពូកនីមួយៗមានមេរៀនដាច់ៗដោយឡែកពីគ្នាចំនួន១២មេរៀន។ ជំពូកនីមួយៗមានកំណត់ពីលទ្ធផលសិក្សាដែលរំពឹងទុករៀងៗខ្លួន។

ជំពូកស្តីពីអត្តសញ្ញាណធ្វើឱ្យសិស្សមានសមត្ថភាពឆ្លុះបញ្ចាំងពី«ខ្លួនឯង» និងកត្តាផ្សេងៗដែលមានឥទ្ធិពលលើអត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ ការគោរពចំពោះអត្តសញ្ញាណរបស់អ្នកដទៃ និងការយល់ដឹងពីអ្វីដែលអ្នកដទៃយល់ និងគិតពីយើង។ ជំពូកស្តីពីយេនឌ័រធ្វើឱ្យសិស្សយល់ពីយេនឌ័រ តួនាទី និងឥទ្ធិពលយេនឌ័រ ព្រមទាំងរបៀបដែលវាកើតឡើងនៅក្នុងសង្គម។ ចំណែកជំពូកស្តីពីការប្រាស្រ័យទាក់ទងធ្វើឱ្យសិស្សយល់ពីដំណើរនៃការបញ្ជូន និងទទួលព័ត៌មាន មធ្យោបាយនៃការបញ្ជូន និងការទទួលព័ត៌មាន សារៈសំខាន់ និងឧបសគ្គនៃការបញ្ជូន និងការទទួលព័ត៌មាន ព្រមទាំងផលវិបាកដែលអាចកើតមាននៅពេលបញ្ជូន និងទទួលព័ត៌មានមិនបានល្អ ឬត្រឹមត្រូវ។

## ២. វត្ថុបំណងរបស់ម៉ូឌុល

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិស្ស៖

- អាចកំណត់ និងនិយាយរៀបរាប់ពីខ្លួនឯង និងអត្តសញ្ញាណផ្ទាល់ខ្លួន។
- អាចកំណត់ឥទ្ធិពលនានាដែលកំណត់ពី«ខ្លួនឯង» និងអត្តសញ្ញាណផ្ទាល់ខ្លួន។
- យល់ដឹងថា យេនឌ័រគឺជាការកំណត់របស់សង្គម និងកំណត់តួនាទីរបស់បិតាធិបតេយ្យនៅក្នុងការរស់នៅប្រចាំថ្ងៃ។
- បង្កើនកម្រិតនៃភាពងាយស្រួល និងសមត្ថភាពរបស់សិស្សក្នុងការប្រាស្រ័យទាក់ទងជាមួយមនុស្សពេញវ័យ។
- អភិវឌ្ឍជំនាញប្រាស្រ័យទាក់ទងជាពាក្យសំដី និងកាយវិការប្រកបដោយប្រសិទ្ធភាព។

## ៣. សេចក្តីពន្យល់ពីការប្រើប្រាស់ម៉ូឌុល

សៀវភៅនេះគឺជាសៀវភៅសម្រាប់គ្រូដែលបានរៀបចំរួចជាស្រេចនូវផែនការ ឬលំនាំនៃការបង្រៀនសម្រាប់ជំនួយដល់គ្រូក្នុងការបង្រៀនសិស្ស។ វាចែកចេញជា៥ផ្នែកធំៗតាមលំដាប់លំដោយ

ពោលគឺ ១) ម៉ូឌុល ២) ជំពូក ៣) មេរៀន ៤) ឧបសម្ព័ន្ធទី១ សន្លឹកកិច្ចការសិស្ស និង ៥) ឧបសម្ព័ន្ធទី២ ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន។ នៅក្នុងម៉ូឌុលមានបែងចែកជាជំពូកធំៗចំនួន៣ ហើយនៅក្នុងជំពូកនីមួយៗមានចំនួនមេរៀនជាក់លាក់ទៅតាមភាពចាំបាច់របស់ជំពូក។

**ផ្នែកនៃម៉ូឌុល** ផ្តល់នូវការណែនាំទូទៅទាក់ទងនឹងខ្លឹមសារទាំងមូលនៃប្រធានបទ ជំពូក និង មេរៀន។ ដូច្នេះនៅក្នុងផ្នែកនេះ បានដាក់បញ្ចូលនូវ៖ ទិដ្ឋភាពទូទៅនៃម៉ូឌុល រយៈពេលឬចំនួនម៉ោងបង្រៀនសរុប ចំនួនលំនាំបង្រៀន និងវត្ថុបំណងរបស់ម៉ូឌុលដើម្បីឱ្យគ្រូបង្រៀនយល់ដឹងបានទូលំទូលាយពីខ្លឹមសារទូទៅរបស់ប្រធានបទទាំងមូល។

**ផ្នែកនៃជំពូក** ផ្តល់នូវការណែនាំជាក់លាក់សម្រាប់ប្រធានបទរួមរបស់មេរៀនទាំងមូលនៅក្នុងជំពូកនីមួយៗ។ ដូចគ្នានឹងផ្នែកម៉ូឌុលដែរ បានដាក់បញ្ចូលនូវ៖ ទិដ្ឋភាពទូទៅ រយៈពេលឬចំនួនម៉ោងបង្រៀនសរុប ចំនួនលំនាំបង្រៀន និងវត្ថុបំណងដាច់ដោយឡែកសម្រាប់ជំពូកនីមួយៗដើម្បីឱ្យគ្រូបង្រៀនយល់ដឹងពីខ្លឹមសារទូទៅរបស់ជំពូកនីមួយៗ។

**ផ្នែកនៃមេរៀន** ផ្តល់នូវព័ត៌មានលម្អិតសម្រាប់ការងាររៀបចំជាមុនរបស់គ្រូបង្រៀន។ នៅក្នុងមេរៀននីមួយៗមានកំណត់ និងរៀបចំតាមលំដាប់លំដោយនូវ ៖ រយៈពេល វត្ថុបំណង សម្ភារៈដែលត្រូវការ សេចក្តីណែនាំ និងចំណុចសម្រាប់ការពិភាក្សា។ នៅខាងចុងនៃមេរៀន ក៏បានបញ្ចូល«គន្លឹះសម្រាប់គ្រូបង្រៀន និងសារសំខាន់ៗ»ដើម្បីជាជំនួយដល់គ្រូបង្រៀនផងដែរ។

**ផ្នែកឧបសម្ព័ន្ធទី១** សន្លឹកកិច្ចការសិស្សមានបញ្ជាក់ច្បាស់លាស់ពីកិច្ចការសម្រាប់សិស្សដែលត្រូវបំពេញនៅក្នុងថ្នាក់ និងកិច្ចការផ្ទះ។

**ផ្នែកឧបសម្ព័ន្ធទី២** ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន គឺជាទម្រង់ស្ទង់ដារដែលសិស្សត្រូវបំពេញមុនពេលរៀន និងក្រោយពេលបញ្ចប់ដើម្បីឱ្យគ្រូងាយស្រួលក្នុងការពិនិត្យមើលលទ្ធផលសិក្សារបស់សិស្សក្រោយពេលបញ្ចប់ម៉ូឌុលនេះ។

- **ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស**

មានព័ត៌មានទាក់ទងនឹងរបៀបចាប់ផ្តើមពីការបង្រៀនសិស្សឬផ្នែកដែលទាក់ទងនឹងសកម្មភាពនៃការបង្រៀន និងរៀន។ វាក៏ផ្តល់នូវការណែនាំពីការរៀបចំសម្ភារៈ និងឯកសារដែលគ្រូបង្រៀនត្រូវការសម្រាប់ការបង្រៀន និងរៀន។

- **សម្ភារឧបទ្ទេស**

ផ្នែកនេះផ្ដល់នូវសេចក្ដីសង្ខេបពីសម្ភារឧបទ្ទេស ដែលភាគច្រើនជាសម្ភារៈមូលដ្ឋានដូចជា ក្ដារខៀន ដីស ឬហ្វឺត ស្កុត កន្ត្រៃ ប៊ិក សៀវភៅ ក្រដាសទំហំផ្សេងៗគ្នា ក្រដាសព័ត៌មាន ឬឯកសារផ្សេងៗជាដើម។ សម្ភារៈ ឯកសារផ្សេងៗទៀតនៅក្នុងសៀវភៅនេះក៏ត្រូវផ្ដល់ឱ្យសិស្សសម្រាប់អនុវត្ត ដែរតាមរយៈសន្លឹកកិច្ចការសម្រាប់សិស្សដែលមានភ្ជាប់នៅក្នុងសៀវភៅនេះ។

- **វត្ថុបំណង**

ផ្ដល់នូវឃ្លា ឬប្រយោគជាក់លាក់មួយចំនួនពីអ្វីដែលត្រូវសម្រេចឱ្យបាន។ សម្រាប់ចំណុចនេះ វត្ថុបំណងចែកចេញជា៣ផ្នែកធំៗដូចរៀបរាប់ខាងលើ ពោលគឺ ៖ ១) វត្ថុបំណងទូទៅដែលមានកំណត់នៅក្នុងផ្នែកនៃម៉ូឌុល ២)វត្ថុបំណងដែលមានលក្ខណៈជាក់លាក់ដែលមានកំណត់នៅក្នុងផ្នែកនៃជំពូក និង ៣) វត្ថុបំណងជាក់លាក់សម្រាប់មេរៀននីមួយៗ។

- **ជំហាន និងលំនាំនៃការបង្រៀន និងរៀន**

នេះជាផ្នែកមេរៀនពិតប្រាកដ។ នៅក្នុងផ្នែកនេះមានផ្ដល់ព័ត៌មានទាក់ទងនឹងរយៈពេលបង្រៀន និងរៀន វត្ថុបំណង សម្ភារៈដែលត្រូវការ និងសេចក្ដីណែនាំដែលជាផ្នែកដ៏សំខាន់សម្រាប់គ្រូបង្រៀនក្នុងការធ្វើសកម្មភាពក្នុងពេលបង្រៀន និងរៀន។ នៅក្នុងផ្នែកនៃ «សេចក្ដីណែនាំ» មានបញ្ជាក់នូវសកម្មភាពដែលគ្រូបង្រៀនត្រូវធ្វើ សំណួរបំផុសគំនិត ឧទាហរណ៍ និងព័ត៌មានផ្សេងៗទៀត។ ដូចដែលបានបញ្ជាក់ពីខាងលើ «គន្លឹះសម្រាប់គ្រូបង្រៀន និងសារសំខាន់ៗ»ដែលនៅចុងបញ្ចប់នៃមេរៀននីមួយៗ ក៏ផ្ដល់នូវការណែនាំបន្ថែមសម្រាប់ដំណើរការបង្រៀន និងរៀន និងខ្លឹមសារផ្សេងៗដែលគ្រូបង្រៀនអាចណែនាំ និងពន្យល់សិស្សបន្ថែមទៀតទៅលើខ្លឹមសារមេរៀន។

- **ការប្រើប្រាស់និមិត្តសញ្ញា**

និមិត្តសញ្ញាមួយចំនួនត្រូវបានគេដាក់បញ្ចូលនៅក្នុងសៀវភៅនេះដើម្បីឱ្យគ្រូបង្រៀនមានការចាប់អារម្មណ៍ និងងាយស្រួលយល់ និងប្រើប្រាស់។ និមិត្តសញ្ញាទាំងនោះរួមមាន ៖

| | | |
|---|---|---|
| 🏆 វត្ថុបំណងម៉ូឌុល ឬជំពូក | ៖ | ចំណេះដឹងក្រោយរបស់សិស្សដែលទទួលបាននៅក្នុងម៉ូឌុលទាំងមូល និងជំពូកនីមួយៗ។ |
| | | ☺ ចំណេះដឹងលម្អិតនីមួយៗដែលសិស្សទទួលបាន។ |
| 🕘 រយៈពេល | ៖ | ចំនួនម៉ោងសម្រាប់មេរៀននីមួយ។ |
| ➡ វត្ថុបំណងមេរៀន | ៖ | លទ្ធផលសិក្សាដែលសិស្សសម្រេចបានក្រោយពីបញ្ចប់មេរៀន |

នីមួយៗ។

| | | |
|---|---|---|
| 📖 សម្ភារៈដែលត្រូវការ | ៖ | មានសរសេរនៅក្នុងមេរៀននីមួយៗដែលតម្រូវឱ្យគ្រូបង្រៀនរៀបចំទុកជាមុន។ |
| 📢 សេចក្តីណែនាំ | ៖ | ចំណុចនានាដែលគ្រូបង្រៀនត្រូវអនុវត្តជាទូទៅក្នុងពេលបង្រៀន និងរៀន។<br>☞ ចំណុចនីមួយៗដែលគ្រូបង្រៀនត្រូវធ្វើ។ |
| 🗣 ចំណុចសម្រាប់ការពិភាក្សា | ៖ | បញ្ជាក់ពីចំណុចនានាសម្រាប់ការពិភាក្សាក្រុមតូច ឬក្រុមធំ។<br>◈ សំណួរបំផុសគំនិត ឬពិភាក្សាក្នុងពេលបង្រៀន និងរៀន។<br>☝ ចម្លើយសម្រាប់សំណួរនីមួយៗ ឬការពន្យល់ទូទៅ។ |
| ⊶ គន្លឹះសម្រាប់គ្រូបង្រៀន | ៖ | ចំណុចបន្ថែមដែលគ្រូបង្រៀនត្រូវរៀបចំ អនុវត្ត ឬពន្យល់បន្ថែមក្នុងពេលបង្រៀន និងរៀន។<br>🕯 ចំណុចនីមួយៗដែលគ្រូបង្រៀនត្រូវរៀបចំ អនុវត្ត ឬពន្យល់បន្ថែម។ |
| ✉ សារសំខាន់ៗ | ៖ | ខ្លឹមសារសង្ខេបរបស់មេរៀននីមួយៗដែលគ្រូបង្រៀនត្រូវបញ្ជាក់ប្រាប់សិស្ស។<br>🗎 ខ្លឹមសារសង្ខេបនីមួយៗ។ |

## ៤. សៀវភៅកិច្ចការសិស្ស

នៅខាងក្រោយនៃសៀវភៅនេះមានដាក់បញ្ចូលនូវសន្លឹកកិច្ចការសិស្ស*(ឧបសម្ព័ន្ធទី១)*។ មេរៀនមួយចំនួនក្នុងចំណោមមេរៀនទាំងនេះមានឯកសារ និងលំហាត់សម្រាប់សិស្ស។ តាមការជាក់ស្តែងគ្រូអាចថតចម្លងលំហាត់ ឬអាចរៀបចំសន្លឹកកិច្ចការសិស្សនីមួយៗសម្រាប់ចែកជូនដល់សិស្ស។ តាមការអនុវត្តន៍ជាក់ស្តែង និងលក្ខណៈពិសេសរបស់ម៉ូឌុល សន្លឹកកិច្ចការសិស្សគប្បីដាក់បញ្ចូលគ្នាទាំង៤ម៉ូឌុលដើម្បីឱ្យសិស្សអាចមើលឡើងវិញបាននៅពេលដែលត្រូវការ ព្រោះថាម៉ូឌុលទាំង៤ពាក់ព័ន្ធនឹងការប្រតិបត្តិល្អច្រើនក្នុងជីវិតប្រចាំថ្ងៃ។

## ៥. ខ្លឹមសារសង្ខេបរបស់ម៉ូឌុល

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបរបស់មេរៀនទាំង១២ដែលមាននៅក្នុងម៉ូឌុលនេះ ៖

| ចំណងជើងមេរៀន | រយៈពេល | សេចក្តីសង្ខេប |
|---|---|---|
| ជំពូកទី១ ៖ អត្តសញ្ញាណ | | |

| | | |
|---|---|---|
| ១. ខ្ញុំ និងខ្លួនរបស់ខ្ញុំ | ៦០នាទី | - សិស្សមានការយល់ដឹងពីទស្សនៈទានស្ដីពី«ខ្លួនឯង» និង «អត្តសញ្ញាណ»។ |
| ២. ខ្ញុំ និងអ្នកដទៃ | ៦០នាទី | - សិស្សយល់ដឹងពីរបៀបដែលបរិយាកាសជុំវិញ និងទំនាក់ទំនងខុសៗគ្នាមានឥទ្ធិពលទៅលើភាពនៃ«ខ្លួនឯង»របស់បុគ្គលម្នាក់ៗ។ |
| **ជំពូកទី២ ៖ យេនឌ័រ** | | |
| ៣. ការយល់ដឹងពីយេនឌ័រ | ៦០នាទី | - សិស្សយល់ដឹងពីទស្សនៈទានផ្នែកយេនឌ័រ និងរបៀបដែលសង្គមកំណត់ពីទស្សនៈទាននេះ។ |
| ៤. តើតួនាទីយេនឌ័រគឺជាអ្វី? | ៦០នាទី | - សិស្សយល់ដឹងពីអ្វីដែលជាតួនាទីយេនឌ័រ និងរបៀបដែលតួនាទីយេនឌ័រទាំងនេះជះឥទ្ធិពលលើតថភាពជាក់ស្ដែងដែលយើងកំពុងរស់នៅ។ |
| ៥. អំណាចជាអ្វី? | ៤៥នាទី | - សិស្សយល់ដឹងអំពីអត្ថន័យនៃអំណាច។ |
| ៦. អំណាច និងបិតាធិបតេយ្យ | ៦០នាទី | - សិស្សយល់ដឹងអំពីទំនាក់ទំនងរវាងអំណាច និងបិតាធិបតេយ្យ |
| ៧. ភាពជាក្មេងស្រី | ៦០នាទី | - សិស្សវិភាគពីទស្សនៈទានស្ដីពី«ក្មេងស្រីល្អ» និង«ក្មេងស្រីមិនល្អ» និងរបៀបដែលទស្សនៈទាននេះមានទំនាក់ទំនងទៅនឹងបុព្វសិទ្ធិ បិតាធិបតេយ្យ ព្រមទាំងការរើសអើង និងវិសមភាពយេនឌ័រ |
| ៨. ការចរចាពីតួនាទីយេនឌ័រ | ៤៥នាទី | - សិស្សសិក្សាស្វែងយល់ពីលទ្ធភាពនៃការចរចាចំពោះតួនាទី និងការរំពឹងទុកផ្នែកយេនឌ័រ។ |
| **ជំពូកទី៣ ៖ យេនឌ័រ និងការប្រាស្រ័យទាក់ទង** | | |
| ៩. តើការប្រាស្រ័យទាក់ទងជាពាក្យសម្ដីគឺជាអ្វី? | ៣០នាទី | - សិស្សសិក្សាពីសារៈសំខាន់នៃការនិយាយឱ្យបានច្បាស់លាស់ ការដឹងនិងការស្ដាប់ដោយយកចិត្តទុកដាក់(ការស្ដាប់យ៉ាងសកម្ម) ដោយសារចំណុចមានភាពចាំបាច់ចំពោះការប្រាស្រ័យទាក់ទងជាពាក្យសម្ដីប្រកបដោយប្រសិទ្ធភាព។ |
| ១០. ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព | ១៥នាទី | - សិស្សបង្ហាញពីការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។ |
| ១១. ការប្រាស្រ័យ | ៣០នាទី | - សិស្សទទួលបានការយល់ដឹងពីការប្រាស្រ័យទាក់ទងដោយប្រើ |

| | | |
|---|---|---|
| ទាក់ទងដោយកាយវិការ | | កាយវិការ។ |
| ១២. យេនឌ័រ និងការប្រាស្រ័យទាក់ទង | ៤៥នាទី | - សិស្សស្វែងយល់ពីរបៀបដែលថាមវន្តនៃយេនឌ័រ និងអំណាចមានផលជះដល់សមត្ថភាពប្រាស្រ័យទាក់ទង។ |

## ៦. ការវាយតម្លៃសិស្ស

នៅខាងចុងនៃសៀវភៅនេះមានដាក់បញ្ចូលនូវទម្រង់នៃការវាយតម្លៃសិស្ស*(ឧបសម្ព័ន្ធទី២)* ដែលទម្រង់នេះត្រូវបានរៀបចំឡើងសម្រាប់វាស់វែងចំណេះដឹងរបស់សិស្ស។ ការវាយតម្លៃនេះត្រូវធ្វើជាពីរដំណាក់កាល ពោលគឺ ការវាយតម្លៃមុនពេលបង្រៀន *(Pre-test)* និងក្រោយពេលបង្រៀន *(Post-test)* ដើម្បីពិនិត្យមើលលើការរីកចម្រើនផ្នែកចំណេះដឹងរបស់សិស្ស។

## ៧. ឯកសារយោង

នៅក្នុងមេរៀននីមួយៗមានបញ្ចូលនូវឯកសារយោង ឬបន្ថែមសម្រាប់ការអានរបស់សិស្ស និងការពន្យល់បន្ថែមរបស់គ្រូ។ ឯកសារទាំងនេះមានចំនួន២ប្រភេទគឺ «ឧបសម្ព័ន្ធ និងក្របខណ្ឌចំណេះដឹង»។ វាមានសារៈសំខាន់ណាស់ដែលគ្រូបង្រៀនត្រូវអានចំណុចទាំងនេះជាមុន ព្រោះវាផ្តល់នូវការពន្យល់ទូទៅនូវចំណេះដឹងមួយចំនួន។

# ម៉ូឌុលទី១៖ ខ្ញុំ និងបរិស្ថានជុំវិញខ្ញុំ

## ទិដ្ឋភាពទូទៅ

ម៉ូឌុលដំបូងនេះផ្តោតសំខាន់ទៅលើទស្សនៈទានចំនួនបីគឺ ៖ អត្តសញ្ញាណ យេនឌ័រ និងការប្រាស្រ័យទាក់ទង។ ប្រធានបទទាំងនេះអាចអនុវត្តបាននៅគ្រប់វគ្គសិក្សាទាំងអស់ និងត្រូវបានបង្ហាញនៅក្នុងម៉ូឌុលទី១ ដើម្បីឱ្យគ្រូបង្រៀនដាក់បញ្ចូលគំនិតទាំងនេះនៅគ្រប់មេរៀន។

ទស្សនៈទាននីមួយៗមានមេរៀនពិសេសដាច់ដោយឡែកមួយនៅក្នុងម៉ូឌុលនេះ។ មេរៀននីមួយៗមានសកម្មភាពជាច្រើនដែលអាចឱ្យអ្នកចូលរួមបានរៀនសូត្រអំពីទស្សនៈទានទាំងអស់នេះបាន។

**រយៈពេលរួម ៖** ៩ ម៉ោង ៥០ នាទី

**ចំនួនលំនាំបង្រៀនសរុប ៖** ១២ មេរៀន

## វត្ថុបំណង

- ☺ អាចកំណត់ និងនិយាយរៀបរាប់ពីខ្លួនឯង និងអត្តសញ្ញាណផ្ទាល់ខ្លួន។
- ☺ អាចកំណត់ឥទ្ធិពលនានាដែលកំណត់ពី «ខ្លួនឯង»និងអត្តសញ្ញាណផ្ទាល់ខ្លួន។
- ☺ យល់ដឹងថាយេនឌ័រគឺជាការកំណត់របស់សង្គម និងកំណត់តួនាទីរបស់បិតាធិបតេយ្យនៅក្នុងការរស់នៅប្រចាំថ្ងៃ។
- ☺ បង្កើនកម្រិតនៃភាពងាយស្រួល និងសមត្ថភាពរបស់សិស្សក្នុងការប្រាស្រ័យទាក់ទងជាមួយមនុស្សពេញវ័យ។
- ☺ អភិវឌ្ឍជំនាញប្រាស្រ័យទាក់ទងជាពាក្យសម្តី និងកាយវិការប្រកបដោយប្រសិទ្ធភាព។

# ជំពូកទី១ ៖ អត្តសញ្ញាណ

## ទិដ្ឋភាពទូទៅ

ជំពូកនេះមានគោលបំណងឱ្យសិស្សអាចឆ្លុះបញ្ចាំងពីគំនិតស្ដីពី«ខ្លួនឯង» អត្តសញ្ញាណបុគ្គល និងយល់ដឹងថាកត្តាផ្សេងៗដូចជាអាយុ កម្រិតវប្បធម៌ វណ្ណៈ វង្សត្រកូល សាសនា សមត្ថភាព ព្រមទាំងលក្ខណៈផ្សេងៗទៀតដែលបានកំណត់ និងជះឥទ្ធិពលលើអត្តសញ្ញាណ។ ជំពូកនេះផ្ដោតលើសារៈសំខាន់នៃការគោរព និងការស្ដាប់នូវអ្វីដែលអ្នកដទៃគិត និងនិយាយពីខ្លួនគេ ដោយសារបុគ្គលម្នាក់ៗមានលក្ខណៈពិសេសផ្ទាល់ខ្លួន ព្រមទាំងការជួយសិស្សឱ្យទទួលយកទស្សនៈទានទាំងនោះ។ សិស្សត្រូវមានលទ្ធភាពបង្កើតទំនាក់ទំនងរវាងកត្តាសង្គម និងការយល់ឃើញផ្ទាល់ខ្លួនពីខ្លួនឯង។

🕘 **រយៈពេលរួម ៖** ២ ម៉ោង

❐ **ចំនួនលំនាំបង្រៀនសរុប ៖** ២ មេរៀន

### 🏆 វត្ថុបំណង ៖

- ☺ យល់ដឹងស៊ីជម្រៅ ឬយល់ច្បាស់ពី «ខ្លួនឯង» និងយល់ថាវាជាលក្ខណៈពិសេសចំពោះបុគ្គលម្នាក់ៗ។
- ☺ យល់ដឹងថាទិដ្ឋភាពជាក់លាក់របស់អត្តសញ្ញាណគឺសហគមន៍ និងគុណតម្លៃសង្គមជាអ្នកកំណត់ ហើយថាទិដ្ឋភាពទាំងនេះអាចកំណត់ឡើងវិញ និងធ្វើការផ្លាស់ប្ដូរបាន។

# មេរៀនទី១ ៖ ខ្ញុំ និងខ្លួនរបស់ខ្ញុំ[9]

🕘 **រយៈពេល** ៖ ១ ម៉ោង

➲ **វត្ថុបំណង** ៖ ដើម្បីឱ្យសិស្សមានការយល់ដឹងពីទស្សនៈទានស្តីពី «ខ្លួនឯង» និង «អត្តសញ្ញាណ»។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

- ☞ សម្រាប់គ្រូ៖ ក្តារខៀន ហ្វឺតពណ៌ និងក្រដាសសកាត់ជារាងការេ។
- ☞ សម្រាប់សិស្ស៖ សន្លឹកកិច្ចការក្នុងថ្នាក់ទំព័រទី៧៦ និងកិច្ចការផ្ទះទំព័រ៧៧។

**ការរៀបចំទុកជាមុន** ៖

- ☞ អានទិដ្ឋភាពទូទៅនៃម៉ូឌុលទី១៖ ខ្ញុំ និងបរិស្ថានជុំវិញខ្ញុំ និងជំពូកទី១ ៖ អត្តសញ្ញាណ។
- ☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- ☞ អានបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្នាក់រៀន។
- ☞ បង្កើតដ្យាក្រាមស្តីពីការបង្កើតអត្តសញ្ញាណផ្ទាល់ខ្លួន ដើម្បីបង្ហាញសិស្ស។
- ☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។
- ☞ ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

**ផ្នែកទី១៖** លោកគ្រូ អ្នកគ្រូត្រូវ ៖

- ☞ ប្រាប់ក្រុម(សិស្ស)ថា លំហាត់នេះនឹងជួយសិស្សទាំងអស់ឱ្យបានស្គាល់គ្នា និងយល់ពីលក្ខណៈផ្ទាល់ខ្លួនរបស់ពួកគេម្នាក់ៗ។
- ☞ ឱ្យសិស្សចាប់ដៃគូជាមួយសិស្សផ្សេងទៀតនៅក្នុងក្រុមដែលពួកគេពុំស្គាល់គ្នាច្បាស់។ មិនត្រូវឱ្យសិស្សចាប់ដៃគូជាមួយមិត្តភក្តិជិតស្និទ្ធរបស់ខ្លួនឡើយ។
- ☞ ប្រសិនបើសិស្សណាម្នាក់គ្មានដៃគូ លោកគ្រូ អ្នកគ្រូអាចចាប់ដៃគូជាមួយសិស្សនោះ ឬស្នើឱ្យសិស្សនោះចូលរួមជាមួយក្រុមដទៃដែលមានស្រាប់ដែលបង្កើតជាក្រុមថ្មីមួយមានសមាជិកបីនាក់។

---

[9] ICRW,. (២០១៦). *កម្មវិធី តែកស ប្រនហ្ស៍សម្រាប់នារីពេញវ័យ។* Gap Inc.

សិស្សអាចអង្គុយធ្វើលំហាត់នេះ។

☞ ប្រាប់សិស្សឱ្យណែនាំខ្លួនឱ្យដៃគូរបស់ខ្លួនស្គាល់ក្នុងរយៈពេល៥នាទីហើយសិស្សម្នាក់ៗប្រើប្រាស់តែឃ្លាចំនួន៥ប៉ុណ្ណោះ។

☞ ប្រាប់សិស្សឱ្យស្តាប់ដោយយកចិត្តទុកដាក់នូវអ្វីដែលដៃគូបាននិយាយពីព្រោះពួកគេត្រូវចែករំលែកនូវអ្វីដែលដៃគូរបស់ខ្លួនបាននិយាយនៅក្នុងក្រុមធំ។

☞ អាចផ្តល់ឧទាហរណ៍ដូចខាងក្រោមបាន ៖

ក. ខ្ញុំឈ្មោះ «គីរី»។

ខ. ខ្ញុំមានអាយុ ១៤ ឆ្នាំ។

គ. ខ្ញុំរស់នៅក្នុងភូមិ …… ឃុំ / សង្កាត់ …..ក្រុង / ស្រុក / ខណ្ឌ …… រាជធានី / ខេត្ត (ឈ្មោះអាសយដ្ឋានជាក់លាក់)។

ឃ. ខ្ញុំចូលចិត្តសត្វឆ្កែ។

ង. ខ្ញុំចូលចិត្តគូររូប។

☞ ឱ្យសិស្សរៀបរាប់ដោយសង្ខេបនូវឃ្លាទាំង ៥ ដែលគេបានឮពីដៃគូរបស់ខ្លួនឱ្យក្រុមធំស្តាប់។

☞ នៅពេលសិស្សទាំងអស់បាននិយាយគ្រប់គ្នាហើយ ត្រូវឱ្យសិស្សក្នុងក្រុមកំណត់ចំណុច ឬវិធីសាស្ត្ររួមដែលគេប្រើប្រាស់ដើម្បីរៀបរាប់ពីខ្លួនគេផ្ទាល់។ ចំណុចទាំងនេះត្រូវសរសេរនៅលើក្តារខៀន។ ឧទាហរណ៍ ៖ អាយុ ភេទ កម្រិតវប្បធម៌ ភាសា ការងារ ចំណង់ចំណូលចិត្ត ការចូលចិត្ត និងការមិនចូលចិត្ត ចំណុចខ្លាំង។ល។

☞ ត្រូវពន្យល់សិស្សថាមានចំណុចចំនួន ២ ក្នុងការកំណត់ពីអត្តសញ្ញាណ ហើយចំណុចទាំង ២ នេះមានឥទ្ធិពលលើគ្នាទៅវិញទៅមក ៖

- ចំណុចទី១ ៖ អ្វីដែលយើងគិតពីខ្លួនឯង។
- ចំណុចទី២ ៖ អ្វីដែលអ្នកដទៃគិតពីយើង។

*កិច្ចការក្នុងថ្នាក់ ៖*

☞ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រ៧៦។

☞ ចែកក្រដាសសឱ្យសិស្សម្នាក់ៗ រួចឱ្យពួកគេគូសដ្យាក្រាមស្តីពីអត្តសញ្ញាណនៅលើក្រដាសរបស់ខ្លួន។ សិស្សអាចសរសេរពាក្យផ្សេងៗដែលពួកគេប្រើដើម្បីរៀបរាប់អំពីខ្លួនឯង ព្រមទាំងពាក្យដែលអ្នកដទៃប្រើដើម្បីរៀបរាប់អំពីខ្លួនរបស់គេ។

☞ គូសដ្យាក្រាមខាងក្រោមនៅលើក្តារខៀនដើម្បីធ្វើជាឧទាហរណ៍ ដោយសរសេរពាក្យដែលលោក

គ្រូ អ្នកគ្រូបង្កើតឡើងដោយខ្លួនឯងដើម្បីបង្ហាញពីអត្តសញ្ញាណផ្ទាល់របស់ខ្លួន។




☞ សិស្សត្រូវបង្ហាញផ្សាក្រាមស្ដីពីអត្តសញ្ញាណរបស់ខ្លួនឱ្យដៃគូរបស់ខ្លួនមើល។

*កិច្ចការផ្ទះ៖*

☞ នៅពេលបញ្ចប់សកម្មភាពនេះ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៧៧។

☞ អានសេចក្ដីណែនាំនៅក្នុងសន្លឹកកិច្ចការ បន្ទាប់មកពន្យល់ពីអ្វីដែលពួកគេចាំបាច់ត្រូវធ្វើ។

☞ បញ្ជាក់ប្រាប់សិស្សពីសារៈសំខាន់នៃកិច្ចការនេះ សម្រាប់ការសិក្សានៅមេរៀនបន្ទាប់។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

◇ សម្រាប់លំហាត់នេះ គេបានឱ្យរកតែ៥ចំណុចប៉ុណ្ណោះសម្រាប់រៀបរាប់ពីមនុស្សម្នាក់។ ក៏ប៉ុន្តែ ប្រសិនបើមានពេលវេលាបន្ថែមយើងអាចស្វែងរកចំណុចបន្ថែមទៀតដើម្បីកំណត់ពីខ្លួនរបស់យើង។ គ្រូបង្រៀនអាចឱ្យសិស្សបន្ថែមចំណុចមួយចំនួនទៀត។

◇ តើយើងយល់ដូចម្ដេចចំពោះពាក្យថា«ខ្លួនឯង»? គេអាចយល់ពាក្យ **ខ្លួនឯង** ខុសៗគ្នា។ ខ្លួនឯងគឺសំដៅលើ «តើបុគ្គលនោះជានរណា?» ហើយ «មានបុគ្គលិកលក្ខណៈដូចម្ដេច?» ឬរបៀបដែលបុគ្គលទាំងនោះមើលឃើញខ្លួនឯងថាមានលក្ខណៈខុសពីមនុស្សដទៃទៀត។ ទោះជាពាក្យ «ខ្លួនឯង» ហាក់ដូចជាមានន័យស្រដៀងទៅនឹងពាក្យ «អត្តសញ្ញាណ» ក៏ដោយ ក៏ពាក្យទាំង២នេះបង្កប់នូវគោលគំនិតខុសៗគ្នា[២]ដែរ។

---

[២] (016) ដកស្រង់ពី https://dornsife.usc.edu/assets/sites/782/docs/handbook_of_self_and_identity _

◈ តើយើងយល់ដូចម្ដេចចំពោះពាក្យ«អត្តសញ្ញាណ»? **អត្តសញ្ញាណ** គឺជាការពិពណ៌នាពីគំនិតរបស់បុគ្គលម្នាក់ចំពោះខ្លួនឯងផ្ទាល់ ឬជាទស្សនៈរបស់អ្នកដទៃចំពោះមនុស្សម្នាក់ដែលអាចមានមូលដ្ឋានលើកត្តាចិត្តសាស្ត្រសង្គម វប្បធម៌សង្គម នយោបាយ ប្រវត្តិសាស្ត្រ និងកត្តាផ្សេងៗទៀត។

- កត្តាចិត្តសាស្ត្រសង្គម ៖ គេយល់ឃើញយ៉ាងសាមញ្ញថាជាទំនាក់ទំនងរវាងចិត្ត បរិយាកាស និងកាលៈទេសៈផ្ទាល់ខ្លួនដែលជះឥទ្ធិពលលើទស្សនៈ និងសុខុមាលភាពរបស់យើង។ ឧទាហរណ៍ ក្មេងស្រីម្នាក់អាចមានអារម្មណ៍អាម៉ាស់ ខុសឆ្គង ឬកង្វល់ចំពោះការបៀតបៀននៅតាមដងផ្លូវ ប្រសិនបើសង្គម និងគ្រួសាររបស់នាងបន្ទោសនាងចំពោះការបៀតបៀននេះ។

- វប្បធម៌សង្គម ៖ អត្តសញ្ញាណអាចត្រូវបានកំណត់ ឬយល់ឃើញចំពោះទំនៀមទម្លាប់សង្គមដែលមានដូចជាការកាន់ត្រណម និងពិធីសាសនាដែលជាបញ្ញត្តិសម្រាប់ស្ត្រី ឬក្មេងស្រី។

- នយោបាយ ៖ ស្ថានភាពនយោបាយមានឥទ្ធិពលលើអត្តសញ្ញាណ មិនថាតែតាមរយៈការចូលរួមជាមួយស្ថាប័ន ឬមនោគមវិជ្ជានយោបាយដែលគ្របដណ្ដប់លើគេ ឬជាការបះបោរប្រឆាំងនឹងពួកគេឡើយ។ ឧទាហរណ៍ ប្រសិនបើរដ្ឋាភិបាលមិនដាក់ទណ្ឌកម្មចំពោះការបរិភោគសាច់គោ ឬសាច់ជ្រូកទេ ការបរិភោគនេះអាចក្លាយជាផ្នែកមួយនៃការពេញចិត្តរបស់បុគ្គលនានាទោះបីជាយើងមិនបានបង្កើតឱ្យមានការពេញចិត្តនេះក្ដី។

- កត្តាប្រវត្តិសាស្ត្រផ្សេងៗដែលមានឥទ្ធិពលលើអត្តសញ្ញាណអាចដក់ជាប់យ៉ាងជ្រៅនៅក្នុងចិត្តបុគ្គលម្នាក់។ កត្តានេះអាចបង្ហាញឱ្យឃើញតាមរយៈទំនៀមទម្លាប់ក្នុងគ្រួសារដែលគេរំពឹងទុកថាសមាជិកគ្រួសារម្នាក់ៗនឹងអនុវត្តតាម។ ដូច្នេះអត្តសញ្ញាណរបស់គ្រួសារ និងអត្តសញ្ញាណរបស់បុគ្គលគឺជាអត្តសញ្ញាណរួម។ ឧទាហរណ៍ គ្រួសារវេជ្ជបណ្ឌិតអាចមិនសប្បាយចិត្តប្រសិនបើកូនណាម្នាក់ក្នុងគ្រួសារមានគេស្គាល់ច្រើនតាមរយៈមុខរបរជាអ្នកសម្ដែង។

◈ តើយើងបង្កើតភាពនៃ «ខ្លួនឯង» និង «អត្តសញ្ញាណ» ដោយរបៀបណា? មនុស្សម្នាក់ៗទទួលបានភាពនៃខ្លួនឯងជានរណាតាមរយៈប្រភពជាច្រើនដូចជា ៖ អារម្មណ៍ស្រមើស្រមៃផ្ទាល់ខ្លួន គ្រួសារ សហគមន៍ តំបន់ សញ្ជាតិ ជាដើម។ របៀបដែលយើងយល់ឃើញពីខ្លួនឯងមានលក្ខណៈខុសគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់។ អ្នកដែលមានសាវតារខុសគ្នាយល់ និងកំណត់អត្តសញ្ញាណខ្លួនឯងតាមរបៀបផ្សេងៗគ្នា។ ហើយពេលខ្លះ អ្នកដែលនៅក្នុងគ្រួសារតែមួយ (ដូចជាបងប្អូនបង្កើត)ដែល

---

-_second_edition_-_ch._4_pp._69-104_38_pages.pdf និង ICRW,. (២០១៦). *កម្មវិធីសិក្សា កែស ប្រនហ្ស៍ សម្រាប់នារីពេញវ័យ។* Gap Inc.

មានលក្ខណៈដូចគ្នាច្រើន ក៏អាចមានភាពខុសគ្នាយ៉ាងខ្លាំងដែរចំពោះ«ខ្លួនឯង»។ តើចំណុចមួយចំនួនក្នុងចំណោមចំណុចនានាស្តីពីខ្លួនយើងដែលមានភាពជាក់លាក់ និងមិនអាចផ្លាស់ប្តូរបាន និងចំណុចមួយចំនួនក្នុងចំណោមចំណុចនានាដែលអាចផ្លាស់ប្តូរបានមានអ្វីខ្លះ?

- ប្រការមួយចំនួនដូចជា ថ្ងៃខែឆ្នាំកំណើត ឬទីកន្លែងកំណើតរបស់មនុស្សម្នាក់គឺមិនអាចផ្លាស់ប្តូរបានទេ ហើយមានប្រការផ្សេងទៀតដែលមិនមានលក្ខណៈដាច់ខាត និងជាក់លាក់ដែលមនុស្សម្នាក់អាចជ្រើសរើសដើម្បីធ្វើការផ្លាស់ប្តូរបាន។ ការចូលចិត្ត ការមិនចូលចិត្ត គុណភាព និងជំនាញអាចផ្លាស់ប្តូរបាន។ ឧទាហរណ៍ មនុស្សម្នាក់អាចចូលចិត្តគូរគំនូរនាពេលបច្ចុប្បន្ននេះ តែបីឆ្នាំក្រោយមកគាត់អាចចូលចិត្តកីឡា ហើយលែងគូរគំនូរញឹកញាប់ដូចមុនទៀត។ ឬក៏មនុស្សម្នាក់ដែលជាមនុស្សស្ងៀមស្ងាត់ពេលនៅក្មេង ប៉ុន្តែក្រោយមកក៏ក្លាយជាមនុស្សនិយាយច្រើនទៅវិញ។ យើងទាំងអស់គ្នាមានសិទ្ធិសម្រេចចិត្តសម្រាប់ខ្លួនយើងផ្ទាល់នូវអ្វីដែលយើងចង់ធ្វើឱ្យបានសម្រេច និងអ្វីដែលយើងមិនចង់ធ្វើ។

**ផ្នែកទី ២** - លោកគ្រូ អ្នកគ្រូត្រូវ ៖

- ប្រគល់ក្រដាសរាងការេដែលបានកាត់រួចឱ្យទៅសិស្សម្នាក់ៗដើម្បីធ្វើលំហាត់នេះ។
- ឱ្យសិស្សកំណត់គុណសម្បត្តិពិសេសផ្ទាល់ខ្លួនមួយដែលគេចង់ឱ្យអ្នកដទៃដឹង។ សិស្សអាចសរសេរ ឬគូររូបភាពស្តីពីអត្តសញ្ញាណនោះនៅលើក្រដាស ហើយកិប ឬបិទជាប់នឹងខ្លួនពេញមួយថ្ងៃ។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- លុបដ្យាក្រាមអត្តសញ្ញាណគំរូដែលគូរលើក្តារខៀនចេញមុនពេលសិស្សចាប់ផ្តើមគូរដ្យាក្រាមផ្ទាល់ខ្លួនរបស់គេដើម្បីកុំឱ្យគេទទួលឥទ្ធិពលពី(ចម្លង)ដ្យាក្រាមនោះពេលអនុវត្តសកម្មភាពនេះ។
- ត្រៀមទុកដ្យាក្រាមអត្តសញ្ញាណគំរូលើក្រដាសព័ត៌មាន(ក្រដាសផ្ទាំងធំ)ដើម្បីងាយស្រួលយកមកមើលឡើងវិញនៅពេលត្រូវការពេលអនុវត្តសកម្មភាពនេះ។
- អាចពិភាក្សាពីកត្តាផ្សេងៗដូចជាភាសា អាយុ ការចូលចិត្ត ការមិនចូលចិត្ត ឥទ្ធិពលគ្រួសារ និងវង្សត្រកូល ឬវណ្ណៈ យេនឌ័រ (ឧទាហរណ៍ ប្រុស ស្រី ។ល។) សាសនា និងពិការភាពថាជាលក្ខខណ្ឌពីកំណើតចំពោះរបៀបដែលបុគ្គលម្នាក់ឆ្លងកាត់ពិភពលោកនេះដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើភាពនៃ«ខ្លួនឯង»របស់បុគ្គលម្នាក់។ គ្រូបង្រៀនត្រូវជូនដំណឹងដល់សិស្សថា គេនឹងសិក្សាស្វែងយល់លម្អិតពាក្យទាំងនេះច្រើនថែមទៀតនៅក្នុងម៉ូឌុល

នេះ ហើយថា ការលើកឡើងនូវពាក្យទាំងនេះនៅពេលនេះគឺដើម្បីឱ្យមានការចងចាំថា នៅពេលដែលកត្តាទាំងអស់នេះរួមបញ្ចូលគ្នា វានឹងធ្វើឱ្យមានផលប៉ះពាល់ដល់ភាពនៃ«ខ្លួនឯង» របស់បុគ្គលម្នាក់។ ការពិភាក្សានេះត្រូវប្រើរយៈពេលខ្លី និងស្របតាមវត្ថុបំណងរបស់សកម្មភាពនេះ។

**សារសំខាន់ៗ ៖**

- គំនិតរបស់យើងស្តីពី«ខ្លួនឯង» និង«អត្តសញ្ញាណ»វិវឌ្ឍន៍ទៅតាមពេលវេលា និងពេញមួយជីវិត។
- វាមានសារៈសំខាន់ណាស់ក្នុងការគោរព និងស្តាប់អំពីអ្វីដែលអ្នកដទៃគិត និងត្រូវនិយាយពីខ្លួនគេ។ នេះគឺជាជំហានទី១ក្នុងការទទួលស្គាល់ថា មនុស្សម្នាក់ៗមានអត្តសញ្ញាណពិសេសដាច់ដោយឡែកផ្ទាល់ខ្លួនរបស់គេ។

# មេរៀនទី២ ៖ ខ្ញុំ និងអ្នកដទៃ

🕒 **រយៈពេល ៖** ១ ម៉ោង

➲ **វត្ថុបំណង ៖** ដើម្បីយល់ដឹងពីរបៀបដែលបរិយាកាសជុំវិញ និងទំនាក់ទំនងខុសៗគ្នាមានឥទ្ធិពលទៅលើភាពនៃ «ខ្លួនឯង» របស់បុគ្គលម្នាក់ៗ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

- សម្រាប់គ្រូ៖ ក្រដាស A4 ខ្មៅដៃទៀនពណ៌(គូល័រទៀន) និងហ្វឺតពណ៌(គូល័រទឹក)។
- សម្រាប់សិស្ស៖ ក្រដាស A4 ៣សន្លឹក ខ្មៅដៃទៀនពណ៌(គូល័រទៀន) និងហ្វឺតពណ៌(គូល័រទឹក) និងសន្លឹកកិច្ចការក្នុងថ្នាក់របស់សិស្សទំព័រទី៧៨-៨០។

**ការរៀបចំទុកជាមុន ៖**

- អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។
- ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

## ២. ដំណើរការបង្រៀន

📢 **សេចក្ដីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកមេរៀនដែលពួកគេបានរៀនក្នុងជំពូកមុន។
- អានចំណងជើងមេរៀន ដោយចង្អុលទៅរកចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្ស ទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ហៅសិស្សស្ម័គ្រចិត្ត ២-៣ នាក់ ឱ្យចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុម។
- ឱ្យសិស្សគិត ប៉ុន្តែមិនត្រូវពិភាក្សាគ្នាទេ ថាតើគេមានអារម្មណ៍ដូចម្ដេចចំពោះការដើរចុះដើរឡើងដោយមានបិទជាប់នឹងខ្លួននូវគុណសម្បត្តិពិសេសរបស់ខ្លួនបន្ទាប់ពីអនុវត្តសកម្មភាពចុងក្រោយរួចមក។

*កិច្ចការក្នុងថ្នាក់ ៖*

☞ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួនទំព័រទី ៧៨-៨០។

☞ បែងចែកសិស្សជា៣ក្រុម។ ក្រុមនីមួយៗអាចជ្រើសរើសទីកន្លែងផ្សេងៗគ្នាមួយក្នុងបន្ទប់សម្រាប់អនុវត្តសកម្មភាពបន្ទាប់នេះ។

☞ ផ្តល់ក្រដាសសម្រាប់គូររូបចំនួន៣សន្លឹកឱ្យសិស្សម្នាក់ៗ ហើយក្រុមនីមួយៗត្រូវមានខ្មៅដៃទៀន ពណ៌ និងហ្វឺតពណ៌សម្រាប់ប្រើរួមគ្នា។

☞ ផ្តល់ប្រធានបទចំនួន៣ឱ្យសិស្ស ហើយប្រាប់ពួកគេឱ្យគូររូបអ្វីមួយដែលតំណាងឱ្យប្រធានបទនីមួយៗ។ ត្រូវអានប្រធានបទទី១ឱ្យសិស្សស្តាប់ និងប្រាប់ពួកគេពីពេលវេលាដែលត្រូវចាប់ផ្តើមគូរ ហើយសិស្សត្រូវប្រើក្រដាសមួយសន្លឹកដើម្បីគូររូប។ បន្ទាប់មក ប្រាប់សិស្សថាអស់ពេលហើយ ក្រោយពេលគេចំណាយពេល៥នាទីដើម្បីគូររូប។ បន្ទាប់មកទៀត អានប្រធានបទទី២ និងប្រធានបទទី៣បន្តទៀតរហូតដល់សិស្សគូររូបតំណាងឱ្យប្រធានបទទាំង ៣ រួចរាល់។ ជារួម សកម្មភាពគូររូបភាពនេះត្រូវចំណាយពេល១៥នាទី។ ប្រធានបទទាំង៣រួមមាន ៖

- ខ្ញុំ និងសាលារៀនរបស់ខ្ញុំ
- ខ្ញុំ និងផ្ទះរបស់ខ្ញុំ
- ខ្ញុំ និងមិត្តភក្តិរបស់ខ្ញុំ

☞ បន្ទាប់ពីគូរគំនូររួចហើយ ឱ្យសិស្សពិភាក្សាគ្នាពីគំនូរទាំងនេះនៅក្នុងក្រុមរបស់ខ្លួន។ សិស្សមានពេល៧នាទីដើម្បីពិភាក្សាគ្នា ហើយសមាជិកក្រុមទាំងអស់ត្រូវមានឱកាសនិយាយពីគំនិតរបស់ខ្លួន។ ការពិភាក្សានេះត្រូវផ្តោតទៅលើ ៖

- ភាពខុសគ្នាចំពោះរបៀបដែលពួកគេពិពណ៌នាពីខ្លួនឯងនៅក្នុងបរិបទខុសៗគ្នាទាំងអស់នេះ ប្រសិនបើមាន។ តើភាពខុសគ្នាទាំងនេះមានអ្វីខ្លះ ហើយហេតុអ្វីបានជាមានភាពខុសគ្នាទាំងនោះ?
- តើប្រធានបទមួយណាដែលពួកគេចូលចិត្តបំផុត? ហេតុអ្វី?

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

◈ តើសិស្សធ្លាប់អនុវត្តសកម្មភាពបែបនេះពីមុនមកដែរឬទេ? តើសកម្មភាពនេះធ្វើឱ្យពួកគេមានអារម្មណ៍បែបណា?

◈ តើបរិស្ថាន និងមនុស្សនៅជុំវិញខ្លួនមនុស្សម្នាក់ៗមានឥទ្ធិពលលើបុគ្គលនោះដែរ ឬទេ? ដោយ

របៀបណា?

- ☝ អ្វីដែលយើងគិតពីខ្លួនរបស់យើង និងអ្វីដែលអ្នកដទៃគិតចំពោះយើងមានឥទ្ធិពលលើភាពនៃជំនឿផ្ទាល់ខ្លួនរបស់យើង។ របៀបដែលយើងកំណត់អត្តសញ្ញាណ និងភាពនៃតម្លៃផ្ទាល់ខ្លួនរបស់យើងមានឥទ្ធិពលលើយើង និងអាកប្បកិរិយា (នៅកន្លែងធ្វើការ សាលារៀន ឬនៅក្នុងទំនាក់ទំនងនានា) ឥរិយាបថ សមត្ថភាព និងជម្រើសក្នុងជីវិតរបស់យើង។ ឧទាហរណ៍ កញ្ញាគិតថា នាងជាអ្នកនិពន្ធដ៏ល្អម្នាក់។ ប៉ុន្តែមិត្តភក្តិរបស់នាងគិតថា នាងធ្វើជាវាគ្មិនល្អជាងធ្វើជាអ្នកនិពន្ធ។ ក្រោយមក នាងបានចាប់ផ្តើមចូលរួមក្នុងការជជែកដេញដោល និងការពិភាក្សាជាច្រើន ហើយបានចំណាយពេលវេលាតិចតួចលើការតែងនិពន្ធ។ នាងមានអារម្មណ៍ថា នាងទទួលបានការកោតសរសើរ និងការទទួលស្គាល់ជាវាគ្មិនច្រើនជាងជាអ្នកនិពន្ធ។ នៅក្នុងឧទាហរណ៍នេះ យើងឃើញថាមានស្ថានភាពជាច្រើននៅក្នុងជីវិតរបស់យើងដែលយើងអាចបណ្តុះនូវចំណុចពិសេសជាក់លាក់មួយចំនួនសម្រាប់អត្តសញ្ញាណរបស់យើងដោយសារតែឥទ្ធិពលរបស់អ្នកដទៃ។ យើងអាចព្យាយាមធ្វើឱ្យអ្នកដទៃចាប់អារម្មណ៍មកលើយើងនៅពេលយើងមានអារម្មណ៍ថា យើងទទួលបានការបញ្ជាក់អះអាង និងការទទួលស្គាល់ជាវិជ្ជមានពីអ្នកទាំងនោះចំពោះអត្តសញ្ញាណ និងខ្លួនរបស់យើង។

- ◈ ការរៀបឥរិយាបថ និងការពិពណ៌នាពីខ្លួនឯងតាមរបៀបផ្សេងៗក្នុងបរិយាកាសខុសៗគ្នា ដូចជានៅសាលារៀន ផ្ទះ ភូមិ ឬសហគមន៍។

- ☝ ការពិភាក្សានេះត្រូវផ្តែកលើរូបភាពដែលបានគូរពេលអនុវត្តសកម្មភាពនេះ។ បុគ្គលម្នាក់មានបទពិសោធន៍ចំពោះកម្រិតនៃភាពងាយស្រួលខុសៗគ្នាជាមួយមនុស្សផ្សេងៗគ្នា និងស្ថានភាពខុសៗគ្នា។ ឧទាហរណ៍ អាចមានប្រធានបទមួយចំនួនដែលគេអាចមានអារម្មណ៍ថាធម្មតាក្នុងការពិភាក្សាជាមួយម្តាយ ឬឪពុករបស់គេដោយងាយ ខណៈដែលមានបញ្ហាមួយចំនួនទៀតគេពេញចិត្តពិភាក្សាជាមួយមិត្តភក្តិជាងជាមួយឪពុកម្តាយ បើទោះបីជាមានសេចក្តីស្រឡាញ់ និងការជឿទុកចិត្តនៅក្នុងទំនាក់ទំនងទាំងអស់នេះក៏ដោយ។ ស្រដៀងគ្នានេះដែរ ស្ថានភាពផ្សេងគ្នាក៏ទាមទារឱ្យមានឥរិយាបថផ្សេងគ្នាដែរពីមនុស្សដទៃ។ សាលារៀនអាចមានលក្ខណៈផ្លូវការជាងផ្ទះរបស់មិត្តភក្តិ។ ប្រសិនបើមនុស្សម្នាក់ចូលចិត្តទៅលេងផ្ទះមិត្តភក្តិច្រើនជាងការទៅរៀននៅក្នុងថ្នាក់ ពួកគេអាចមើលឃើញខ្លួនឯងថាជាមនុស្សងាយចូលសង្គមច្រើនជាងជាមនុស្សម្នាក់ដែលចូលចិត្តរៀនសូត្រ។ ជារឿយៗ ក្មេងស្រីអាចមានអត្តសញ្ញាណខុសៗគ្នានៅកន្លែងផ្សេងៗដូចជានៅសាលារៀន ផ្ទះ ឬផ្ទះរបស់មិត្តភក្តិ។ ពួកគេអាចនឹងគោរពតាមឥរិយាបថដែលគួរធ្វើ និងមិនគួរធ្វើមួយចំនួនដែលអាចរួមចំណែកដល់របៀបដែលពួកគេយល់ឃើញ និងមើលឃើញខ្លួនឯង។ ដូច្នេះ អត្តញ្ញាណអាចប្រែប្រួលទៅតាមទីកន្លែង ឬស្ថានភាព

ដែលយើងស្ថិតនៅ។

- គំនិតចុងក្រោយ វាមានសារៈសំខាន់ក្នុងការចំណាយពេលវេលានៅចុងម៉ោងជារៀងរាល់ថ្ងៃ ដើម្បីគិតពីអន្តរកម្មរបស់យើងជាមួយមនុស្ស ឬក្នុងស្ថានភាពផ្សេងៗសម្រាប់បង្កើនការយល់ដឹងរបស់យើងពីខ្លួនឯង។

◇ ហេតុអ្វីបានជាវា នសារៈសំខាន់ក្នុងការនិយាយពីបញ្ហានេះ?

- ការយល់ដឹងដោយខ្លួនឯង ការដឹងពីការចូលចិត្ត ការមិនចូលចិត្ត គុណសម្បត្តិ កម្រិតនៃភាពងាយស្រួល និងការលើកទឹកចិត្ត (មូលហេតុដែលយើងធ្វើអ្វីមួយ) មានសារៈសំខាន់ណាស់ក្នុងការជួយយើងឱ្យស្គាល់ពីខ្លួនឯង។ នេះគឺជារបៀបដែលបុគ្គលម្នាក់អាចជ្រើសរើសថាតើចំណុចពិសេសអ្វីនៃអត្តសញ្ញាណរបស់គេដែលត្រូវរក្សាទុក និងអ្វីដែលត្រូវផ្លាស់ប្តូរ។
- ឧទាហរណ៍ មនុស្សមួយចំនួនអាចមិនមានភាពជឿជាក់ចំពោះស្ថានភាពសង្គមមួយចំនួន និងអាចជាចង់ធ្វើឱ្យមានការផ្លាស់ប្តូរចំពោះចំណុចនោះ ខណៈពេលដែលមនុស្សមួយចំនួនទៀតមានអារម្មណ៍ថាពួកគេមានយុត្តិធម៌ចំពោះអ្នកដទៃ ហើយចង់រក្សាគុណសម្បត្តិនេះជាផ្នែកមួយនៃអត្តសញ្ញាណរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ លក្ខណៈមួយចំនួននៃអត្តសញ្ញាណអាចទទួលរងឥទ្ធិពលពីសហគមន៍ ផ្នត់គំនិតផ្នែកវប្បធម៌ និងការរំពឹងទុក ហើយប្រហែលជាមិនងាយផ្លាស់ប្តូរទេ។ ឧទាហរណ៍ការកាន់គ្រណមបែបសាសនាយ៉ាងខ្ជាប់ខ្ជួនដោយសារប្រពៃណីគ្រួសារ ឬការដែលក្មេងស្រីមិនលេងកីឡាមួយចំនួនដូចជាបាល់ទាត់ក្តីព្រោះតែសង្គម និងសហគមន៍អាចទទួលយកបានការលេងបាល់ទាត់សម្រាប់តែក្មេងប្រុសប៉ុណ្ណោះ។

◇ តើមនុស្សម្នាក់ជ្រើសរើសយកចំណុចពិសេសនៃអត្តសញ្ញាណអ្វីខ្លះដើម្បីរក្សាទុក និងបណ្តុះបន្ថែម ហើយចំណុចអ្វីខ្លះដែលត្រូវផ្លាស់ប្តូរដោយរបៀបណា?

- ពេលខ្លះ មានចំណុចពិសេសផ្សេងៗនៃអត្តសញ្ញាណរបស់យើងដែលយើងចូលចិត្ត ប៉ុន្តែអ្នកផ្សេងមិនចូលចិត្ត ឬមនុស្សមួយចំនួនទៀតអាចចាត់ទុកចំណុចពិសេសទាំងនោះថាខុស ឬមិនសមស្រប។ ឧទាហរណ៍ ប្រសិនបើក្មេងស្រីម្នាក់ចូលចិត្តនិយាយ ឬសួរពីអ្វីដែលនាងបានឮមនុស្សមួយចំនួនអាចប្រាប់នាងថា វាមិនមែនជាការត្រឹមត្រូវ សម្រាប់ក្មេងស្រីក្នុងការនិយាយស្តី ឬសួរនាំច្រើន។ កត្តានេះអាចមានផលប៉ះពាល់ជាអវិជ្ជមានដល់ភាពនៃអត្តសញ្ញាណរបស់នាងពោលគឺ នាងអាចលែងហ៊ាននិយាយស្តី និងអាចលែងមានសមត្ថភាពបញ្ចេញមតិផ្ទាល់ខ្លួនដោយសេរី។ វាមានសារៈសំខាន់ណាស់ក្នុងការចងចាំថា វាជារឿងត្រឹមត្រូវក្នុងការសម្រេចចិត្តខ្លួនឯងថាតើចំណុចពិសេសអ្វីនៃអត្តសញ្ញាណរបស់ខ្លួនដែលត្រឹមត្រូវក្នុងការរក្សាទុក និងមួយណាដែលមិនត្រូវរក្សាទុក។ ការសម្រេចចិត្តនេះគឺមិនងាយស្រួលនោះទេ។ ការឆ្លុះបញ្ចាំងថាតើអត្តសញ្ញាណ ឬចំណុចពិសេសមួយនៃអត្តសញ្ញាណរបស់បុគ្គលម្នាក់កំពុងធ្វើឱ្យនរណា

ម្នាក់ឈឺចាប់ រួមទាំងខ្លួនឯងផង ឬកំពុងបង្កើត ឬកំពុងជម្រុញឱ្យមានវិសមភាព និងភាពអយុត្តិធម៌ចំពោះនរណាម្នាក់ រួមទាំងខ្លួនឯងផង គឺជាវិធីសាស្រ្តដ៏ល្អក្នុងការឈានទៅរកការសម្រេចចិត្តនេះ។ ប្រសិនបើចំណុចពិសេសមួយបង្កឱ្យមានការឈឺចាប់ ឬភាពអយុត្តិធម៌ នោះគេត្រូវធ្វើការពិចារណាឡើងវិញ និងតម្រូវឱ្យមានការខិតខំប្រឹងប្រែងដើម្បីផ្លាស់ប្ដូរអ្វីមួយ។

- វិធីមួយទៀតដើម្បីឈានទៅរកការសម្រេចចិត្តទាំងនេះគឺត្រូវឆ្លុះបញ្ចាំងទៅលើចំណុចពិសេសនៃអត្តសញ្ញាណរបស់នរណាម្នាក់ដែលធ្វើឱ្យខ្លួនគេសប្បាយចិត្ត និងមានអារម្មណ៍ល្អ។ ដូចជា «គុណសម្បត្តិពិសេស» ដែលគ្រូបង្រៀនឱ្យសិស្សស្វែងរកពីខ្លួនគេកន្លងមក។ ចំណុចពិសេសទាំងនេះអាចមានតម្លៃក្នុងការផ្តោតការយកចិត្តទុកដាក់ និងបណ្តុះបន្ថែម។
- ទោះជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ក្នុងការយល់ថា មនុស្សម្នាក់ៗគឺជាបុគ្គលមួយរូបដែលមានលក្ខណៈខុសពីបុគ្គលផ្សេងទៀត។ មនុស្សផ្សេងគ្នាមានការចូលចិត្ត និងមិនចូលចិត្តផ្សេងៗគ្នាចំពោះខ្លួនគេផ្ទាល់ និងចំពោះគ្នាទៅវិញទៅមក។ វាមានសារៈសំខាន់ណាស់ក្នុងការគោរពចំពោះភាពខុសគ្នាទាំងនេះ និងយល់ពីចំណុចទាំងនោះដោយស្តាប់នូវអ្វីដែលអ្នកដទៃនិយាយពីខ្លួនគេ។ វាក៏មានសារៈសំខាន់ដូចគ្នាដែរក្នុងការគោរពចំពោះខ្លួនឯងផ្ទាល់ និងរំពឹងថា អ្នកដទៃក៏មានការគោរពដូចគ្នាដែរ។ នេះគឺជាគន្លឹះនៃទំនាក់ទំនងជាវិជ្ជមានជាមួយខ្លួនឯង និងជាមួយអ្នកដទៃទៀត។

**គន្លឹះសម្រាប់គ្រូបង្រៀន ៖**

ទស្សនៈទានមួយចំនួនក្នុងចំណោមទស្សនៈទានទាំងនេះ ដូចជាការគោរពខ្លួនឯង និងការរំពឹងទុកថា គំនិត និងទស្សនៈរបស់ខ្លួនទទួលបានការគោរពពីអ្នកដទៃអាចតម្រូវឱ្យមានពេលវេលាសម្រាប់ពន្យល់ ឬពិភាក្សាបន្ថែមដោយធៀបទៅនឹងទស្សនៈទានផ្សេងទៀត។

សិស្សមួយចំនួនប្រហែលជាមានការស្ទាក់ស្ទើរក្នុងការកំណត់ពីចំណុចល្អពីខ្លួនគេ ខណៈដែលសិស្សដទៃទៀតអាចធ្វើបានយ៉ាងឆាប់រហ័ស។ លោកគ្រូ អ្នកគ្រូត្រូវមានការប្រុងប្រយ័ត្នថា ការប្រៀបធៀបបែបអវិជ្ជមាន ភាពអៀនខ្មាស ឬការនិយាយមិនបានល្អមិនបង្កជាឧបសគ្គដល់សិស្សទេ។

✉ **សារសំខាន់ៗ ៖**

- មនុស្សមានបទពិសោធន៍ដោយខ្លួនឯងចំពោះអន្តរកម្មជាមួយនឹងបរិស្ថានជុំវិញខ្លួន និងទំនាក់ទំនងផ្សេងៗ។
- អត្តសញ្ញាណវិវឌ្ឍន៍ និងផ្លាស់ប្តូរទៅតាមពេលវេលា ព្រមទាំងក្រោមឥទ្ធិពលរបស់អ្នកដទៃ និងស្ថានភាពផ្សេងៗ។
- មនុស្សម្នាក់អាចជ្រើសរើសការបណ្តុះ និងបន្តរក្សាទុកនូវចំណុចពិសេសនៃអត្តសញ្ញាណរបស់ខ្លួនដែលខ្លួនយល់ឃើញថាមានភាពវិជ្ជមាន។

**ក្របខណ្ឌចំណេះដឹង**

«គេអាចយល់ពីអត្តសញ្ញាណយ៉ាងសាមញ្ញថាជាភាពមួយដែលថាយើងជានរណា»។ មនុស្សម្នាក់ទទួលបានភាពថាខ្លួនឯងជានរណាតាមរយៈប្រភពជាច្រើនដែលមានដូចជា ៖ អារម្មណ៍ស្រមើស្រមៃផ្ទាល់ខ្លួន គ្រួសារ សហគមន៍ ការរំពឹងទុកចំពោះយេនឌ័រដែលពាក់ព័ន្ធនឹងភេទរបស់ខ្លួន អាយុ សាសនា វង្សត្រកូល តំបន់ សញ្ជាតិជាដើម។ ហេតុនេះហើយ ក្នុងនាមជាបុគ្គលដ៏ស្មុគ្រស្មាញ យើងម្នាក់ៗទទួលរងនូវឥទ្ធិពលផ្នែកផ្លូវចិត្ត វប្បធម៌សង្គម និងនយោបាយនៅក្នុងជីវិតដែលធ្វើឱ្យយើងក្លាយជាបុគ្គលខុសប្លែកពីគេ។ របៀបដែលយើងកំណត់អត្តសញ្ញាណរបស់យើង និងភាពនៃតម្លៃផ្ទាល់ខ្លួនមានឥទ្ធិពលសំខាន់ៗ និងធំធេងជាច្រើនមកលើអាកប្បកិរិយា (នៅកន្លែងធ្វើការ សាលារៀន ឬនៅក្នុងទំនាក់ទំនងនានា) ឥរិយាបថ សមត្ថភាព និងជម្រើសក្នុងជីវិតរបស់យើង។ វាក៏មានផលប៉ះពាល់យ៉ាងខ្លាំងផងដែរចំពោះសក្តានុពលរបស់យើងក្នុងនាមជាមនុស្ស និងសមត្ថភាពរបស់យើងក្នុងការដឹងអំពីសក្តានុពលនោះ។ វ័យជំទង់គឺជារយៈពេលដែលមានការផ្លាស់ប្តូរជាច្រើនចំពោះរាងកាយ និងផ្លូវចិត្ត។ ក្នុងនាមជាក្មេងជំទង់ កុមារីឆ្លងកាត់បទពិសោធន៍ទាក់ទងនឹងបំណងប្រាថ្នា និងបញ្ហាប្រឈមដែលមានលក្ខណៈពិសេសដាច់ដោយឡែកដែលអាចមានលក្ខណៈខុសពីបំណងប្រាថ្នា និងការប្រឈមដែល«យុវវ័យ» ឬ«ស្ត្រី»ជួបប្រទះ[៩]។ (Standard Chartered (២០០៩) គោលការណ៍ណែនាំពីសកម្មភាពគោលដៅ មូលនិធិ Naz ការធ្វើឱ្យក្មេងស្រីជំទង់មានលទ្ធភាពឱ្យតម្លៃខ្លួនឯង កសាងអត្តសញ្ញាណរបស់ខ្លួនតាមលក្ខខណ្ឌរបស់ខ្លួនផ្ទាល់ និងពង្រឹងតម្លៃផ្ទាល់ខ្លួនគឺមានសារៈសំខាន់ណាស់ចំពោះដំណើរការនៃការពង្រឹងការគិតដោយឯករាជ្យ និងការកសាងទំនុកចិត្ត។

[៩] (ស្តាបនាតាមបទដ្ឋាន ២០០៩), *គោលការណ៍ណែនាំពីសកម្មភាពគោលដៅ* ។ មូលនិធិ Naz

# ជំពូកទី២ ៖ យេនឌ័រ

## ទិដ្ឋភាពទូទៅ[៥]

គោលបំណងនៃជំពូកនេះគឺដើម្បីកសាងការយល់ដឹងរបស់សិស្សស្តីពីយេនឌ័រ និងរបៀបដែលយេនឌ័រកើតឡើងទៅតាមការកំណត់របស់សង្គម។ ភាពខុសគ្នាផ្នែកយេនឌ័រដែលគេយល់ឃើញទាំងនេះនាំទៅរកវិសមភាពដែលជារឿយៗដាក់កម្រិតលើការរីកចម្រើន និងការអភិវឌ្ឍន៍របស់មនុស្ស និងរំលោភបំពានលើសិទ្ធិមនុស្សរបស់គេ។

«យេនឌ័រសំដៅទៅលើសំណុំនៃលក្ខណៈសម្បត្តិ ការរំពឹងទុក និងតួនាទីដែលសង្គមឱ្យតម្លៃទៅលើមនុស្សម្នាក់ដែលកើតមកជាប្រុសឬជាស្រី។ អត្តសញ្ញាណផ្នែកយេនឌ័រ សំដៅទៅលើភាពផ្ទាល់ខ្លួន ថាតើបុគ្គលនោះជានរណា។ ដូច្នេះ ដើម្បីឱ្យងាយយល់ទី១ (យេនឌ័រ) គឺជាអ្វីដែលសង្គមរំពឹងទុកពីបុគ្គលម្នាក់ហើយទី២ (អត្តសញ្ញាណយេនឌ័រ) គឺរបៀបដែលបុគ្គលម្នាក់មាន អារម្មណ៍ចេញពីក្នុងខ្លួន។» (ប្រភព ៖ សៀវភៅពណ៌ខៀវ។ (២០១៣) TARSHI)

វាមានសារៈសំខាន់ណាស់ក្នុងការដឹងថា តួនាទី និងការរំពឹងទុកផ្នែកយេនឌ័រគឺសង្គម ព្រមទាំងបទដ្ឋាន និងគុណតម្លៃនៃវប្បធម៌សង្គមជាអ្នកកំណត់។ រឿងទាំងនេះមិនមានក្នុងសិលាចារឹកទេ ហើយគេក៏ត្រូវលើកជាសំណួរដែរ។ សង្គមអាចកំណត់អាកប្បកិរិយា និងច្បាប់សម្រាប់ក្មេងប្រុស និងក្មេងស្រី ព្រមទាំងបុរស និងស្ត្រីខុសៗគ្នា និងតាមវិធីផ្សេងគ្នា ទីកន្លែងផ្សេងគ្នា និងនៅពេលវេលាជាប្រវត្តិសាស្ត្រខុសៗគ្នា។ ដូច្នេះ នៅកន្លែងជាច្រើន សហគមន៍បិតាធិបតេយ្យដែលតឹងរ៉ឹងអាចព្យាយាមរឹតបន្តឹងចំពោះការដើរហើររបស់ស្ត្រី និងក្មេងស្រី ឬសិទ្ធិប្រើប្រាស់បច្ចេកវិទ្យារបស់ពួកគេដោយសារតែតួនាទី និងទស្សនៈផ្នែកយេនឌ័រ។ នៅកន្លែងផ្សេងទៀត គេអាចរំពឹងទុកថាក្មេងប្រុស និងបុរសត្រូវមានភាពប្រកួតប្រជែង និងយកឈ្នះគេបើមិនដូច្នេះទេ ពួកគេចូលចំណោមគេមិនចុះទេ។ ទោះជាយ៉ាងណាក៏ដោយ ទាំងនេះគឺជាការរំពឹងទុករបស់សង្គមប៉ុណ្ណោះ ហើយគេអាចជម្នះ និងផ្លាស់ប្តូរបានដើម្បីសមភាពយេនឌ័រ និងសង្គមមួយដែលមានភាពយុត្តិធម៌ផ្នែកយេនឌ័រ។

---

[៥] ICRW,. (២០១៦) *កម្មវិធីសម្រាប់ក្មេងស្រីពេញវ័យរបស់គែស ប្រនហ្វ* Gap Inc., និង TARSHI,. (២០១៣). *សៀវភៅពណ៌ខៀវ (The Blue Book )* Young Zubaan

🕘 **រយៈពេលរួម ៖ ៥ ម៉ោង ៥០ នាទី**

🗗 **ចំនួនលំនាំបង្រៀនសរុប ៖ ៦ មេរៀន**

## 🏆 វត្ថុបំណង ៖

- ☺ យល់ដឹងពីភាពខុសគ្នារវាងភេទ និងយេនឌ័រ។
- ☺ យល់ដឹងថា យេនឌ័រគឺជាទម្រង់នៃការកំណត់របស់សង្គម និងក្លាយទៅជាមូលដ្ឋានសម្រាប់ការដាក់កម្រិតជាច្រើន។
- ☺ មានការយល់ដឹងស៊ីជម្រៅពីរបៀបដែលយេនឌ័រ តួនាទីយេនឌ័រ និងផ្នត់គំនិតផ្សេងៗជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងការរើសអើង ជាពិសេសដោយសារទំនាក់ទំនងរវាងអំណាច និងបិតាធិបតេយ្យ។
- ☺ យល់ដឹងអំពីទស្សនៈទាននៃអំណាច និងផលជះរបស់វាមកលើជីវិត ជាពិសេសទៅលើការធ្វើសេចក្តីសម្រេចចិត្ត និងសមត្ថភាពនៃការចរចា។
- ☺ យល់ដឹងថា ការយល់ឃើញ និងទម្រង់នៃការរើសអើងផ្នែកយេនឌ័រទាំងនេះអាចជម្នះបាន ហើយការផ្លាស់ប្តូរគឺអាចធ្វើទៅបានដោយជោគជ័យ។

# មេរៀនទី៣ ៖ ការយល់ដឹងពីយេនឌ័រ[៦]

**រយៈពេល** ៖ ១ ម៉ោង

**វត្ថុបំណង** ៖ ដើម្បីយល់ដឹងពីទស្សនៈទានផ្នែកយេនឌ័រ និងរបៀបដែលសង្គមកំណត់ពីទស្សនៈទាន នេះ។

## ១. ការរៀបចំ

**សម្ភារៈដែលត្រូវការ ៖**

- សម្រាប់គ្រូ៖ ក្រដាសផ្ទាំងធំ និងហ្វឺត ក្រដាសព័ត៌មាន ហ្វឺតពណ៌។
- សម្រាប់សិស្ស៖ ក្រដាសផ្ទាំងធំ១សន្លឹក ហ្វឺតពណ៌ និង សន្លឹកកិច្ចការផ្ទះរបស់សិស្សទំព័រទី៨១។

**ការរៀបចំទុកជាមុន ៖**

- អានទិដ្ឋភាពទូទៅស្តីពី ជំពូកទី២ ៖ យេនឌ័រ និងស្វែងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។
- ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

## ២. ដំណើរការបង្រៀន

**សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួន ដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកមេរៀនដែលពួកគេបានរៀនក្នុងជំពូកមុន។
- អានចំណងជើងមេរៀន ដោយចង្អុលទៅរកចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្ស ទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ហៅសិស្សស្ម័គ្រចិត្ត ២-៣ នាក់ ឱ្យចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុម។
- បន្ទាប់មកចែកសិស្សជា៤ក្រុម ហើយផ្តល់ក្រដាសព័ត៌មានមួយសន្លឹក និងហ្វឺតពណ៌មួយចំនួនដល់ក្រុមនីមួយៗ។ លំហាត់នេះគឺទាក់ទងនឹងការបង្កើតពាក្យដែលទាក់ទងនឹងពាក្យ «បុរស» និង «ស្ត្រី»។

---

[៦] TARSHI,. (២០០៦). *មូលដ្ឋាន និងលើសពីមូលដ្ឋាន សៀវភៅមគ្គុទេសក៍សម្រាប់គ្រូបង្វឹក 'ការរួមបញ្ចូលគ្នា ផ្លូវភេទ សិទ្ធិ និងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ'*។ ទីក្រុងញូដេលី។
ក្រុមការងារផ្លូវភេទអន្តរជាតិ និងកម្មវិធីមេរោគអេដស៍(២០០៩)។ *គ្រប់យ៉ាងតែមួយ*។ ក្រុមប្រឹក្សាចំនួនប្រជាជន។

បន្ទាប់មក ឱ្យក្រុមទាំងអស់បង្ហាញពីបណ្តុំពាក្យរបស់ខ្លួនទាំងនោះទៅកាន់ក្រុមធំ។ ក្រដាសព័ត៌មានត្រូវចែកជា២កូឡោនគឺ កូឡោនមួយដាក់ថា «បុរស» និងមួយទៀតដាក់ថា «ស្ត្រី»។

☞ អាចគូសក្រដាសព័ត៌មាននេះនៅលើក្តារខៀនជាគំរូដូចបានបង្ហាញខាងក្រោមនេះ ៖

| បុរស | ស្ត្រី |
|---|---|
| | |

☞ ឱ្យក្រុមទាំងអស់សរសេរបណ្តុំពាក្យរបស់ខ្លួននៅក្នុងកូឡោននីមួយៗ។ (លោកគ្រូ អ្នកគ្រូអាចផ្តល់ឧទាហរណ៍មួយពីបណ្តុំពាក្យដែលទាក់ទងនឹងសត្វ «ឆ្មា» ដែលអាចរួមបញ្ចូលទាំងពាក្យពណ៌ខ្មៅ គួរឱ្យស្រលាញ់ កន្ទុយ លឿន សត្វចិញ្ចឹម ត្រី ព្រៃ ។ល។)។

☞ ឱ្យសិស្សពិភាក្សាគ្នា និងសរសេរពី ៧ ទៅ ១០ ពាក្យនៅក្នុងកូឡោននីមួយៗ។ ពួកគេមានពេល ១០ នាទីដើម្បីធ្វើកិច្ចការនេះ។

☞ បន្ទាប់ពីការបញ្ចប់កិច្ចការនេះ ឱ្យក្រុមនីមួយៗចែករំលែកពាក្យចំនួន ២ ក្នុងបញ្ជីរបស់ខ្លួនជាមួយក្រុមធំ។ លោកគ្រូ អ្នកគ្រូត្រូវសរសេរពាក្យទាំងនោះនៅលើក្តារខៀននៅក្នុងកូឡោន «បុរស» និង «ស្ត្រី» រៀងៗគ្នា។ ក្រុមទាំងអស់មិនត្រូវយកពាក្យណាដែលក្រុមផ្សេងបានបង្ហាញ និងមានសរសេរលើក្តារខៀនរួចហើយមកចែករំលែកទេ។

☞ ឱ្យសិស្សចាត់ថ្នាក់ពាក្យនីមួយៗថា វាមានលក្ខណៈពិតប្រាកដបែបជីវសាស្ត្រ (តាងដោយអក្សរ «ជ») ឬជាទស្សនៈទាន ឬគំនិតមួយដែលសង្គមបានបង្កើតឡើង (តាងដោយអក្សរ «ស») តាមរយៈការលើកដៃបោះឆ្នោត។ ដូច្នេះ នៅចុងបញ្ចប់នៃលំហាត់ ពាក្យនីមួយៗនៅលើក្តារខៀននឹងត្រូវបានសម្គាល់ដោយអក្សរ «ជ» ឬ «ស» ។

☞ ពាក្យទាំងនេះដែលស្ថិតនៅក្នុងផ្នែកជីវសាស្ត្រ ឬសង្គមនឹងក្លាយជាមូលដ្ឋានគ្រឹះនៃការពិភាក្សាលើយេនឌ័រ។ ពាក្យណាមួយដែលសិស្សចាត់ថ្នាក់ខុសគឺត្រូវពិភាក្សា និងចាត់ថ្នាក់ឡើងវិញ។

*កិច្ចការផ្ទះ ៖*

☞ ក្រោយចប់សកម្មភាពខាងលើ គ្រូណែនាំសិស្សអំពីកិច្ចការផ្ទះដែលពួកគេត្រូវធ្វើ។

☞ ឱ្យពួកគេបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៨១។

☞ អានសេចក្តីណែនាំនៅក្នុងសន្លឹកកិច្ចការ បន្ទាប់មកពន្យល់ពីអ្វីដែលពួកគេចាំបាច់ត្រូវធ្វើ។

### ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

- តើលំហាត់នេះមានគោលបំណងអ្វី?

- តើយេនឌ័រជាអ្វី? តើភេទជាអ្វី?

  - ភេទសំដៅទៅលើភាពខុសគ្នាផ្នែកជីវសាស្ត្ររវាងភេទប្រុស និងភេទស្រីដោយផ្អែកលើប្រដាប់បន្តពូជ និងហៃ្សន។ យេនឌ័រពណ៌នាអំពីលក្ខណៈដែលសង្គមចាត់ទុកថាសមស្របសម្រាប់បុរស និងស្ត្រី។ ដូច្នេះ យេនឌ័រគឺការកំណត់របស់សង្គម (ការកំណត់របស់សង្គមគឺជាទស្សនៈទាន ឬការអនុវត្តមួយដែលជាការកំណត់ ឬជាគំនិតរបស់ក្រុម ឬសង្គមជាក់លាក់មួយ ហើយវាមិនមែនជាលទ្ធផលនៃគុណសម្បត្តិដែលមានពិតប្រាកដទៅតាមទស្សនៈទានដែលនៅស្រពិចស្រពិលនោះទេ)។ ដូចគ្នានេះដែរ តួនាទី និងគំនិតដែលសង្គមបានកំណត់គឺមានលក្ខណៈខុសគ្នាពីវប្បធម៌មួយ ទៅវប្បធម៌មួយ និងសូម្បីតែនៅក្នុងសង្គម ឬវប្បធម៌ដូចគ្នា ក៏មានភាពខុសគ្នាពីជំនាន់មួយទៅជំនាន់មួយដែរ។

- តើយេនឌ័រមានតែ ២ សម្រាប់តែប្រុស និងស្រីប៉ុណ្ណោះឬ?[៧]

  - មិនមែនទេ។ យេនឌ័រមិនមែនមានតែ «ភេទប្រុស» និង«ភេទស្រី» ២ ប៉ុណ្ណោះទេ។ ខណៈដែលភេទសំដៅទៅលើលក្ខណៈពិសេសផ្នែកជីវសាស្ត្ររបស់មនុស្សម្នាក់ យេនឌ័រពណ៌នាពីលក្ខណៈដែលសង្គមចាត់ទុកថាសមស្របសម្រាប់បុរស និងស្ត្រី។ ទោះជាយ៉ាងណាក៏ដោយ មនុស្សមួយចំនួនប្រហែលជាមិនបានកំណត់ពីយេនឌ័រដែលគេផ្តល់ទៅឱ្យខ្លួនទេ ហើយអ្នកផ្សេងទៀតក៏ប្រហែលជាមិនបានកំណត់ថាខ្លួនឯងជា «ភេទប្រុស» ឬជា «ភេទស្រី» ដែរ។ យេនឌ័រមានមូលដ្ឋានលើការរំពឹងទុកដែលសង្គម ឬវប្បធម៌មួយមានចំពោះអាកប្បកិរិយា និងតួនាទីសមស្របសម្រាប់បុរស និងស្ត្រី។ **អត្តសញ្ញាណយេនឌ័រ** សំដៅទៅលើរបៀបដែលមនុស្សមានអារម្មណ៍ពោលគឺ មិនថាពួកគេគិតពីខ្លួនឯងថាជាប្រុស ជាស្រី ទាំងពីរភេទ ឬថាជាយេនឌ័រខុសគ្នាមួយទេ។ ឧទាហរណ៍ សម្រាប់មនុស្សមួយចំនួន ភេទដែលមានពីកំណើតស្របគ្នានឹងរបៀបដែលពួកគេយល់ឃើញចំពោះយេនឌ័ររបស់ខ្លួន ពោលគឺកើតមកជាស្រីធម្មតា និងមានអារម្មណ៍ពេញចិត្តចំពោះការកំណត់ថាខ្លួនជាស្ត្រី(ចំពោះយេនឌ័រ)។ ក៏ប៉ុន្តែ សម្រាប់អ្នកខ្លះទៀត វាប្រហែលជាមិនមានលក្ខណៈដូចគ្នាទេ ពោលគឺ មនុស្សមួយចំនួនប្រហែលជាមិនមានអារម្មណ៍ពេញចិត្តចំពោះភេទពីកំណើតរបស់ខ្លួនទេ ហើយអាចកំណត់ខ្លួនឯងថាស្ថិតនៅក្នុងក្រុមយេនឌ័រខុសគ្នាមួយ។ មនុស្សទាំងនេះគឺជាប្រភេទមនុស្ស «ប្តូរយេនឌ័រ»។

---

[៧] TARSHI,. (២០០៦). *មូលដ្ឋាន និងលើសពីមូលដ្ឋាន សៀវភៅមគ្គុទេសក៍សម្រាប់គ្រូបង្វឹក "ការរួមបញ្ចូលគ្នា ផ្លូវភេទ សិទ្ធិ និងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។* ទីក្រុងញូដេលី។

◈ តើពាក្យថា «ប្តូរយេនឌ័រ»មានន័យដូចម្តេច?

☝ អ្នកប្តូរយេនឌ័រសំដៅទៅលើបុគ្គលម្នាក់ដែលមិនកំណត់យកយេនឌ័រដែលពួកគេមានពីកំណើត ទៅតាមលក្ខណៈជីវសាស្រ្ត(ភេទ)ដែលខ្លួនមាន។ ពួកគេអាច ឬមិនអាចសម្រេចចិត្តប្តូរយេនឌ័រ ដែលពួកគេមានតាំងពីកំណើតទៅជាយេនឌ័រដទៃទៀតបានតាមរយៈការវះកាត់ និងនីតិវិធីវេជ្ជសាស្រ្តផ្សេងទៀត។

◈ ហេតុអ្វីបានជាការយល់ថាយេនឌ័រគឺជាការកំណត់របស់សង្គមមានសារៈសំខាន់?

☝ វាមានសារៈសំខាន់ណាស់ក្នុងការបែងចែកភាពខុសគ្នារវាងអ្វីដែលសង្គមបានកំណត់សម្រាប់យេនឌ័រនីមួយៗ និងអ្វីដែលជាលក្ខណៈជីវសាស្រ្ត។ ឧទាហរណ៍ គំនិតដែលថា បុរសមិនយំគឺជាការកំណត់របស់សង្គម ចំណែកឯការពិតដែលថា សំឡេងរបស់ពួកគេកាន់តែគ្រលួ ឬទៅជាធ្ងន់នៅពេលដែលពួកគេធំឡើងគឺផ្អែកទៅលើលក្ខណៈជីវសាស្រ្ត។ ស្រដៀងគ្នានេះដែរ គំនិតដែលថា ស្រ្តីមានការខ្មាសអៀន និងខ្សោយជាងបុរសគឺជាការកំណត់របស់សង្គម ចំណែកឯសមត្ថភាពរបស់ពួកគេក្នុងការផ្តល់កំណើតដល់កូនគឺជាលក្ខណៈជីវសាស្រ្ត។ ការទទួលស្គាល់ថា យេនឌ័រគឺជាការកំណត់របស់សង្គម ហើយថាអាកប្បកិរិយាផ្អែកយេនឌ័រគឺជាការរៀនសូត្រជួយយើងឱ្យយល់ថាអាកប្បកិរិយាគឺអាចផ្លាស់ប្តូរបាន។ ឧទាហរណ៍ ការទទួលស្គាល់គំនិតដែលថាបុរសមិនយំគឺជាការរៀនសូត្រជាញឹកញាប់អាចជួយយើងឱ្យផ្លាស់ប្តូររបៀបដែលយើងបង្រៀន ឬបណ្តុះក្មេងប្រុសកុំឱ្យបង្ហាញពីអារម្មណ៍របស់ខ្លួនដោយគ្មានការភ័យខ្លាចចំពោះការវិនិច្ឆ័យថា «មិនមានលក្ខណៈគ្រប់គ្រាន់ជាមនុស្សប្រុស»។ ឧទាហរណ៍មួយទៀតគឺ យើងតែងតែឮថាស្រ្តីមិនអាចបើកបរបានល្អទេ។ ទោះជាយ៉ាងណាក៏ដោយ ការពិតគឺថា ស្រ្តីជាច្រើនបើកបរបានយ៉ាងល្អក្នុងការធ្វើចរាចរប្រចាំថ្ងៃតាមដងផ្លូវសាធារណៈ និងក្នុងការប្រណាំងយានយន្តផងដែរ។ នេះជាឧទាហរណ៍មួយស្តីពីរបៀបនៃការកំណត់របស់សង្គម និងតថភាពជាក់ស្តែងជារឿយៗមានភាពខុសគ្នាទាំងស្រុង។

**⊶ គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូ ៖

- វាអាចមានការពិបាកសម្រាប់សិស្សក្នុងការពន្យល់ឱ្យបានច្បាស់ពីបណ្តុំពាក្យរបស់ខ្លួន។ ដូច្នេះ ពួកគេអាចមានភាពស្ទាក់ស្ទើរនៅពេលធ្វើការជាក្រុម ឬនៅពេលឡើងនិយាយនៅក្នុងក្រុមធំ។ លោកគ្រូ អ្នកគ្រូត្រូវលើកទឹកចិត្ត និងប្រាប់ពួកគេថាមិនមានចម្លើយត្រឹមត្រូវ និង

ខុសទេសម្រាប់សកម្មភាពនេះទេ។

- សកម្មភាពនេះផ្តោតទៅលើការពន្យល់ពីភាពខុសគ្នារវាងភេទ និងយេនឌ័រ ព្រមទាំងរបៀបដែលសង្គមកំណត់ពីយេនឌ័រ។ ប្រសិនបើការពិភាក្សាមាននិន្នាការឆ្ពោះទៅរកការរើសអើងផ្នែកយេនឌ័រ លោកគ្រូ អ្នកគ្រូត្រូវបង្វែការផ្ចង់ផ្តោតមកលើយេនឌ័រ និងភេទវិញ។
- ផ្តល់ឧទាហរណ៍ឱ្យបានច្រើនដើម្បីជួយសិស្សឱ្យយល់ពីទស្សនៈទានផ្សេងៗ ដូចជាយេនឌ័រ តួនាទីយេនឌ័រ និងផ្នត់គំនិតផ្នែកយេនឌ័រ ដោយសារតែទស្សនៈទានទាំងនេះគឺជាគំនិតដែលមានលក្ខណៈស្មុគស្មាញ។
- ប្រសិនបើសិស្សចាត់ថ្នាក់តួនាទីយេនឌ័រណាមួយដែលសង្គមបានកំណត់ថាមានមូលដ្ឋានលើផ្នែក«ជីវសាស្ត្រ» សូមលោកគ្រូ អ្នកគ្រូពន្យល់ឱ្យបានល្អិតល្អន់ក្នុងពេលពិភាក្សាពីផលប៉ះពាល់អវិជ្ជមាន អ្វីខ្លះដែលផ្នត់គំនិតទាំងនេះអាចមាននៅក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្ស។ ឧទាហរណ៍ ការសន្មតតាមបែបយេនឌ័រដែលថា ស្ត្រីគឺស័ក្តិសមនឹងអាជីពជាអ្នកថែទាំ ដូចជាការបីបាច់ និងមើលថែកូនដោយសារតែពួកគាត់មានលក្ខណៈបែបនោះពី«ធម្មជាតិ»។ ចំណុចនេះមិនត្រឹមតែមានផលវិបាកអវិជ្ជមានមួយចំពោះស្ត្រីជាច្រើននាក់ទេ តែថែមទាំងមានផលប៉ះពាល់ចំពោះបុរសជាច្រើនដែលអាចស័ក្តិសមនឹងអាជីពជាអ្នកថែទាំនេះ ក៏ប៉ុន្តែមិនអាចស្វែងរកការងារប្រភេទនេះធ្វើបានដោយសារតែឥទ្ធិពល និងសម្ពាធពីសង្គម។

**សារសំខាន់ៗ ៖**

- ភេទសំដៅទៅលើភាពខុសគ្នាផ្នែកជីវសាស្ត្ររវាងភេទប្រុស និងភេទស្រី ដោយផ្អែកលើប្រដាប់បន្តពូជ និងហ៊ែរ្សន។ យេនឌ័រពិពណ៌នាពីលក្ខណៈ និងតួនាទីជាទូទៅដែលផ្អែកលើផ្នត់គំនិតដែលសង្គមចាត់ទុកថាសមស្របសម្រាប់បុរស និងស្ត្រី។
- ទោះជាយ៉ាងណាក៏ដោយ យេនឌ័រមិនមែនមានចំនួនតែ២ទេ ពោលគឺមានយេនឌ័រច្រើនជាង ២ ហើយមានលទ្ធភាពមួយដែលថា បុគ្គលម្នាក់អាចមិនយល់ស្របតាមការកំណត់ភេទរបស់ខ្លួនថាជាបុរស ឬស្ត្រីទៅតាមលក្ខណៈជីវសាស្ត្រដែលពួកគេមានតាំងពីកំណើតទេ។
- ការទទួលស្គាល់ថា យេនឌ័រគឺសង្គមជាអ្នកកំណត់ ហើយថាអាកប្បកិរិយាផ្នែកយេនឌ័រគឺជាការរៀនសូត្រជួយយើងឱ្យយល់ថាគេអាចផ្លាស់ប្តូរអាកប្បកិរិយានោះបាន ហើយការរំពឹងទុក និងសម្ពាធរបស់សង្គមគឺអាចជម្នះបានដោយជោគជ័យ។

# មេរៀនទី៤ ៖ តើតួនាទីយេនឌ័រគឺជាអ្វី?[៨]

🕒 **រយៈពេល** ៖ ១ ម៉ោង

➲ **វត្ថុបំណង** ៖ ដើម្បីយល់ដឹងពីអ្វីដែលជាតួនាទីយេនឌ័រ និងរបៀបដែលតួនាទីយេនឌ័រទាំងនេះជះឥទ្ធិពលលើតថភាពជាក់ស្តែងដែលយើងកំពុងរស់នៅ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

☞ សម្រាប់គ្រូ៖ ក្តារខៀន និងហ្វឺត។

☞ សម្រាប់សិស្ស៖ សន្លឹកកិច្ចការផ្ទះរបស់សិស្សទំព័រទី៨២។

**ការរៀបចំទុកជាមុន** ៖

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ** ៖

**ផ្នែកទី ១[៩] ៖ លំហាត់ស្តីពីស្វ័យឆ្លុះបញ្ចាំង**

លោកគ្រូ អ្នកគ្រូត្រូវ ៖

☞ ឱ្យសិស្សធ្វើការជាគូ។ សិស្សម្នាក់ៗត្រូវបិទភ្នែក ហើយគិតពីអតីតកាលដ៏យូរអង្វែងដែលខ្លួនបានឆ្លងកាត់នៅក្នុងជីវិតរហូតដល់ពេលដំបូងដែលពួកគេដឹងថាខ្លួនឯងខុសពីសមាជិកផ្សេងដែលគេហៅថា «ភេទផ្ទុយគ្នា» ឬត្រូវគេរំពឹងទុកថាត្រូវមានអាកប្បកិរិយាខុសគ្នា និងត្រូវបានគេប្រព្រឹត្តដាក់ខុសគ្នាពីអ្នកដែលមានភេទផ្ទុយពីខ្លួន។ ឱ្យសិស្សគិតពីចំណុចនេះឱ្យបានស៊ីជម្រៅ ថាតើពួកគេមានអាយុប៉ុន្មាន នរណាខ្លះដែលពាក់ព័ន្ធ ហេតុការណ៍នេះបានកើតឡើងនៅឯណា ហេតុការណ៍

---

[៨] Nirantar,. (២០១៤), *យេនឌ័រ និងបិតាធិបតេយ្យ គោលការណ៍ណែនាំសម្រាប់គ្រូបង្វឹក* ចំណុចសង្គមស៊ីវិលដែលខ្សោយបំផុត (PACS)។

៩ផ្នែកសុខភាពបន្តពូជ និងការស្រាវជ្រាវ។ (២០០១)។ *ការផ្លាស់ប្តូរប្រព័ន្ធសុខាភិបាល៖ យេនឌ័រ និងសិទ្ធិនៃសុខភាពបន្តពូជ សៀវភៅមគ្គុទេសក៍បង្ហាត់បង្រៀនសម្រាប់សុខភាពអ្នកគ្រប់គ្រង*។ ប្រទេសហ្សឺណែវ៖ អង្គការសុខភាពពិភពលោក។

នោះគឺជាអ្វី? ពួកគេមានអារម្មណ៍យ៉ាងណាចំពោះរឿងនេះ និងរបៀបដែលចំណុចពិសេសផ្សេងៗនៃអត្តសញ្ញាណរបស់ខ្លួន(ពូជសាសន៍ សាសនា អត្តសញ្ញាណ សញ្ជាតិ ជាតិពន្ធ) បានរួមចំណែកក្នុងហេតុការណ៍នេះយ៉ាងដូចម្តេចខ្លះ ។ ល។

☞ បន្ទាប់មក លោកគ្រូ អ្នកគ្រូឱ្យសិស្សចែករំលែករឿងរ៉ាវរបស់ខ្លួនជាមួយដៃគូរបស់ខ្លួន។

**ផ្នែកទី ២ - លោកគ្រូ អ្នកគ្រូត្រូវ ៖**

☞ បែងចែកសិស្សជា២ក្រុម ដោយចាត់តាំងឱ្យក្រុមមួយធ្វើការលើប្រធានបទស្តីពី «ក្មេងប្រុស» ហើយក្រុមមួយទៀតត្រូវធ្វើការលើប្រធានបទស្តីពី«ក្មេងស្រី»។ ក្រុមនីមួយៗត្រូវធ្វើការសម្តែងតួមួយ។ សិស្សមានពេលចំនួន១០នាទីដើម្បីពិភាក្សា និងរៀបចំ និងមានពេល៥នាទីទៀតសម្រាប់សម្តែង។ ការសម្តែងតួត្រូវផ្តោតលើរបៀបដែលគេចិញ្ចឹមបីបាច់ក្មេងស្រី ឬក្មេងប្រុស (អាស្រ័យលើប្រធានបទរបស់ក្រុម)នៅក្នុងគ្រួសារ។ ចំណុចនេះអាចរួមបញ្ចូលទាំងរបៀបរបបស្លៀកពាក់ របបអាហារ ប្រដាប់ ក្មេងលេង ការដាក់កម្រិត គុណសម្បត្តិ និងកត្តាផ្សេងៗជាច្រើនទៀត។

☞ បន្ទាប់ពីសម្តែងចប់ សូមពិភាក្សាពីតួនាទីយេនឌ័រដែលមានមុនពេលបន្តការសម្តែង និងការពិភាក្សារបស់ក្រុមទី២។

***កិច្ចការផ្ទះ ៖***

☞ បន្ទាប់ពីបញ្ចប់សកម្មភាពខាងលើ លោកគ្រូ អ្នកគ្រូត្រូវបង្ហាញនូវកិច្ចការផ្ទះដែលពួកគេត្រូវធ្វើ។

☞ ឱ្យពួកគេបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៨២។

☞ អានសេចក្តីណែនាំនៅក្នុងសន្លឹកកិច្ចការ បន្ទាប់មកពន្យល់ពីអ្វីដែលពួកគេចាំបាច់ត្រូវធ្វើ។

☞ រំឭកពួកគេឱ្យដឹងពីសារៈសំខាន់នៃការយកសន្លឹកកិច្ចការរបស់ខ្លួនមកវិញនៅម៉ោងរៀនបន្ទាប់។

## ៣. ការពង្រឹងចំណេះដឹង

**🗣 ចំណុចសម្រាប់ការពិភាក្សា ៖**

◈ តើ "តួនាទីយេនឌ័រ" មានន័យដូចម្តេច?

☝ តួនាទីយេនឌ័រគឺជាការរំពឹងទុកដែលផ្អែកលើការប្រតិបត្តិតាមវប្បធម៌សង្គមដែលជាញឹកញាប់មានភាពមិនស្មើភាពគ្នា និងអយុត្តិធម៌។ គេបង្រៀនក្មេងប្រុស និងក្មេងស្រីជាប្រព័ន្ធឱ្យមានភាពខុសគ្នា។ ការបង្រៀនពីតួនាទីយេនឌ័រចាប់ផ្តើមតាំងតែពីដើមដំបូងនៃជីវិត។ ចំណុចនេះរួមបញ្ចូលទាំងការរៀនសូត្រដើម្បីឱ្យមានលក្ខណៈខុសគ្នាចំពោះ ៖

- **ការបែងចែកពលកម្ម** ៖ ប្រភេទនៃកិច្ចការផ្ទះដែលគេរំពឹងទុកថាក្មេងស្រីត្រូវធ្វើដោយប្រៀបធៀប

ទៅនឹងក្មេងប្រុស។ ក្មេងស្រីត្រូវធ្វើការនៅក្នុងផ្ទះ ហើយក្មេងប្រុសត្រូវធ្វើនៅក្រៅផ្ទះ។ ក្មេងស្រីធ្វើការងារឱ្យអ្នកផ្សេងទៀតនៅក្នុងផ្ទះ ដូចជាការចម្អិនអាហារ លាងចាន សម្អាតផ្ទះ និងបោកគក់ជាដើម។ ក្មេងប្រុសត្រូវគេបញ្ជូនឱ្យទៅធ្វើការងារនៅខាងក្រៅ។ ក្មេងស្រីធ្វើកិច្ចការ ផ្សេងៗសម្រាប់ក្មេងប្រុស ដូចជាការរៀបចំម្ហូបអាហារ លាងសម្អាតបន្ទាប់ពីបរិភោគរួច និងការបោកសម្លៀកបំពាក់ឱ្យក្មេងប្រុស។

- **ការដើរហើរ** ៖ ក្មេងស្រីប្រឈមមុខនឹងការរឹតបន្តឹងជាច្រើនដែលធ្វើឱ្យពួកគេមិនអាចចេញក្រៅបាន ហើយចំណុចនេះក្លាយទៅជាករណីពិសេសនៅពេលពួកគេកាន់តែមានវ័យច្រើនឡើង ។ នៅក្នុងវប្បធម៌មួយចំនួន ក្មេងស្រីមិនមានសេរីភាពក្នុងការដើរហើរទេ ហើយពួកគេអាចទៅណាមកណាបានលុះត្រាតែមានមនុស្សប្រុសម្នាក់ ដូចជាបងប្អូនប្រុស ឬសមាជិកប្រុសក្នុងគ្រួសារអមដំណើរពួកគេ។ ក្មេងស្រីខ្លះទៀតត្រូវគេបង្ខំឱ្យបោះបង់ចោលការសិក្សាទៀតផង។

- **របៀបរបបនៃការស្លៀកពាក់** ៖ គ្រប់វប្បធម៌ទាំងអស់ គេរំពឹងទុកថាក្មេងស្រី និងក្មេងប្រុសត្រូវស្លៀកពាក់ខុសគ្នា ជាពិសេសគឺម៉ូតសម្លៀកបំពាក់ និងពណ៌តាំងតែពីពេលពួកគេកើតមកម្ល៉េះ។ ភាពខុសគ្នាទាំងនេះមានលក្ខណៈខុសគ្នាទៅតាមវប្បធម៌ និងសង្គម។ នរណាម្នាក់ដែលបំពានរបៀបរបបនៃការស្លៀកពាក់នេះត្រូវគេសង្ស័យ ឬមើលឃើញថាជាមនុស្សចម្លែក។

- **ការហាមប៉ះពាល់រាងកាយគ្នារវាងក្មេងប្រុស និងក្មេងស្រី** ៖ នៅក្នុងវប្បធម៌ជាច្រើន ជាពិសេសនៅទ្វីបអាស៊ី ការហាមប៉ះពាល់រាងកាយគ្នាចាប់ផ្តើមតាំងពីវ័យក្មេងម្ល៉េះ។ បទពិសោធន៍រួមជាទូទៅមានការហាមឃាត់មិនឱ្យលេងជាមួយអ្នកដែលមានភេទផ្ទុយគ្នា ឬមិនឱ្យចូលរួមសកម្មភាពណាមួយដែលធ្វើឱ្យក្មេងម្នាក់មានការប៉ះពាល់រាងកាយគ្នាជាមួយមនុស្សដែល មានភេទផ្ទុយគ្នា។ ជាញឹកញាប់ ក្មេងស្រីគឺជាចំណុចផ្តោតចំពោះប្រភេទនៃការព្រមាន ឬការរឹតត្បិតរបៀបនេះ ហើយគេធ្វើឱ្យក្មេងស្រីមានអារម្មណ៍ក្នុងការទទួលខុសត្រូវចំពោះការគាំទ្រការហាមឃាត់នេះ។

- **ប្រភេទល្បែងដែលក្មេងស្រី និងក្មេងប្រុសលេង** ៖ ក្មេងស្រីមិនទទួលបានការលើកទឹកចិត្តឱ្យលេងល្បែងដូចជាបាល់ទាត់ដែលមានសកម្មភាពផ្នែករាងកាយខ្លាំង និងមានការប៉ះពាល់រាងកាយគ្នាទៅវិញទៅមកទេ។ ជារឿយៗ គេមិនឱ្យក្មេងប្រុសលេងតុក្កតាកូនក្រមុំ ឬដើរតួជាមេផ្ទះ

ឡើយ។ ក្មេងប្រុសដែលមិនចូលរួមលេងកីឡាពិបាកៗ និងការហាក់លោតនឹងត្រូវគេសើចចំអក។

- **ការឆ្លើយតបផ្នែកអារម្មណ៍** ៖ គេរំពឹងទុកថាក្មេងស្រី និងក្មេងប្រុសឆ្លើយតបក្នុងលក្ខណៈខុសគ្នាចំពោះកត្តាជុំវិញដូចគ្នា។ ខណៈដែលក្មេងស្រីយំគឺអាចទទួលយកបាន ការយំរបស់ក្មេងប្រុសគឺជាការទទួលបានសារថាពួកគេទន់ខ្សោយ ហើយត្រូវមាន«ភាពក្លាហាន និងរឹងមាំ»។ ការណ៍នេះមានឥទ្ធិពលលើគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត តួនាទី និងការទទួលខុសត្រូវ។ ក្មេងប្រុសត្រូវតែជាអ្នកថែរក្សា និងទទួលខុសត្រូវលើតម្រូវការផ្នែកសម្ភារៈក្នុងគ្រួសាររបស់ពួកគេ និងត្រូវតែជាអ្នកផ្គត់ផ្គង់ ចំណែកឯក្មេងស្រីត្រូវមើលថែទាំក្មេងប្រុសដោយមិនគិតពីខ្លួនឯង ព្រោះថាឪពុក បងប្អូនប្រុស ឬស្វាមីរបស់ពួកគេនឹងមើលថែរក្សា ព្រមទាំងផ្តល់អ្វីគ្រប់យ៉ាងឱ្យពួកគេហើយ។ តួនាទីយេនឌ័រដែលមានភាពរឹតត្បិតទាំងនេះធ្វើឱ្យភាពអយុត្តិធម៌នៃប្រព័ន្ធនេះបន្តមានជារៀងរហូត។ ក្មេងប្រុស និងបុរសជារឿយៗពុំមានឱកាសចែករំលែកនូវអារម្មណ៍របស់ខ្លួនជាមួយមិត្តភក្តិ ឬជ្រើសរើសយកការងារដែលមានប្រាក់ចំណូលតិចដែលអាចជាចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះពួកគេទេ។ ជារឿយៗ ក្មេងស្រីពុំមានលទ្ធភាពធ្វើតាមការចាប់អារម្មណ៍របស់ខ្លួនក្រៅពីកិច្ចការងារក្នុងផ្ទះទេ។ សូម្បីតែពេលដែលក្មេងស្រីទៅធ្វើការងារនៅខាងក្រៅផ្ទះក៏ដោយ ក៏វាអាចមានរយៈពេលខ្លីដែរ ហើយគេក៏មិនយល់ស្របដែរ ប្រសិនបើវាមានផលប៉ះពាល់ទៅលើការទទួលខុសត្រូវនៅក្នុងផ្ទះដែលគេមើលឃើញថាទទួលរងផលប៉ះពាល់ដោយសារតែអវត្តមានរបស់នាង។

- **អាកប្បកិរិយា និងឥរិយាបថ** ៖ មានការរំពឹងទុកមួយថា ក្មេងស្រីមិនត្រូវនិយាយតមាត់ ឬបញ្ចេញមតិរបស់ខ្លួនឡើយ។ ជារឿយៗ គេតែងលើកពីចំណុចនេះនៅតាមសាលារៀន និងរបៀបដែលគ្រូបង្រៀនយកចិត្តទុកដាក់ចំពោះក្មេងប្រុសច្រើនជាងព្រោះពួកគាត់មានក្តីរំពឹងចំពោះក្មេងប្រុសច្រើនជាង។ គេរំពឹងទុកថា ក្មេងប្រុសធំធាត់ឡើងក្លាយជាមេគ្រួសារ ចំណែកឯក្មេងស្រីត្រូវបានគេចាត់ទុកថាជាទ្រព្យសម្បត្តិ និងកម្មសិទ្ធិរបស់អ្នកផ្សេងទៀត (នៅក្នុងបរិបទឥណ្ឌាហៅថា «paraya dhan») ដែលមានន័យថាក្មេងស្រីម្នាក់នឹងរៀបការ ហើយក្លាយជា «កម្មសិទ្ធិ» របស់ក្រុមគ្រួសារផ្សេងទៀត។ ក្មេងស្រីមិនត្រូវបង្ហាញចំណុចខ្លាំង ឬការជំទាស់ទេ។ ភាពអយុត្តិធម៌នៃការពេញចិត្តតែទៅលើកូនប្រុសក៏នៅតែកើតមាន និងបន្ទាបតម្លៃក្មេងស្រីយ៉ាងធ្ងន់ធ្ងរ តាំងពីមុនពេលពួកគេកើតមកទៅទៀត។

☝ ស្ថាប័នសង្គមជាច្រើនដូចជា ៖ គ្រួសារ សាលារៀន ស្ថាប័នវប្បធម៌ និងសាសនា កន្លែងធ្វើការ

និងសង្គមដែលតំណាងដោយមិត្តភក្តិ និងអ្នកជិតខាង ។ល។ គឺជាអ្នកបង្រៀន និងពង្រឹងតួនាទីយេនឌ័រ។ ទោះជាយ៉ាងណាក៏ដោយ តួនាទីយេនឌ័រគឺជាការរៀនសូត្រ ហេតុដូច្នេះហើយគេអាចមិនរៀន និងពិនិត្យមើលវាឡើងវិញបាន។ តួនាទីយេនឌ័រមានលក្ខណៈបើកចំហសម្រាប់ការជជែកវែកញែក ពិភាក្សា និងចរចា ហើយអាចផ្លាស់ប្តូរបានទៅតាមភាពរឹងមាំនៃអត្តសញ្ញាណផ្ទាល់ខ្លួនផង។

- តើភាពអយុត្តិធម៌ផ្នែកយេនឌ័រមានឥទ្ធិពលអ្វីខ្លះចំពោះបុរស និងស្ត្រី?

  - ជារឿយៗ គេរឹតត្បិតទៅលើជម្រើសមួយដោយសារតួនាទីយេនឌ័រ ហើយទាំងបុរស និងស្ត្រីត្រូវតែទ្រាំទទួលយកនូវជម្រើសនេះ។ ទោះជាបុរសទទួលរងសម្ពាធដោយសារជម្រើសនេះក្តី ពួកគេមានសេរីភាព និងបុព្វសិទ្ធិច្រើនជាងស្ត្រី ដែលចំណុចនេះគេហៅថា ការ**រើសអើងយេនឌ័រ**ដែលគេនឹងពិភាក្សាលម្អិតបន្ថែមទៀត។

  - ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងការសម្តែងតួ លោកគ្រូ អ្នកគ្រូត្រូវណែនាំពីទស្សនៈទាន**បិតាធិបតេយ្យ**នៅពេលធ្វើការពិភាក្សាពីការសម្តែងនោះ។ បិតាធិបតេយ្យគឺជាប្រព័ន្ធសង្គមមួយដែលគេផ្តល់អាទិភាពឱ្យបុរស។ ហេតុនេះហើយ បុរសមានលទ្ធភាពត្រួតត្រាដោយស្របច្បាប់លើចំណុចពិសេសជាច្រើននៃជីវិតរបស់ស្ត្រី ដូចជាការងារ ទ្រព្យសម្បត្តិ សេរីភាព និងការដើរហើរព្រមទាំងទំនាក់ទំនងផ្លូវភេទ និងការបន្តពូជ។ ទោះជាយ៉ាងណាក៏ដោយ ការពិភាក្សានៅដំណាក់កាលនេះត្រូវគូសបញ្ជាក់ពី «តួនាទីរបស់យេនឌ័រ» ដោយសារតែបិតាធិបតេយ្យនឹងត្រូវពិភាក្សាស៊ីជម្រៅនៅក្នុងលំហាត់ខាងក្រោម។

  - នៅពេលដែលមានបុគ្គលនានាជំទាស់ទៅនឹងវិសមភាពយេនឌ័រទាំងនេះ ពេលដែលយើងគិតពីប្រជាជនទូទៅ យើងមើលឃើញថាវិសមភាព និងការរើសអើងយេនឌ័រមានទំហំធំធេងណាស់។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូ ៖

- ដោយសារលំហាត់នេះពាក់ព័ន្ធនឹងការពន្យល់ពីទស្សនៈទានថ្មីៗ ពោលគឺតួនាទីយេនឌ័រ ការរើសអើងយេនឌ័រ និងបិតាធិបតេយ្យ វាមានសារៈសំខាន់ណាស់ក្នុងការពិនិត្យមើលម្តងទៀតជាមួយក្រុម ថាតើពួកគេយល់ពីវាក្យសព្ទ និងទស្សនៈទានទាំងនេះដែរឬទេ។

✉ **សារសំខាន់ៗ ៖**

- ដំណើរការផ្ទេរកេរ្តិ៍យេនឌ័របង្កើតឱ្យមានប្រព័ន្ធមួយនៃការផ្តល់សិទ្ធិ បុព្វសិទ្ធិ និងការរឹតត្បិតសម្រាប់បុរស និងស្ត្រី។
- ទោះបីជាបុរស និងស្ត្រីប្រឈមនឹងការរឹតត្បិតផ្សេងៗដោយសារតួនាទីយេនឌ័ររបស់ខ្លួនក៏ដោយ ក៏បុរសមានសិទ្ធិ និងបុព្វសិទ្ធិច្រើនជាងស្ត្រីដែរដែលប្រឈមមុខនឹងការរឹតត្បិតសំខាន់ៗ និងការដកហូតសិទ្ធិអំណាចច្រើនជាងបុរស។

# មេរៀនទី៥ ៖ តើអំណាចជាអ្វី?[៩]

🕒 **រយៈពេល** ៖ ៤៥ នាទី

➲ **វត្ថុបំណង** ៖ ដើម្បីយល់អំពីអត្ថន័យនៃអំណាច។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

- សម្រាប់គ្រូ៖ ក្រដាសផ្ទាំងធំ និងហ្វឺត ឬក្តារខៀន និងដីស។
- សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន** ៖

- អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកមេរៀនដែលពួកគេបានរៀនក្នុងជំពូកមុន។
- អានចំណងជើងមេរៀន ដោយចង្អុលទៅរកចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្ស ទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ហៅសិស្សស្ម័គ្រចិត្ត ២-៣ នាក់ ឱ្យចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុម។
- បន្ទាប់មកគូរតារាងមួយដែលមានកូឡោនចំនួន ២ នៅលើក្តារខៀន។ កូឡោនទី១ ត្រូវដាក់ឈ្មោះថា «អំណាច ឬបុព្វសិទ្ធិច្រើនជាង» ហើយកូឡោនទី២ «អំណាច ឬបុព្វសិទ្ធិតិចជាង»។ បន្ទាប់មកឱ្យសិស្សពិភាក្សាគ្នាពីទស្សនៈទាននៃអំណាច បុព្វសិទ្ធិ និងសមភាពនៅក្នុងជីវិតផ្ទាល់របស់ខ្លួន និងនៅក្នុងសង្គម។ ការពិភាក្សាត្រូវផ្អែកលើបញ្ជីដូចខាងក្រោម ៖

---

[៩] ក្រុមការងារផ្នែកកម្មវិធីផ្លូវភេទ និងមេរោគអេដស៍។ (២០០៩)។ *គ្រប់យ៉ាងតែមួយ*។ ក្រុមប្រឹក្សាចំនួនប្រជាជន។

**បញ្ជីនៃក្រុមមនុស្សដែលទំនងជាមានវិសមតាពអំណាចក្នុងសង្គម ៖**

- អ្នកមាន / អ្នកក្រ
- បុរស / ស្ត្រី
- គ្រូបង្រៀន / សិស្ស
- ម្តាយ / កូន
- ថៅកែ / អ្នកធ្វើការ(កម្មករ)
- អ្នកនយោបាយ (ឬ ប្រធានភូមិ) / សមាជិកសហគមន៍
- បុគ្គលមានវណ្ណៈខ្ពស់ / បុគ្គលមានវណ្ណៈទាប
- មនុស្សធម្មតា / ជនពិការ
- អ្នកដែលមានភាពទាក់ទាញ / អ្នកដែលមិនមានភាពទាក់ទាញ

☞ ឱ្យសិស្សពិភាក្សាជាក្រុមនូវពាក្យគូនីមួយៗនៅក្នុងតារាង ហើយបន្ទាប់មកពាក្យគូនេះត្រូវបែងចែកតាមប្រភេទនៃ«អំណាចច្រើនជាង» និង«អំណាចតិចជាង»។ លោកគ្រូ អ្នកគ្រូត្រូវរម្លឹកសិស្សថា ការចំណាត់ថ្នាក់ទាំងនេះមិនមានលក្ខណៈពិតប្រាកដដូចគ្នាទាំងអស់ ឬមានលក្ខណៈដាច់ខាតឡើយ។

☞ សរសេរចម្លើយទាំងអស់នៅក្នុងកូឡោនដែលបានគូររួចហើយ។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

◈ សូមពិនិត្យមើលបញ្ជីក្រុមមនុស្សដែលទំនងជាមានបុព្វសិទ្ធិច្រើននៅក្នុងសង្គម។ តើសិស្សអាចរកក្រុមមួយនៅក្នុងបញ្ជីនេះដែលពួកគេយល់ថាមានលក្ខណៈដូចខ្លួនដែរឬទេ? តើសិស្សយល់ស្របថាក្រុមនេះជាទូទៅទទួលបានអំណាចច្រើននៅក្នុងសង្គមដែរឬទេ? ហេតុអ្វី?

◈ សូមពិនិត្យមើលបញ្ជីក្រុមមនុស្សដែលជាទូទៅមានបុព្វសិទ្ធិតិច។ តើសិស្សអាចយល់ថាក្រុមណាមួយក្នុងចំណោមក្រុមទាំងនេះមានលក្ខណៈដូចខ្លួនដែរឬទេ? តើពួកគេយល់ស្របថាក្រុមដែលបានជ្រើសរើសនេះមានបុព្វសិទ្ធិតិចដែរឬទេ? ហេតុអ្វី?

◈ តើមានសិស្សណាយល់ថាខ្លួនមានលក្ខណៈដូចគ្នានឹងក្រុមយ៉ាងហោចណាស់ក៏មួយដែរនៅក្នុងចំណោមក្រុមដែលមានក្នុងបញ្ជីនីមួយៗដែរឬទេ? តើមនុស្សភាគច្រើនដឹងឬទេថាវាមានលក្ខណៈដូចម្តេចចំពោះការមានបុព្វសិទ្ធិច្រើន ក៏ដូចជាការមានបុព្វសិទ្ធិតិច?

◈ មនុស្សមួយចំនួនមានឋានៈ ឬអំណាចនៅក្នុងជីវិត ពោលគឺមានបុព្វសិទ្ធិច្រើន។ ការណ៍នេះធ្វើឱ្យ

ពួកគេអាចត្រួតត្រា មានផាសុកភាព និងភាពងាយស្រួល ទំនុកចិត្ត ក៏ដូចជាសុវត្ថិភាពដែរ។ ទោះជាយ៉ាងណាក៏ដោយ ការមានបុព្វសិទ្ធិតិចតួចតែងតែមានការប្រឈមមួយ ដោយបុគ្គលម្នាក់មានអារម្មណ៍មិនប្រាកដថា តើពួកគេត្រូវអ្នកដទៃទទួលយកដែរឬទេ។ មនុស្សបែបនេះអាចមានអារម្មណ៍ស្ទាក់ស្ទើរក្នុងការនិយាយ ឬមិនមានគេស្ដាប់ទេ ប្រសិនបើពួកគេសម្រេចចិត្តនិយាយ។ បុគ្គលដែលមានបុព្វសិទ្ធិ ឬអំណាចតិចអាចទទួលរងការបង្ខិតបង្ខំឱ្យគោរពតាមអ្វីដែលបុគ្គលដែលមានបុព្វសិទ្ធិ ឬអំណាចច្រើនចង់បាន ឬគិតថាត្រឹមត្រូវ។

- អំណាចកើតចេញពីប្រភពផ្សេងៗគ្នា ៖
  - នៅក្នុងទម្រង់នៃការប្រព្រឹត្តចំពោះគ្នាទៅវិញទៅមករវាងម្ដាយ និងកូន ចៅហ្វាយ និងបុគ្គលិក គ្រូបង្រៀន និង សិស្ស អ្នកដែលមានអំណាចច្រើនជាងនឹងកាន់កាប់អំណាចនោះដោយសារតែខ្លួនមានតួនាទីជាអាជ្ញាធរ។ តួនាទីនេះអាចកើតមានមកពីកត្តាផ្សេងៗដូចជា អាយុ ទំនាក់ទំនងផ្ទាល់ ឬការកំណត់ផ្នែកវិជ្ជាជីវៈ។
  - អំណាចក៏កើតមកពីតួនាទីផ្សេងៗដែរនៅពេលដែលមនុស្សមួយចំនួនមានអ្វីមួយ ដែលគេចាត់ទុកថាគួរឲ្យចង់បាន ហើយដែលអ្នកផ្សេងទៀតពុំមាន ដូចជាលុយកាក់ កិត្តិយស ទ្រព្យសម្បត្តិ ឬរបស់របរផ្សេងៗដែលថ្លៃ ឬមានគុណតម្លៃខ្ពស់។
  - កត្តាផ្សេងៗទៀត អាចមានឋានានុក្រមសង្គមដូចជា វណ្ណៈ ឬសហគមន៍ យេនឌ័រ អាយុ សមត្ថភាព ។ល។ ដែលអំណាចនេះមានចំពោះមនុស្សដែល «សង្គមចង់បាន ឬទទួលស្គាល់»។ ហេតុដូច្នេះហើយ អំណាចនេះគឺជាការកំណត់របស់សង្គម។
  - គេអាចប្រើប្រាស់អំណាចក្នុងផ្លូវវិជ្ជមាន ក៏ដូចជាអវិជ្ជមានបានដែរ។ អំណាចក៏មានសក្ដានុពលភាពដែលគេអាចប្រើក្នុងមធ្យោបាយមួយសម្រាប់ការកេងប្រវ័ញ្ច និងការរំលោភបំពានដែរ។ ឧទាហរណ៍ មនុស្សពេញវ័យដែលអាចជាឪពុកម្ដាយ ឬគ្រូបង្រៀនមានសមត្ថភាពផ្ដល់ចំណេះដឹងដល់ក្មេងៗ។ កត្តានេះធ្វើឱ្យមនុស្សពេញវ័យមានអំណាចលើក្មេង។ គេអាចប្រើអំណាចនេះដើម្បីចែករំលែក ឬមិនចែករំលែកចំណេះដឹង ឬគេអាចប្រើដើម្បីបំភ័យ ឬធ្វើបាបក្មេងៗបាន។
- តើលោកគ្រូ អ្នកគ្រូអាចរកឧទាហរណ៍មួយចំនួនស្តីពីការប្រើអំណាចក្នុងការកេងប្រវ័ញ្ចបានដែរឬទេ?

សិស្សត្រូវរកឧទាហរណ៍តាមរយៈការសង្កេត និងបទពិសោធន៍ផ្ទាល់របស់ខ្លួន។ លោកគ្រូ អ្នកគ្រូអាចប្រើប្រាស់ឧទាហរណ៍មួយចំនួនក្នុងចំណោមឧទាហរណ៍ខាងក្រោមមកប្រើប្រាស់ដើម្បីជំរុញ

ការពិភាក្សានេះ ៖

- ការមិនអាចប៉ះពាល់បានដោយសារការប្រកាន់វណ្ណៈ
- គ្រូបង្រៀនដាក់ទណ្ឌកម្មលើរាងកាយសិស្ស
- ទំនាក់ទំនងប្តី និងប្រពន្ធដែលមានជំនឿថា ប្តីមានសិទ្ធិ «អនុញ្ញាត» ឬ «បដិសេធ» ក្នុងការឱ្យប្រពន្ធទៅធ្វើការ។
- បណ្ណាការ
- ការរៀបការនៅវ័យក្មេង
- ការចង់បានកូនប្រុស

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ភ្ជាប់ចម្លើយភាគច្រើនទៅនឹងការតស៊ូអំណាចផ្អែកយេនឌ័រ។ លោកគ្រូ អ្នកគ្រូចាំបាច់ត្រូវទាញការពិភាក្សាទៅរកប្រធានបទយេនឌ័រវិញ ប្រសិនបើសិស្សបែកអារម្មណ៍ដោយសារគំនិត និងការសង្កេតផ្សេងៗ។ ប្រសិនបើសិស្សខ្លួនឯងពុំបានផ្តល់ឧទាហរណ៍ណាមួយដែលទាក់ទងនឹងយេនឌ័រទេ លោកគ្រូ អ្នកគ្រូត្រូវផ្តល់ឧទាហរណ៍នោះដល់ពួកគេ។

**សារសំខាន់ៗ ៖**

- មានទំនាក់ទំនងជាច្រើនដែលភាគីម្ខាងអាចមានអំណាចលប់លើភាគីម្ខាងទៀត ឧទាហរណ៍ គ្រូបង្រៀន និងសិស្ស ឬកុមារ និងឪពុកម្តាយ។
- អំណាចត្រូវកើតឡើង និងរងឥទ្ធិពលដោយសារកត្តាផ្សេងៗ ដូចជាអាយុ យេនឌ័រ វណ្ណៈ ការអប់រំ មុខរបរ ស្ថានភាពសេដ្ឋកិច្ច ស្ថានភាពអាពាហ៍ពិពាហ៍ ។ល។ និង ។ល។

# មេរៀនទី៦ ៖ អំណាច និងបិតាធិបតេយ្យ[១០]

🕒 **រយៈពេល** ៖ ១ ម៉ោង

➲ **វត្ថុបំណង** ៖ ដើម្បីយល់ដឹងពីទំនាក់ទំនងរវាងអំណាច និងបិតាធិបតេយ្យ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

☞ សម្រាប់គ្រូ៖ ព្រីនចេញឧបសម្ព័ន្ធទី១ សម្រាប់សិស្ស ក្រដាសផ្ទាំងធំ ប៊ិក និងហ្វឺត (ឯកសារចែកជូនមាននៅចុងបញ្ចប់នៃមេរៀនទី៦)។

☞ សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន** ៖

☞ ថតចម្លងឧបសម្ព័ន្ធទី១ សម្រាប់សិស្ស។

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

☞ ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។

☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកមេរៀនដែលពួកគេបានរៀនក្នុងជំពូកមុន។

☞ អានចំណងជើងមេរៀន ដោយចង្អុលទៅរកចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្ស ទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ហៅសិស្សស្ម័គ្រចិត្ត ២-៣ នាក់ ឱ្យចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុម។

☞ ចែកឯកសារឧបសម្ព័ន្ធទី១ ឱ្យសិស្សទាំងអស់។

---

[១០] ICRW (២០១៦) *កម្មវិធី ភែស ប្រនបាប្ឋ* សម្រាប់ក្មេងស្រីពេញវ័យ។ Gap Inc។

☞ ឱ្យសិស្សគិតពីមេរៀនមុនៗ។ លោកគ្រូ អ្នកគ្រូគួររម្លឹកឡើងវិញពីឧទាហរណ៍មួយចំនួនដែលទាក់ទងទៅនឹងការកេងប្រវ័ញ្ចអំណាចផ្អែកយេនឌ័រ។

☞ ឱ្យសិស្សធ្វើការឆ្លុះបញ្ចាំងបន្តិច ហើយបន្ទាប់មកបំពេញចម្លើយរបស់ខ្លួននៅក្នុងឯកសារឧបសម្ព័ន្ធដែលបានចែកជូនរៀងៗខ្លួន។ សិស្សមានពេល ១០ នាទីសម្រាប់សកម្មភាពនេះ។ ការធ្វើបែបនេះនឹងជំរុញឱ្យក្មេងស្រីគិតពីបរិយាកាស និងសហគមន៍របស់ខ្លួន និងធ្វើការឆ្លុះបញ្ចាំងទៅលើអ្នកដែលមានអំណាច ប្រសិនបើគំនិតនេះត្រូវគេអនុវត្តចំពោះបរិយាកាសរបស់ខ្លួន។ សិស្សត្រូវគូសសញ្ញាសម្គាល់ មួយដើម្បីសម្គាល់នៅពីក្រោមចំណាត់ថ្នាក់មួយក្នុងចំណោមចំណាត់ថ្នាក់ទាំង៣ នៅក្នុងកូឡោន «បុរស» «ស្ត្រី» ឬ «មិនដឹង»។

☞ ក្នុងពេលជាមួយគ្នានេះដែរ លោកគ្រូ អ្នកគ្រូត្រូវរៀបចំក្រដាសផ្ទាំងធំ និងគូរឧបសម្ព័ន្ធទី១ ដែលត្រូវប្រើសម្រាប់ធ្វើជាមូលដ្ឋានក្នុងការពិភាក្សាគ្នា។

☞ បន្ទាប់ពីសិស្សបានបំពេញកិច្ចការរបស់ខ្លួនហើយ ត្រូវឱ្យសិស្សចាប់ផ្តើមពិភាក្សាពីចម្លើយរបស់គេ។ លោកគ្រូ អ្នកគ្រូត្រូវអានប្រយោគ(គំនិត)នីមួយៗនៅក្នុងឯកសារចែកជូនម្តងមួយៗ ហើយសិស្សត្រូវចែករំលែកចម្លើយរបស់ខ្លួនចំពោះប្រយោគ(គំនិត)នីមួយៗ។ ប្រសិនបើចម្លើយមានលក្ខណៈដូចគ្នា លោកគ្រូ អ្នកគ្រូត្រូវកត់ចម្លើយនោះនៅលើក្រដាសផ្ទាំងធំ។ បើចម្លើយមិនដូចគ្នាទេ លោកគ្រូ អ្នកគ្រូត្រូវដឹកនាំសិស្សឱ្យពិភាក្សាគ្នារហូតទាល់តែ មានការសន្និដ្ឋាន(ឯកភាព)ជាឯកច្ឆន្ទមួយ។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

◇ តាមការយល់ឃើញរបស់ប្អូន តើគំនិតទាំងនេះបង្ហាញពីតថភាពជាក់ស្តែងនៃការរើសអើងដែរឬទេ?

◇ តើអាកប្បកិរិយា ឬការរើសអើងបែបនេះកើតឡើងញឹកញាប់ដែរឬទេ?

◇ ផ្អែកលើប្រយោគ(គំនិត)នៅក្នុងតារាង និងចំណុចនានាដែលបានមកពីការពិភាក្សា តើមានប្រធានបទអ្វីខ្លះកើតឡើង? តើមានប្រភេទនៃការរឹតត្បិត ឬការរំពឹងទុកអ្វីខ្លះសម្រាប់ក្មេងស្រី? (គ្រូអាចរៀបចំបញ្ជីមួយស្តីពីប្រភេទនៃការរឹតត្បិត ឬការរំពឹងទុកនេះនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ)។

◇ តើអំណាចមានទំនាក់ទំនងដូចម្តេចទៅនឹង**ការរើសអើងផ្អែកយេនឌ័រ**?

☞ ចំពោះប្រយោគ(គំនិត)ភាគច្រើន បុគ្គលម្នាក់អាចមើលឃើញថា បុរសមានអំណាចច្រើន ហើយស្ត្រីមានអំណាចតិច។ ដូច្នេះ ស្ត្រីស្ថិតក្នុងស្ថានភាពមួយដែលមិនទទួលផលប្រយោជន៍។

នេះគឺជារបៀបដែលបិតាធិបតេយ្យមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅទៅលើ ជីវិតប្រចាំថ្ងៃរបស់ស្ត្រី និងក្មេងស្រី។ អំណាចនៅតែបន្តកើតមានតាមរយៈបិតាធិបតេយ្យ ដោយសារតែបិតាធិប្បតេយ្យនេះពង្រឹងការរើសអើង និងភាពអយុត្តិធម៌ផ្នែកយេនឌ័រ។

- តើប្រភពផ្សេងៗគ្នានៃអំណាចមានអ្វីខ្លះ?
  - ការពិភាក្សាពីទំនាក់ទំនងរវាងយេនឌ័រ និងអំណាចគឺមិនមែនគ្រាន់តែជាការពិភាក្សាអំពីភាពខុសគ្នារវាងបុរស និងស្ត្រីដែលសង្គមបានកំណត់ប៉ុណ្ណោះទេ។ អំណាចដើរតួរនាទីមួយតាមរយៈមធ្យោបាយខុសៗគ្នាជាច្រើន និងមានប្រភពផ្សេងៗគ្នា។ ប្រភពទាំងនេះរួមមានការអប់រំ មុខរបរ ការប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដែលស្តែងឱ្យឃើញតាមរយៈទំនាក់ទំនង ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ វណ្ណៈ ឋានៈ លទ្ធភាពទទួលបានធនធាន កាលៈទេសៈផ្ទាល់ខ្លួន សមត្ថភាព ក៏ដូចជាយេនឌ័រដែរ។ ឧទាហរណ៍ ស្ត្រីអ្នកទីក្រុងដែលសម្បូរទ្រព្យធនម្នាក់ ទំនងជាមានអំណាចផ្នែកហិរញ្ញវត្ថុ និងលទ្ធភាពទទួលបានធនធានច្រើនជាងកសិករដែលជាបុរសនៅតាមជនបទដែលមកពីក្រុមដែលមានប្រាក់ចំណូលទាប។ ស្ត្រីដែលផ្តល់កំណើតបានកូនប្រុសអាចមានអំណាចច្រើនជាងចំពោះស្ថានភាពសង្គម និងការគាំទ្រពីគ្រួសារច្រើនជាងស្ត្រីដែលបានផ្តល់កំណើតបានកូនស្រី។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រៀបចំតារាងឧបសម្ព័ន្ធទី១ជាមុននៅលើក្រដាសផ្ទាំងធំសម្រាប់ប្រើប្រាស់។
- នេះគឺជាលំហាត់សម្រាប់ឆ្លុះបញ្ចាំងពីខ្លួនឯង ហើយលោកគ្រូ អ្នកគ្រូចាំបាច់ត្រូវប្រាប់សិស្សថា ពុំមានចម្លើយណាដែលត្រូវ ឬខុសទេ។
- សិស្សអាចឆ្លើយតបខុសៗគ្នាទៅតាមបទពិសោធន៍ និងការសង្កេតនៅក្នុងជីវិតរបស់គេ។ លោកគ្រូ អ្នកគ្រូត្រូវដឹកនាំការពិភាក្សាដើម្បីឆ្លុះបញ្ចាំងអំពីអ្វីដែលសិស្សអាចសង្កេតមើលឃើញជាទូទៅនៅក្នុងសង្គម។

**សារសំខាន់ៗ ៖**

- សមភាពអំណាចរវាងមនុស្សផ្អែកលើកត្តាជាច្រើន។
- បិតាធិបតេយ្យពង្រឹងការរើសអើង និងភាពអយុត្តិធម៌ផ្នែកយេនឌ័រ។

ឧបសម្ព័ន្ធទី១ - តើនរណាជាអ្នកមានអំណាច?

*សេចក្តីណែនាំ ៖ គូសសញ្ញាធិក (✓) ក្នុងប្រអប់មួយសម្រាប់ប្រយោគ(គំនិត)មួយ*

| ប្រយោគ | ប្រុស | ស្រ្តី | មិនដឹង |
|---|---|---|---|
| ខ្ញុំអាចចំណាយប្រាក់ដែលខ្ញុំរកបានតាមចិត្តខ្ញុំចង់។ | | | |
| ខ្ញុំអាចសម្រេចចិត្តបានថាពេលណាខ្ញុំត្រូវមានកូន និងចំនួនប៉ុន្មាន។ | | | |
| ខ្ញុំមានសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិ។ | | | |
| ខ្ញុំមិនមានកាតព្វកិច្ចធ្វើកិច្ចការផ្ទះទេ។ | | | |
| ខ្ញុំអាចទៅណាមកណាបានតាមចិត្ត ឬខ្ញុំអាចទៅកន្លែងណាក៏បានតាមចិត្តខ្ញុំ | | | |
| ខ្ញុំមានសិទ្ធិសម្រេចពីពេលវេលាដែលខ្ញុំចង់រៀបការ។ | | | |
| ខ្ញុំអាចគេងនៅផ្ទះរបស់មិត្តខ្ញុំបានប្រសិនបើខ្ញុំចង់។ | | | |
| ខ្ញុំអាចជ្រើសរើសទៅធ្វើការងារបានជាជាងការរៀបចំផ្ទះ។ | | | |

# មេរៀនទី៧ ៖ ភាពជាក្មេងស្រី[១១]

🕒 **រយៈពេល** ៖ ១ ម៉ោង

➲ **វត្ថុបំណង** ៖ ដើម្បីវិភាគពីទស្សនៈទានស្ដីពី«ក្មេងស្រីល្អ» និង«ក្មេងស្រីមិនល្អ» និងរបៀបដែលទស្សនៈទាននេះមានទំនាក់ទំនងទៅនឹងបុព្វសិទ្ធិ បិតាធិបតេយ្យ ព្រមទាំងការរើសអើង និងវិសមភាពយេនឌ័រ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

☞ សម្រាប់គ្រូ៖ ខ្សែបូពណ៌សទំហំធំសម្រាប់ឱ្យសិស្សម្នាក់ៗសរសេរ ហ្វឺត ឬដីស និងក្ដារខៀន។

☞ សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន** ៖

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

## ២. ដំណើរការបង្រៀន

📢 **សេចក្ដីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

☞ ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។

☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកមេរៀនដែលពួកគេបានរៀនក្នុងជំពូកមុន។

☞ អានចំណងជើងមេរៀន ដោយចង្អុលទៅរកចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្ស ទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ហៅសិស្សស្ម័គ្រចិត្ត ២-៣ នាក់ ឱ្យចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុម។

☞ ចាប់ផ្ដើមការពិភាក្សាដោយសរសេរពាក្យថា«ក្មេងស្រីល្អ»នៅលើក្ដារខៀន និងពិភាក្សាពីពាក្យនេះ។

☞ សិស្សម្នាក់ៗត្រូវរកគុណនាមមួយ ឬលក្ខណៈពិសេសដែលពិពណ៌នាពីគុណសម្បត្តិទូទៅដែលទាក់ទងនឹងភាពជា «ក្មេងស្រីល្អ»។ លោកគ្រូ អ្នកគ្រូត្រូវសរសេរគុណសម្បត្តិនីមួយៗដាច់ដោយ

---

[១១] Nirantar,. (២០១១), Khulti Partein, Yaunikta Aur Hum ទីក្រុងញូដេលី

ឡែកពីគ្នាលើខ្សែបូ (គុណសម្បត្តិមួយនៅលើខ្សែបូមួយ)។ ឧទាហរណ៍ និយាយទន់ភ្លន់ មិនខឹង មិនដើរលេងក្នុងភូមិ ត្រលប់មកផ្ទះវិញមុនពេលថ្ងៃលិច មិនសើចឮៗ មិននិយាយជាមួយមនុស្សចម្លែក មិនធ្វើជាមិត្តជាមួយក្មេងប្រុស ត្រូវធ្វើការងារផ្ទះ។ល។

- ☞ រើសអ្នកស្ម័គ្រចិត្តម្នាក់ឱ្យឈរនៅមុខក្រុម។ លោកគ្រូ អ្នកគ្រូត្រូវអានគុណសម្បត្តិនៅលើខ្សែបូម្តងមួយៗឱ្យសិស្សស្តាប់ ហើយសិស្សត្រូវកំណត់ផ្នែកណាមួយនៃរាងកាយដែលគេគិតថាគុណសម្បត្តិនេះអាចដាក់នៅត្រង់ផ្នែកនៃរាងកាយនោះ។ ឧទាហរណ៍ «និយាយទន់ភ្លន់» អាចដាក់នៅត្រង់មាត់ «មិនដើរលេង» អាចដាក់នៅត្រង់ជើង ។ល។ លោកគ្រូ អ្នកគ្រូត្រូវចងខ្សែបូនៅតាមផ្នែកនានានៃរាងកាយរបស់អ្នកស្ម័គ្រចិត្តដែលឆ្លើយតបទៅនឹងចម្លើយរបស់សិស្សផ្សេងៗទៀតដោយរឹតខ្សែនោះកុំឱ្យអ្នកស្ម័គ្រចិត្តធ្វើចលនាបាន។
- ☞ នៅពេលដែលលោកគ្រូ អ្នកគ្រូចងខ្សែបូ និងគំនិតទាំងអស់រួចហើយ នោះមានន័យថាអ្នកស្ម័គ្រចិត្តត្រូវបានគេរឹតត្បិតយ៉ាងមានប្រសិទ្ធភាពចំពោះការនិយាយស្តី និងការធ្វើចលនាដែលជាការបង្ហាញពីរបៀបដែលគុណសម្បត្តិនីមួយៗក្លាយជានិមិត្តរូបនៃ «ការរឹតត្បិត» លើក្មេងស្រី និងស្ត្រី។ សិស្សត្រូវរៀបរាប់អំពីអារម្មណ៍របស់ខ្លួនដោយផ្អែកលើលំហាត់នេះ ហើយលោកគ្រូ អ្នកគ្រូអាចសរសេរចម្លើយទាំងនេះនៅលើក្តារខៀនបាន។

- ☞ បន្ទាប់មក ឱ្យសិស្សគិត និងរម្លឹកឡើងវិញពីឧប្បត្តិហេតុដែលរូបគេ ឬក្មេងស្រីផ្សេងទៀតដែលគេស្គាល់បានជំទាស់ ឬតវ៉ានឹងការរឹតត្បិតណាមួយក្នុងចំណោមការរឹតត្បិតទាំងនេះ។ ហេតុនេះ ខ្សែបូដែលត្រូវគ្នានឹងការរឹតត្បិតនោះអាចស្រាយចេញពីអ្នកស្ម័គ្រចិត្តបាន។ ចំណុចនីមួយៗត្រូវតែមានការពិភាក្សានៅក្នុងក្រុម។ ឧទាហរណ៍ ប្រសិនបើសិស្សម្នាក់ចែករំលែកថា នាងខឹងនឹងប្អូនៗ ឬម្តាយ ឬមិត្តភក្តិរបស់នាង ។ល។ លោកគ្រូ អ្នកគ្រូអាចស្រាយខ្សែបូដែលទាក់ទងនឹងគុណសម្បត្តិនោះចេញបាន។ លោកគ្រូ អ្នកគ្រូត្រូវសួរសំណួរបញ្ជាក់បន្ថែមឱ្យកាន់តែស៊ីជម្រៅសម្រាប់ឧទាហរណ៍នីមួយៗដើម្បីធ្វើបរិបទនីកម្មចំពោះចំណុចដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ឧទាហរណ៍ តើមានរឿងអ្វីកើតឡើងប្រសិនបើពួកគេទប់កំហឹងមិនបាន? តើមានអ្វីកើតឡើងបន្ទាប់ពីពួកគេបញ្ចេញកំហឹងហើយ? ។ល។ ការសួរបញ្ជាក់បន្ថែមនេះនឹងធ្វើឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅទៅលើដែនកំណត់ និងការរំពឹងទុកសម្រាប់ច្បាប់ទាំងនេះ។
- ☞ អ្នកស្ម័គ្រចិត្តគួរមានអារម្មណ៍ធម្មតានៅចុងបញ្ចប់នៃលំហាត់នេះ ដោយសារខ្សែបូភាគច្រើន ទោះបីមិនទាំងអស់ក៏ដោយ ត្រូវបានគេស្រាយចេញ។ លោកគ្រូ អ្នកគ្រូត្រូវឱ្យអ្នកស្ម័គ្រចិត្តនិយាយរៀបរាប់អំពីអារម្មណ៍របស់ខ្លួន ហើយលោកគ្រូ អ្នកគ្រូត្រូវកត់ត្រាចម្លើយរបស់គាត់ទុកដែរ។

## ៣. ការពង្រឹងចំណេះដឹង

🗣 **ចំណុចសម្រាប់ការពិភាក្សា ៖**

◇ ហេតុអ្វីបានជាគុណសម្បត្តិរបស់ «ក្មេងស្រីល្អ» ទាំងនេះនាំឱ្យមានការរើសអើងយេនឌ័រ?

☞ ដោយសារតែគេអនុវត្តគុណសម្បត្តិទាំងនេះចំពោះក្មេងស្រីគ្រប់រូប ទើបគុណសម្បត្តិទាំងនេះក្លាយជា«ច្បាប់» ឬបទដ្ឋានដែលមានលក្ខណៈពិសេសសម្រាប់យេនឌ័រ។ ច្បាប់ទាំងនេះត្រូវបានក្មេងស្រីចាត់ទុកថាជាផ្នែកមួយដែលមានលក្ខណៈស៊ីជម្រៅនៃការប្រតិបត្តិរបស់ខ្លួន។ វត្ថុបំណងនៃច្បាប់ទាំងនេះគឺដើម្បីរឹតត្បិតការដើរហើរ ការអប់រំ សមិទ្ធិផល អាកប្បកិរិយា បំណងប្រាថ្នា និងទំនាក់ទំនងផ្លូវភេទរបស់គេ។ រាប់ចាប់តាំងពីតើនរណាដែលក្មេងស្រីអាច ឬត្រូវនិយាយជាមួយ តើនាងជាក្មេងស្រីត្រូវមានអាកប្បកិរិយារបៀបណា តើពេលណាជាពេលវេលាសមស្របក្នុងមួយថ្ងៃៗដែលក្មេងស្រីចេញទៅក្រៅ និងត្រលប់មកផ្ទះវិញ តើក្មេងស្រីត្រូវស្លៀកពាក់ដូចម្តេច តើក្មេងស្រីត្រូវដើររបៀបណា ។ល។ គឺជាការកំណត់ថាតើគេអាចហៅក្មេងស្រីម្នាក់ថាជាក្មេង «ស្រីល្អ» បានដែរ ឬទេ។ ការកំណត់នេះគឺជាការធ្វើឱ្យមនុស្សម្នាក់មានអារម្មណ៍ថាត្រូវគេទទួលយក ប្រសិនបើពួកគេធ្វើតាមច្បាប់ទាំងនេះ ឬត្រូវគេបដិសេធប្រសិនបើគេមិនធ្វើតាម។ ប្រសិនបើមាននរណាម្នាក់ប្រឆាំងនឹងច្បាប់ទាំងនេះ នាងនឹងប្រឈមនឹងការដាក់ងារថាជា«ក្មេងស្រីមិនល្អ»។ ការគំរាមកំហែងចំពោះការដែលគេគិតថាជា «ក្មេងស្រីមិនល្អ» គឺការមិនទទួលបានការគាំទ្រពីគ្រួសារ ឬសហគមន៍ ពីអ្នកជិតខាង និងសង្គម។ នេះគឺជារបៀបដែលគេពង្រឹងការរើសអើងផ្នែកយេនឌ័រ។

◇ តើគេកំណត់ក្មេងស្រីម្នាក់ថាជា «ក្មេងស្រីល្អ» បានយ៉ាងដូចម្តេច? និងហេតុអ្វី? តើការទាមទារសិទ្ធិរបស់ខ្លួនគឺជារឿង «មិនល្អ» មែនឬទេ?

☞ ផលវិបាកផ្សេងៗនៃការក្លាយជា «ក្មេងស្រីមិនល្អ» ហាក់ដូចជាធ្ងន់ធ្ងរខ្លាំងណាស់ដែលធ្វើឱ្យមនុស្សភាគច្រើនព្យាយាមចៀសវាងពីបញ្ហានេះ ដូច្នេះហើយទើបធ្វើឱ្យបិតាធិបតេយ្យនៅតែបន្តកើតមាន។ ការដែលត្រូវបានគេហៅថា«ក្មេងស្រីមិនល្អ» ក៏ហាក់ដូចជាធ្វើឱ្យប៉ះពាល់ដល់ឋានៈគ្រួសារនៅក្នុងសង្គមផងដែរ។ សង្គមបានសម្រេចថា «កិត្តិយស» របស់គ្រួសារមួយគឺពឹងផ្អែកទៅលើថាតើកូនស្រីក្នុងគ្រួសារនោះប្រតិបត្តិត្រឹមត្រូវតាមក្បួនច្បាប់ល្អដែលមានលក្ខណៈរឹតត្បិតនេះដែរឬទេ។ នេះគឺជាភាពអយុត្តិធម៌មួយដោយសារតែច្បាប់ដូចគ្នានេះមិនបានអនុវត្តចំពោះក្មេងប្រុសទេ។ មានពេលវេលាមួយដែលស្ត្រីទៅធ្វើការនៅខាងក្រៅផ្ទះត្រូវបានគេហៅថា «មិនល្អ» ហើយស្ត្រីដែលបានជ្រើសរើសជាអ្នកសម្តែង ភាពយន្តក៏ត្រូវបានគេហៅថា«មិនល្អ» ដែរដែលចំណុចនេះមិនមែនជាបញ្ហាទៀតទេនៅតាមទីកន្លែងជាច្រើនលើសកលលោក។ ការផ្លាស់ប្តូរទាំងនេះ

ត្រូវការពេលវេលា និងភាពក្លាហាន ព្រមទាំងការចោទសួរពីតួនាទី និងច្បាប់ទាំងនេះ មិនត្រឹមតែពីសំណាក់ស្ត្រី និងក្មេងស្រីជាច្រើនប៉ុណ្ណោះទេ តែថែមទាំងពីសំណាក់បុរស និងក្មេងប្រុសមួយចំនួនទៀតដែលជឿថា ការរើសអើង និងភាពអយុត្តិធម៌ផ្អែកយេនឌ័រគឺជារឿងមិនត្រឹមត្រូវ។ សិទ្ធិរបស់ស្ត្រីនិងក្មេងស្រីគឺជាសិទ្ធិមនុស្ស និងត្រូវតែទទួលបានការការពារ។

- ហេតុដូច្នេះហើយការយល់ដឹង និងការទទួលស្គាល់ពីរបៀបដែលសង្គមបិតាធិបតេយ្យដំណើរការគឺជាជំហានដំបូងឆ្ពោះទៅរកការផ្លាស់ប្តូរ។

**គន្លឹះសម្រាប់គ្រូបង្រៀន ៖**

- លំហាត់នេះអាចធ្វើឱ្យអ្នកចូលរួមឈឺចាប់ និងមិនសប្បាយចិត្ត។ លោកគ្រូ អ្នកគ្រូត្រូវតែដឹងឱ្យបានច្បាស់ពីបញ្ហានេះក្នុងពេលអនុវត្តសកម្មភាព និងដឹកនាំការធ្វើលំហាត់នេះ ព្រមទាំងត្រូវចែករំលែកនូវចំណុចរសើប និងការយល់ពីអារម្មណ៍នេះឱ្យបានច្រើន។ លោកគ្រូ អ្នកគ្រូត្រូវរក្សាឱ្យបាននូវការផ្តោត និងល្បឿននៃសកម្មភាពនេះ។ បទពិសោធន៍ផ្ទាល់ខ្លួនណាមួយដែលមិនអាចដោះស្រាយបាននៅក្នុងការបណ្តុះបណ្តាលជាក្រុមនេះចាំបាច់ត្រូវតែយកចិត្តទុកដាក់ដោយការគោរព ប៉ុន្តែដកចេញពីការពិភាក្សា។ ចំណុចនេះតម្រូវឱ្យលោកគ្រូ អ្នកគ្រូបង្ហាញទាំងសេចក្តីមេត្តា និងជំនាញក្នុងការគ្រប់គ្រងការបណ្តុះបណ្តាលជាក្រុមដែលមានលក្ខណៈដូចនេះ។
- គោលដៅរបស់លំហាត់នេះគឺដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែស៊ីជម្រៅពីយេនឌ័រ តួនាទីយេនឌ័រ និងបិតាធិបតេយ្យ។ លំហាត់នេះគឺជាលំហាត់តពីលំហាត់មុនៗដើម្បីធានាបានថាសិស្សមានលទ្ធភាពបន្តមានគំនិតទាំងនេះ និងទទួលយកវាបានយ៉ាងមានប្រសិទ្ធភាព។
- នៅពេលដែលការពិភាក្សាឈានដល់ទស្សនៈទានស្តីពីសិទ្ធិ សិទ្ធិមនុស្ស និងសិទ្ធិស្ត្រី ឬសិទ្ធិកុមារ ការពិភាក្សានោះតម្រូវឱ្យមានការផ្តោតការយកចិត្តទុកដាក់ជាក់លាក់។ ដោយមិនចាំបាច់ពិភាក្សាលម្អិត វាមានសារៈសំខាន់ណាស់ដែលលោកគ្រូ អ្នកគ្រូពន្យល់ពីទស្សនៈទានរបស់សិទ្ធិមួយចំនួនដែលអាចអនុវត្តបានចំពោះមនុស្សគ្រប់រូប ហើយថាទស្សនៈទាននេះនឹងត្រូវសិក្សាស្វែងយល់ស៊ីជម្រៅនៅក្នុងម៉ូឌុលក្រោយ។

**សារសំខាន់ៗ ៖**

- គំនិតនានាដែលទាក់ទងនឹង «ក្មេងស្រីល្អ និង មិនល្អ» គឺជាការកំណត់របស់សង្គមដើម្បីរក្សា និងពង្រឹងបិតាធិបតេយ្យ និងការរើសអើងយេនឌ័រ។ ការកំណត់នេះរឹតត្បិតជីវិត និងជម្រើសរបស់ក្មេងស្រី និងស្ត្រី។

# មេរៀនទី៨ ៖ ការចរចាពីតួនាទីយេនឌ័រ

🕒 **រយៈពេល** ៖ ៤៥ នាទី

➲ **វត្ថុបំណង** ៖ ដើម្បីសិក្សាស្វែងយល់ពីលទ្ធភាពនៃការចរចាចំពោះតួនាទី និងការរំពឹងទុកផ្នែកយេនឌ័រ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

☞ សម្រាប់គ្រូ៖ ប័ណ្ណករណីសិក្សា (ឧបសម្ព័ន្ធទី២ មានចែកនៅចុងបញ្ចប់នៃមេរៀននេះ) ។

☞ សម្រាប់សិស្ស៖ សន្លឹកកិច្ចការផ្ទះរបស់សិស្សទំព័រទី៨៣។

**ការរៀបចំទុកជាមុន** ៖

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ ថតចម្លងករណីសិក្សានៅក្នុងឧបសម្ព័ន្ធទី២។

☞ អានន្ទូវក្របខណ្ឌចំណេះដឹងពីទំព័រ៤២-៤៩។

☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

☞ ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។

☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកមេរៀនដែលពួកគេបានរៀនក្នុងជំពូកមុន។

☞ អានចំណងជើងមេរៀន ដោយចង្អុលទៅរកចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្ស ទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ហៅសិស្សស្ម័គ្រចិត្ត ២-៣ នាក់ ឱ្យចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុម។

☞ បែងចែកសិស្សជា២ក្រុម។

☞ ក្រុមនីមួយៗ ត្រូវបង្ហាញការសម្តែងតួខ្លីមួយដោយផ្អែកលើករណីសិក្សាដែលគ្រូបានផ្តល់ឱ្យពួកគេ។ សិស្សមានពេល ១០ នាទីដើម្បីពិភាក្សាករណីសិក្សានោះ និងមានពេល៣នាទីដើម្បីសម្តែង។ ក្រុម

ទាំង២ត្រូវធ្វើការដោយឯករាជ្យ ហើយពុំមានក្រុមណាមួយដឹងថា ក្រុមផ្សេងទៀតកំពុងពិភាក្សា ឬរៀបចំផែនការអ្វីឡើយ។ សមាជិកទាំងអស់របស់ក្រុមនីមួយៗមិនចាំបាច់ចូលរួមក្នុងការសម្តែងទាំងអស់គ្នានោះទេ ប៉ុន្តែគ្រប់គ្នាត្រូវតែចូលរួមពិភាក្សា និងសរសេរសាច់រឿងសម្រាប់ការសម្តែង។

☞ បន្ទាប់ពីការសម្តែង សិស្សត្រូវចែករំលែក និងពិភាក្សាពីគំនិត អារម្មណ៍ និងការសង្កេតរបស់គេ។

*កិច្ចការផ្ទះ ៖*

☞ ពេលចប់សកម្មភាពនេះហើយ លោកគ្រូ អ្នកគ្រូត្រូវបង្ហាញសិស្សនូវកិច្ចការដែលត្រូវធ្វើនៅផ្ទះ។

☞ ឱ្យពួកគេបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៨៣។

☞ អានសេចក្តីណែនាំនៅក្នុងសន្លឹកកិច្ចការ បន្ទាប់មកពន្យល់ពីអ្វីដែលពួកគេចាំបាច់ត្រូវធ្វើ។

☞ រំឭកពួកគេឱ្យដឹងពីសារៈសំខាន់នៃការយកសន្លឹកកិច្ចការរបស់ខ្លួនមកវិញនៅម៉ោងរៀនបន្ទាប់។

## ៣. ដំណើរការបង្រៀន

**ចំណុចសម្រាប់ការពិភាក្សា ៖**

◇ កំណត់ពីតួនាទី និងបទដ្ឋានយេនឌ័រដែល «សោភា» និង «សុផា» កំពុងប្រឈម។

☞ ក្មេងស្រីកំពុងចរចាគ្នា ៖

- ការអប់រំ (សិទ្ធិរបស់គេក្នុងការជ្រើសរើសការសិក្សានៅថ្នាក់ឧត្តមសិក្សា ការអះអាងពីជម្រើសរបស់គេ ។ ល។)
- មុខរបរ (ជាទូទៅគេចាត់ទុកថាមុខរបរផ្នែកវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ ជាមុខរបរសម្រាប់បុរស ហើយគេឱ្យស្ត្រីជ្រើសរើសមុខរបរផ្នែកសិល្បៈ ឬពាណិជ្ជកម្ម)។
- ការដើរហើរ (ក្មេងស្រីដែលធ្វើដំណើរ និងរស់នៅឆ្ងាយពីផ្ទះគឺត្រូវបានហាមឃាត់ពីក្រុមគ្រួសារជាច្រើន ហើយបញ្ហា និងកង្វល់ផ្សេងៗត្រូវបានគេភ្ជាប់ជាមួយបញ្ហានេះ)។

◇ តើមានអ្វីកើតឡើងនៅពេលក្មេងស្រីព្យាយាមជម្នះ ឬចរចាពីតួនាទី និងការរំពឹងទុកផ្នែកយេនឌ័រ?

☝ បិតាធិបតេយ្យធ្វើឱ្យមានការលំបាកសម្រាប់បុរស និងស្ត្រីក្នុងអនុវត្តអ្វីមួយឱ្យលើសពីតួនាទីយេនឌ័រដែលគេបានកំណត់។ ប្រសិនបើក្មេងប្រុស និងបុរសមិនអនុវត្តតាមតួនាទីយេនឌ័រ គេនឹងចាត់ទុកក្មេងប្រុស និងបុរសនោះថា «ទន់ខ្សោយ» និងមិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។ ការអនុវត្តលើសពីតួនាទីយេនឌ័រសម្រាប់បុរសបង្កឱ្យមានហានិភ័យចំពោះភាពអាម៉ាស់មុខ។ ស្ត្រី ឬក្មេងស្រីដែលប្រឆាំងនឹងបទដ្ឋានផ្សេងៗផ្នែកយេនឌ័រពាក់ព័ន្ធនឹងការដើរហើរ ការស្លៀក

ពាក់ ឬការរៀបអាពាហ៍ពិពាហ៍មានហានិភ័យចំពោះការមិនចូលក្នុងសង្គម ការបាត់បង់ការគាំទ្រពីក្រុមគ្រួសារ និងត្រូវបានគេយល់ថា«មិនល្អ» «គ្មានចរិយាមារយាទ» ព្រមទាំងទទួលបាននូវមតិរិះគន់ និងឥរិយាបថអវិជ្ជមានផ្សេងៗទៀត។ ឥរិយាបថ បែបនេះគំរាមកំហែងដល់នាង និងគ្រួសាររបស់នាងដោយបង្កឱ្យមានផលវិបាកអវិជ្ជមានយូរអង្វែង ឬអ្វីៗផ្សេងទៀតដែលគេអាចយល់ឃើញថាជាផលវិបាកអវិជ្ជមាន ដូចជាកាត់បន្ថយឱកាសរៀបការជាដើម។

- ☝ បិតាធិបតេយ្យគឺជាប្រព័ន្ធមួយរបស់សង្គមដែលគេផ្តល់គុណតម្លៃ បុព្វសិទ្ធិ និងឋានៈឱ្យបុរសខ្ពស់ជាងស្ត្រី។ គេយល់ឃើញថាបុរសត្រួតត្រាដោយស្របច្បាប់លើចំណុចពិសេសជាច្រើននៃជីវិតរបស់ស្ត្រីដូចជាការងារ ទ្រព្យសម្បត្តិ សេរីភាព និងការដើរហើរ ព្រមទាំងទំនាក់ទំនងផ្លូវភេទ និងការបន្តពូជផងដែរ។ ជាទូទៅ គេយល់ឃើញថាស្ត្រី ឬក្មេងស្រីគឺជាទ្រព្យសម្បត្តិ ឬជាទំនួលខុសត្រូវរបស់បុរស។ ប្រសិនបើបុរសម្នាក់មិន«ត្រួតត្រា»លើស្ត្រី ឬក្មេងស្រីទេ នោះអំណាច និងសិទ្ធិអំណាចរបស់គេក្នុងនាមជាបុរសនឹងបង្កឱ្យមានការសង្ស័យ។ គេអាចចាត់ទុកបុរសនោះថាមិនមានភាពជាបុរសគ្រប់គ្រាន់ ប្រសិនបើគេមិនបង្ហាញអំពីអំណាចនេះ។

❓ តើក្មេងស្រីអាចចរចា ឬមិនប្រតិបត្តិតាមបទដ្ឋានយេនឌ័របានដែរឬទេ បើសិនពួកគេយល់ឃើញថាបទដ្ឋានទាំងនោះមានលក្ខណៈរឹតបន្តឹង?

- ☝ ដោយអាស្រ័យលើបរិបទគ្រួសារ និងវប្បធម៌ ក្មេងស្រី និងស្ត្រីមួយចំនួនអាចមានភាពងាយស្រួលក្នុងការចរចាពីច្បាប់ និងការរឹតត្បិតផ្សេងៗដូចជា សេរីភាព និងការដើរហើរ ការស្លៀកពាក់ សិទ្ធិទទួលបានធនធាន រួមបញ្ចូលទាំងឧបករណ៍នានា (ដូចជាទូរសព្ទដៃ) ចំណង់ចំណូលចិត្ត ការជ្រើសរើសការសិក្សា ឬមុខរបរនាពេលអនាគតរបស់ខ្លួន។ សម្រាប់ក្មេងស្រី និងស្ត្រីមួយចំនួន ការចរចាទាំងនេះអាចជាបញ្ហាប្រឈមខ្លាំង ហើយជួនកាលមិនអាចធ្វើទៅបានទៀតផង។ ការគាំទ្រពីមិត្តភក្តិ គ្រូបង្រៀន និងមនុស្សពេញវ័យដែលមានឥទ្ធិពលក្នុងសង្គមនៅក្នុងគ្រួសារ ឬអ្នកជិតខាងអាចជាជំនួយដ៏ធំក្នុងករណីបែបនេះ។

**🔑 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូ ៖

- 🕯 បញ្ចប់សកម្មភាពនេះដោយមានកំណត់ត្រាជាវិជ្ជមាន និងត្រូវសម្រេចឱ្យបាននូវលទ្ធភាពនៃការចរចាទោះបីជាសិស្សអាចមានការប្រឈមមុខពិតប្រាកដជាច្រើននៅពេលគេអនុវត្តការចរចានេះនៅក្នុងជីវិតជាក់ស្តែងក៏ដោយ ។

🕯 នៅពេលដែលក្រុមទាំងអស់ដឹងថា ករណីសិក្សារបស់ខ្លួនមានលក្ខណៈដូចគ្នាទាំងស្រុងដោយគ្រាន់តែមានចំណុចខុសគ្នាមួយនៅចុងបញ្ចប់នៃសាច់រឿង សិស្សអាចឆ្លើយតបដោយភាពភ្ញាក់ផ្អើល និងបែបកំប្លែង។ នេះគឺជាការដឹកនាំដ៏ល្អមួយសម្រាប់លោកគ្រូ អ្នកគ្រូក្នុងការធ្វើឱ្យការពិភាក្សាមានភាពវិជ្ជមានដោយផ្តោតលើអ្វីដែលអាចធ្វើទៅបាន។

✉ **សារសំខាន់ៗ ៖**

- ការយល់ដឹងថា យេនឌ័រគឺជាការកំណត់ និងជាការរៀនសូត្ររបស់សង្គម ធ្វើឱ្យការមិនព្រមសិក្សា ការសិក្សាថ្មីៗ ការចរចា និងការផ្លាស់ប្តូរអាចធ្វើទៅបាន។
- ខណៈដែលការរើសអើងផ្នែកយេនឌ័រមានផលជះទៅលើបុរស និងស្ត្រីគ្រប់រូប វាធ្វើឱ្យមានផលប៉ះពាល់ដល់បុគ្គលនានាក្នុងកម្រិតខុសៗគ្នា ដោយអាស្រ័យលើកត្តាផ្សេងៗជាច្រើននៅក្នុងជីវិតរបស់គេ ដូចជាឥរិយាបថគ្រួសារ ស្ថានភាពសេដ្ឋកិច្ច បទដ្ឋានវប្បធម៌សង្គម អាយុ និងការគាំទ្រពីអ្នកដទៃ។
- ករណីនេះធ្លាប់កើតមានរួចហើយ និងនៅតែអាចធ្វើទៅបានទៀតសម្រាប់មនុស្សក្នុងការជម្នះលើបទដ្ឋានយេនឌ័រដែលគេអាចមើលឃើញថា មានភាពរឹតត្បិត និងពង្រីកជម្រើសរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ សមត្ថភាពក្នុងការធ្វើដូច្នេះបានគឺមានលក្ខណៈខុសគ្នាចំពោះបុគ្គលម្នាក់ៗ និងអាស្រ័យលើអាយុ បទពិសោធន៍ និងជំនាញក្នុងការចរចា ក៏ដូចជាកាលៈទេសៈផ្ទាល់ខ្លួន និងសង្គមរបស់គេដែរ។

**ឧបសម្ព័ន្ធទី ២**

**ករណីសិក្សារបស់ «សោភា»**

សោភាមានអាយុ ១៧ឆ្នាំ ហើយនាងជិតបញ្ចប់ការសិក្សារបស់នាងនៅសាលាហើយ។ នាងរៀនពូកែណាស់ ហើយតែងតែជាប់ចំណាត់ថ្នាក់លេខមួយនៅក្នុងថ្នាក់រៀនរបស់នាងទៀតផង។ នាងតែងតែមានចំណាប់អារម្មណ៍មួយក្នុងការសិក្សាផ្នែកវិទ្យាសាស្ត្រ និងចង់ដាក់ពាក្យសុំចូលរៀនមុខវិជ្ជាទន្តពេទ្យនៅមហាវិទ្យាល័យជាន់ខ្ពស់មួយនៅ ក្នុងទីក្រុងភ្នំពេញ។

នាងមិនបានដឹងច្បាស់ទេថា តើឪពុកម្តាយរបស់នាងនឹងអនុញ្ញាតឱ្យនាងទៅរស់នៅក្នុងទីក្រុងភ្នំពេញតែឯងដើម្បីបន្តការសិក្សាសម្រាប់រយៈពេល ២ ឆ្នាំដែរ ឬទេ?

ចូលរៀបចំការសម្តែងតួមួយពីការសន្ទនារបស់នាងជាមួយឪពុកម្តាយរបស់នាង ដែលចុង**បញ្ចប់ឪពុកម្តាយរបស់នាងយល់ព្រមតាមបំណងរបស់នាង។**

**ករណីសិក្សារបស់ «សុផា»**

សុផាមានអាយុ១៧ឆ្នាំ ហើយនាងជិតបញ្ចប់ការសិក្សារបស់នាងនៅសាលាហើយ។ នាងរៀនពូកែណាស់ ហើយតែងតែជាប់ចំណាត់ថ្នាក់លេខមួយនៅក្នុងថ្នាក់រៀនរបស់នាងទៀតផង។ នាងតែងតែមានចំណាប់អារម្មណ៍មួយក្នុងការសិក្សាផ្នែកវិទ្យាសាស្ត្រ និងចង់ដាក់ពាក្យសុំចូលរៀនមុខវិជ្ជាទន្តពេទ្យនៅមហាវិទ្យាល័យជាន់ខ្ពស់មួយនៅ ក្នុងទីក្រុងភ្នំពេញ។

នាងមិនបានដឹងច្បាស់ទេថា តើឪពុកម្តាយរបស់នាងនឹងអនុញ្ញាតឱ្យនាងទៅរស់នៅក្នុងទីក្រុងភ្នំពេញតែម្នាក់ឯងដើម្បីបន្តការសិក្សាសម្រាប់រយៈពេល ២ ឆ្នាំដែរ ឬទេ។

ចូររៀបចំការសម្តែងតួមួយពីការសន្ទនារបស់នាងជាមួយឪពុកម្តាយរបស់នាង ដែលចុង**បញ្ចប់ឪពុកម្តាយរបស់នាងមិនយល់ព្រមតាមបំណងរបស់នាងទេ។**

**ក្របខណ្ឌចំណេះដឹង**

**ភេទ យេនឌ័រ និងទំនាក់ទំនងផ្លូវភេទ[១២]**

**ភេទ** គឺជាភាពខុសគ្នាផ្នែកជីវសាស្រ្តរវាងប្រុស និងស្រីដែលមានតាំងពីកំណើត។ នៅពេលទើបនឹងកើត គេកំណត់ភេទរបស់ទារកដោយផ្អែកលើការរួមបញ្ចូលគ្នារវាងលក្ខណៈរូបរាងកាយ រួមមាន ក្រូម៉ូសូម អ័រម៉ូន សរីរាង្គបន្តពូជខាងក្នុង និងប្រដាប់បន្តពូជ (ដូចជាលិង្គ ឬយោនី) ឧទាហរណ៍ ឪពុកម្តាយ គ្រួសារ និងមិត្តភក្តិ ជាទូទៅរមែងចង់ដឹងអំពីភេទរបស់ទារក។

**យេនឌ័រ** គឺជាបណ្តុំតួនាទី ទំនួលខុសត្រូវ សិទ្ធិ ការផ្តល់សិទ្ធិ និងកាតព្វកិច្ចផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយដែលវប្បធម៌បានកំណត់ទាក់ទងនឹងភាពជាស្រី និងប្រុស ក៏ដូចជាទំនាក់ទំនងនៃអំណាចរវាង និងក្នុងចំណោមស្រ្តី និងបុរស ព្រមទាំងក្មេងស្រី និងក្មេងប្រុស។ បុគ្គលគ្រប់រូបកើតមកជាមួយនឹងភេទផ្នែកជីវសាស្រ្តតែម្តង ប៉ុន្តែគេរៀនពីរបៀបធ្វើជា «ប្រុស» ឬ «ស្រ្តី» តាមរយៈដំណើរការនៃ «កំណត់ពីយេនឌ័រ»។

និយមន័យ និងការរំពឹងទុកនូវអ្វីដែលមានន័យថា ជាមនុស្សស្រី ឬក្មេងស្រី និងជាមនុស្សប្រុស ឬក្មេងប្រុស និងការដាក់ទណ្ឌកម្មចំពោះការមិនបានប្រកាន់ខ្ជាប់នូវការរំពឹងទុកទាំងនោះមានលក្ខណៈខុសគ្នាទៅតាមវប្បធម៌ និងពេលវេលា។ គេអាចកំណត់ចំណុចទាំងនេះថាជាបទដ្ឋានយេនឌ័រ។ ការយល់ឃើញទាំងនេះ ជារឿយៗ ជាប់ទាក់ទងគ្នាជាមួយកត្តាផ្សេងៗដូចជា ពូជសាសន៍ វណ្ណៈ អាយុ និងនិន្នាការភេទ។ ឧទាហរណ៍ ឪពុកម្តាយតែងតែស្លៀកពាក់ឱ្យកូនៗរបស់ខ្លួនដើម្បីឆ្លុះបញ្ចាំងឱ្យឃើញនូវប្រពៃណីវប្បធម៌ដែលថាសម្លៀកបំពាក់អ្វីដែលសមស្របសម្រាប់កូនប្រុស ឬកូនស្រី។

**ទំនាក់ទំនងផ្លូវភេទ**

WHO (អង្គការសុខភាពពិភពលោក) បានពន្យល់ពីនិយមន័យដែលអាចប្រើការបានចំពោះពាក្យ «ទំនាក់ទំនងផ្លូវភេទ» ថាជា «ចំណុចពិសេសដ៏សំខាន់មួយនៅក្នុងជីវិតរបស់មនុស្សដែលមានដូចជា៖ ភេទ អត្តសញ្ញាណ និងតួនាទីយេនឌ័រ និន្នាការភេទ ចំណង់ផ្លូវភេទ ការសប្បាយ ភាពស្និទ្ធស្នាល និងការបន្តពូជ។ ទំនាក់ទំនងផ្លូវភេទត្រូវឆ្លងកាត់ និងបង្ហាញតាមរយៈគំនិត ការស្រមើស្រមៃ ចំណង់ ជំនឿ អាកប្បកិរិយា តម្លៃ ឥរិយាបថ ការអនុវត្តតួនាទី និងទំនាក់ទំនង។ ទោះបីជាទំនាក់ទំនងផ្លូវភេទអាចរួមបញ្ចូលនូវគ្រប់ចំណុចទាំងនេះក៏ដោយ ក៏វាមិនមែនមានន័យថាគេតែងតែឆ្លងកាត់ និងបង្ហាញចំណុចទាំងអស់នេះជានិច្ចដែរ។ ទំនាក់ទំនងផ្លូវភេទទទួលរងឥទ្ធិពលអន្តរកម្មពីកត្តាផ្នែកជីវសាស្រ្ត ចិត្តសាស្រ្ត សង្គម សេដ្ឋកិច្ច នយោបាយ វប្បធម៌ ច្បាប់ ប្រវត្តិសាស្រ្ត សាសនា និងស្មារតី» (WHO,

[១២] ប្រែសម្រួលពី (២០១៦)។ ដកស្រង់ពី
http://www.who.int/reproductivehealth/topics/sexual_health/sh_definitions/en/

២០០៦a)

ជាញឹកញាប់ គេតែងគិតថាពាក្យ «ទំនាក់ទំនងផ្លូវភេទ» ជាប់ពាក់ព័ន្ធនឹងភេទ និងការរួមភេទ។ ទោះជាយ៉ាងនេះក្តី ពាក្យនេះមានអត្ថន័យច្រើនលើសពីនេះទៅទៀត។ ពាក្យនេះរួមបញ្ចូលរាល់ ការគិត អារម្មណ៍ និងអាកប្បកិរិយាផ្នែកយេនឌ័រជាក់លាក់ (ស្រី ឬប្រុស) ភាពទាក់ទាញ និងសេចក្តីស្រឡាញ់ ក៏ដូចជាទំនាក់ទំនងនានាដែលរួមមានភាពស្និទ្ធស្នាលផ្នែកផ្លូវភេទ។ រាប់ចាប់តាំងពីរបៀបស្លៀកពាក់រហូតដល់ដំណើរមានរដូវ ការធ្វើអនាម័យរាងកាយ ការមានអារម្មណ៍ទោរទន់ទៅរកនរណាម្នាក់ ការរៀបការ ។ល។ គឺជាផ្នែកមួយនៃទំនាក់ទំនងផ្លូវភេទរបស់មនុស្ស។ ដូច្នេះ ទំនាក់ទំនងផ្លូវភេទគឺជាទស្សនៈទានដ៏ទូលំទូលាយមួយដែលយេនឌ័រគ្រាន់តែជាផ្នែកមួយនៃទស្សនៈទាននេះប៉ុណ្ណោះ។

**និន្នាការភេទ**

«យើងប្រើអក្សរកាត់ LGBT ដើម្បីពណ៌នាអំពីសហគមន៍ស្រីស្រលាញ់ស្រី ប្រុសស្រលាញ់ប្រុស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ។ អក្សរចំនួន៣ដំបូង (LGB) សំដៅទៅលើនិន្នាការភេទ។ «T» សំដៅលើអត្តសញ្ញាណយេនឌ័រ។

និន្នាការភេទពិពណ៌នាពីការមានអារម្មណ៍ទោរទន់ផ្លូវកាយ មនោសញ្ចេតនា និង ផ្លូវចិត្តដ៏យូររបស់មនុស្សម្នាក់ចំពោះមនុស្សម្នាក់ទៀត (ឧទាហរណ៍ អ្នកស្រឡាញ់ភេទដូចគ្នា ប្រុសស្រឡាញ់ប្រុស ស្រីស្រឡាញ់ស្រី អ្នកស្រឡាញ់ទាំងពីរភេទ) ចំណែកឯអត្តសញ្ញាណយេនឌ័រពិពណ៌នាពីអារម្មណ៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ដែលកើតមកជាប្រុស ឬជាស្រី (ឬនរណាម្នាក់ដែលមិនស្ថិតនៅក្នុងប្រព័ន្ធយេនឌ័រនោះ)។ និយាយសាមញ្ញទៅ៖ និន្នាការភេទសំដៅដល់នរណាម្នាក់ដែលអ្នកទោរទន់ ឬមានទំនោរទៅរក និងស្រឡាញ់ ចំណែកឯអត្តសញ្ញាណយេនឌ័រគឺសំដៅទៅលើអារម្មណ៍នៃលក្ខណៈផ្ទាល់ខ្លួនរបស់អ្នក។

«អ្នកប្តូរភេទមាននិន្នាកាភេទមួយដូចមនុស្សគ្រប់គ្នាដែរ។ អ្នកប្តូរភេទអាចជាអ្នកស្រឡាញ់ភេទដូចគ្នា ជាស្រីដែលស្រឡាញ់ស្រីដូចគ្នា ជាប្រុសដែលស្រឡាញ់ប្រុសដូចគ្នា ឬជាអ្នកដែលស្រឡាញ់ភេទទាំងពីរ។ ឧទាហរណ៍ មនុស្សម្នាក់ប្តូរភេទពីប្រុសទៅស្រី ហើយទោរទន់ទៅរកតែប្រុសប៉ុណ្ណោះ អាចកំណត់បានជាទូទៅថា ជាស្ត្រីស្រឡាញ់ភេទដូចគ្នា។ មនុស្សម្នាក់ដែលប្តូរភេទពីស្រីទៅប្រុស ហើយទោរទន់ទៅរកតែប្រុសប៉ុណ្ណោះ អាចកំណត់បានទូទៅថាជាប្រុសស្រឡាញ់ប្រុស។ដូចគ្នា(ស្រឡាញ់ភេទដូចគ្នា)»

(ប្រភព៖ ការប្តូរយេនឌ័រ FAQ” s. GLAAD.)[១៣]

[១៣] (២០១៦)។ ដកស្រង់ពី https://www.glaad.org/transgender/transfaq

**ក្របខណ្ឌចំណេះដឹង**

ដូចដែលបានពិភាក្សារួចមកហើយ ភេទគឺជាភាពខុសគ្នាផ្នែករាងកាយ និងជីវសាស្ត្ររវាងបុរស និងស្ត្រី។ យេនឌ័រ គឺជានិយមន័យផ្នែកសង្គម និងវប្បធម៌សម្រាប់បុរស និងស្ត្រី។ ភាពខុសគ្នាផ្នែកយេនឌ័រមានលក្ខណៈខុសប្លែកគ្នាតាមវប្បធម៌ និងមានការផ្លាស់ប្តូរទៅតាមពេលវេលា។

កត្តាដែលនាំឱ្យមានវិសមភាពរវាងស្ត្រី និងបុរស គឺយេនឌ័រ មិនមែនភេទទេ។ «**ការបង្រៀនពីសង្គម** គឺជាដំណើរដែលតាមរយៈដំណើរការនោះសង្គមមួយបានបង្កើតបទដ្ឋាន និងវប្បធម៌ ព្រមទាំងកំណត់ពីតួនាទី និងទំនួលខុសត្រូវរបស់មនុស្ស។ ការបង្រៀនពីសង្គមកើតមានឡើងនៅគ្រប់ទីកន្លែង។ គ្រួសារ និងផ្ទះបង្កើតឱ្យមានគ្រឹះនៃការបង្រៀនពីសង្គមដែលបន្តរហូតអស់មួយជីវិត។ ការបង្រៀនពីសង្គមធ្វើឱ្យអាកប្បកិរិយា និងរបៀបនៃការប្រាស្រ័យទាក់ទងរបស់បុរស និងស្ត្រីមានលក្ខណៈខុសគ្នា។ នៅក្នុងសង្គមអភិរក្សនិយម គេមិនអនុញ្ញាតឱ្យស្ត្រីចែករំលែកពីទស្សនៈរបស់គេទេ។ គេពេញចិត្តឱ្យស្ត្រីរក្សាភាពស្ងប់ស្ងាត់ និងភាពឱនលំទោន ហើយអាកប្បកិរិយាស្លូតបូតត្រូវបានពង្រឹងដោយការរើសអើងយេនឌ័រ។ ស្ថានភាពនេះរីករាលដាលតាំងពីក្នុងគ្រួសាររហូតដល់កន្លែងធ្វើការ និងរហូតដល់ស្ថាប័ននានាក្នុងសហគមន៍»។ (ICRW, (២០១៦) កម្មវិធី ភែស ប្រនហ្ស៍ (Gap Inc.)

សង្គមធ្វើឱ្យបុគ្គលម្នាក់ៗប្រកាន់ខ្ជាប់នូវបទដ្ឋាន និងការរំពឹងទុកយេនឌ័រយ៉ាងរឹងមាំ។ ការដាក់ពិន័យចំពោះការប្រព្រឹត្តល្មើសបទដ្ឋានទាំងនេះមានភាពខុសប្លែកគ្នាទៅតាមឋានៈ ឬអំណាចរបស់មនុស្សម្នាក់ដែលមាននៅក្នុងសង្គម។ ប៉ុន្តែ ដោយសារតែយើងរស់នៅក្នុងពិភពលោកមួយដែលមានអំណោយផលចំពោះបុរស ទើបធ្វើឱ្យស្ត្រីភាគច្រើនរមែងប្រឈមនឹងផលវិបាកធ្ងន់ធ្ងរចំពោះការមិនអនុវត្តតាមបទដ្ឋានយេនឌ័រ។ វិសមភាពទាំងនេះអាចផ្លាស់ប្តូរបានដើម្បីឱ្យស្ត្រីទទួលបានឱកាសកាន់តែច្រើន។ នេះហើយជាមូលហេតុដែលវាមានសារៈសំខាន់សម្រាប់យើងក្នុងការយល់ដឹងពីយេនឌ័រ។

**ក្របខណ្ឌចំណេះដឹង**

**ការយល់ដឹងកាន់តែប្រសើរពីបិតាធិបតេយ្យ[១៤]**

បិតាធិបតេយ្យបង្កើតឱ្យមានមូលដ្ឋានគ្រឹះនៃការកំណត់ពីយេនឌ័រ និងទំនាក់ទំនងអំណាចមិនស្មើភាពគ្នារវាងបុរស និងស្ត្រី។ បិតាធិបតេយ្យមិនមែនជាបុគ្គលិកលក្ខណៈបុគ្គលទេ ប៉ុន្តែវាជា*ប្រព័ន្ធ*សង្គមដែលមានឥទ្ធិពលយ៉ាងសំខាន់ និងមានគ្រប់ទីកន្លែង។ វាជាប្រព័ន្ធមួយរបស់ច្បាប់ និងបទដ្ឋានដែលផ្តល់ឱ្យបុរសនូវអំណាច និងបុព្វសិទ្ធិជាក់លាក់មួយចំនួន។ គេបានរៀបចំចំណុចទាំង២ឡើងយ៉ាងច្បាស់លាស់ ប៉ុន្តែក៏មានការកំណត់ព្រំដែនស្តីពីតួនាទី និងទំនួលខុសត្រូវផ្នែកយេនឌ័រដែលមានលក្ខណៈមិនច្បាស់លាស់ច្រើនដែរ។ បិតាធិបតេយ្យមាននៅគ្រប់ស្ថាប័ន និងវប្បធម៌ទាំងអស់ ៖

**គ្រួសារ** គឺជាគ្រឹះនៃការត្រួតត្រា និងការធានាចំពោះបញ្ញត្តិនៃបទដ្ឋានសង្គម។

**សាសនា** កំណត់សំណុំនៃកាតព្វកិច្ច និងសិទ្ធិ ព្រមទាំងកំណត់ពីចរិយាធម៌ សីលធម៌ អាកប្បកិរិយា និងច្បាប់ និងជាច្បាប់សម្រាប់អ្វីដែលគេហៅថាអំពើល្អសម្រាប់សាធារណៈជន។ សាសនាហាក់ដូចជាមិនអាចដកខ្លួនចេញពីការគ្រប់គ្រងរបស់បិតាធិបតេយ្យបានឡើយ។

**ប្រព័ន្ធច្បាប់** នៅតែមានភាពអំណោយផលចំពោះបុរសនៅក្នុងគំនិតដូចគ្នានៃរបបបិតាធិបតេយ្យ។ ភាពអំណោយផលនេះគឺមានវត្តមាន និងមានលក្ខណៈទូទៅនៅពេលដែលគេបកស្រាយច្បាប់ និងឆ្លុះបញ្ចាំងជាច្រើនដងនៅក្នុងការប្រកាសរបស់តុលាការ។

**ប្រព័ន្ធសេដ្ឋកិច្ច** នៅតែមិនទទួលស្គាល់តម្លៃនៃការងារក្នុងផ្ទះ។ យើងនៅតែត្រូវការច្បាប់ដើម្បីធានានូវប្រាក់ឈ្នួលស្មើគ្នាសម្រាប់ស្ត្រី ដែលឆ្លុះបញ្ចាំងពីការបន្តនៃប្រព័ន្ធបិតាធិបតេយ្យ។

**ប្រព័ន្ធនយោបាយ** កម្រនឹងអនុញ្ញាតឱ្យស្ត្រីរីកចម្រើនណាស់ លុះត្រាតែពួកគេមានជាប់ទាក់ទង ឬត្រូវបានតម្លើងឋានៈដោយបុរសខ្លាំងមួយចំនួន។

**ប្រព័ន្ធអប់រំ** ក៏ពង្រឹងនិមិត្តរូប ការរំពឹងទុក និងតួនាទីយេនឌ័រដែរ។ នៅក្នុងសៀវភៅនានា យើងតែងតែឃើញថាគេបង្ហាញស្ត្រីកំពុងធ្វើការងារផ្ទះ។ល។ ហើយបុរសជាអ្នកមានចំណេះដឹង។ ចំពោះសកម្មភាពក្រៅកម្មវិធីសិក្សា គេឱ្យក្មេងស្រីធ្វើសកម្មភាពពាក់ព័ន្ធនឹងការច្រៀងរាំ ចំណែកឯក្មេង

[១៤] បណ្តាញច្បាប់សិទ្ធិមនុស្ស (បំណែងចែកមជ្ឈមណ្ឌលព័ត៌មានសង្គម-ច្បាប់)។ (២០១១) *ម៉ូឌុលបណ្តុះបណ្តាលអំពីសិទ្ធិស្ត្រីប្រឆាំងនឹងអំពើហិង្សា* មជ្ឈមណ្ឌលព័ត៌មានសង្គម-ច្បាប់ ទីក្រុងញូដេលី

ប្រុសធ្វើសកម្មភាពទាក់ទងនឹងការរៀបចំចាត់ចែង កីឡា ។ល។

**ប្រព័ន្ធផ្សព្វផ្សាយ និងការកម្សាន្ត និងកីឡា** សុទ្ធតែឆ្លុះបញ្ចាំងអំពីផ្នត់គំនិតអវិជ្ជមានដូចគ្នា។ តាមពិតទៅ ប្រព័ន្ធផ្សព្វផ្សាយ និងរបៀបដែលវាបង្ហាញពីស្ត្រី ដើរតួនាទីយ៉ាងសំខាន់មួយក្នុងការបន្តនិងពង្រឹងប្រព័ន្ធបិតាធិបតេយ្យ។ ឧទាហរណ៍ ការប្រកួតកីឡាវាយកូនបាល់សំខាន់ៗនៅតែបន្តផ្តល់រង្វាន់ជាទឹកប្រាក់ខុសគ្នាសម្រាប់ព្រឹត្តិការណ៍ប្រកួតរវាងបុរស និងស្ត្រី។ (បណ្តាញច្បាប់សិទ្ធិមនុស្ស (Human Rights Law Network) (ការបែងចែកមជ្ឈមណ្ឌលព័ត៌មានស្តីពីច្បាប់សង្គម (A division of Socio Legal Information Centre))។ (២០១១). ម៉ូឌុលសម្រាប់ការបណ្តុះបណ្តាលពីសិទ្ធិស្ត្រីប្រឆាំងនឹងអំពើហិង្សា(Training Module on the Rights of Women Against Violence) មជ្ឈមណ្ឌលព័តិស្តីពីច្បាប់សង្គម(Socio Legal Information Centre) ទីក្រុងញូដេលី)

បុរសតែឯងមិនមែនជាអ្នកដឹកនាំបិតាធិបតេយ្យទេ។ ស្ត្រីខ្លួនឯងក៏ជាអ្នកដឹកនាំ និងជាអ្នកប្រព្រឹត្តនូវការឱ្យតម្លៃបិតាធិបតេយ្យដែរ ហេតុនេះហើយទើបយើងជារឿយៗ តែងឮពាក្យថា «ស្ត្រីគឺជាសត្រូវដ៏អាក្រក់បំផុតរបស់ស្ត្រីគ្នាឯង»។

គេក៏សម្តែងឱ្យឃើញ និងមើលឃើញតម្លៃបិតាធិបតេយ្យតាមរយៈការគិត និងអាកប្បកិរិយារបស់មនុស្សដែរ។ តម្លៃបិតាធិបតេយ្យគឺជាការកំណត់ ដូច្នេះហើយ គេអាចជម្នះ និងផ្លាស់ប្តូរបានតាមរយៈការផ្តល់ឱកាសស្មើភាពគ្នាដល់ស្ត្រីដើម្បីឱ្យគាត់សម្រេចបាននូវសមភាពយេនឌ័រ។

**ក្របខណ្ឌចំណេះដឹង**

**ការបង្ហាញអំណាចក្នុងលក្ខណៈខុសៗគ្នា**[១៥]

"ជាញឹកញាប់ គេយល់ពីអំណាចតាមរយៈបរិបទនៃការបង្ខិតបង្ខំ ការត្រួតត្រា និងសិទ្ធិអំណាច(អាជ្ញា) ហើយគេមើលឃើញវាថាជាការបង្កើនភាពងាយរងគ្រោះដល់អ្នកដែលមានអំណាចតិច។ អំណាចអាចមានទាំង**ការមិនផ្តល់លទ្ធភាពផង និងការផ្តល់លទ្ធភាពផង**។ អំណាចដែលយើងនឹងសិក្សានៅពេលក្រោយគឺមានទាំងលក្ខណៈថាមវន្តផង និងប្រែប្រួលផងហើយអាចផ្លាស់ប្តូរគោលជំហរអវិជ្ជមានទៅជាវិជ្ជមាន និងទៅជាមានលទ្ធភាពវិញបានដោយអាស្រ័យលើការបង្ហាញពីអំណាច ពោលគឺ ***នៅពេលគេប្រើអំណាចដើម្បីផ្តល់លទ្ធភាព វាក្លាយជាដំណើរនៃការផ្តល់សិទ្ធិអំណាច*** ដែលនេះមានន័យថាគេប្រើអំណាចក្នុងលក្ខណៈស្ថាបនាដើម្បីភាពរីកចម្រើន និងសុខុមាលភាពផ្ទាល់ខ្លួន និងអ្នកដទៃ។ ខាងក្រោមនេះគឺជាការបង្ហាញពីអំណាចក្នុងលក្ខណៈខុសៗគ្នាដែលគេប្រើប្រាស់ជាទូទៅបំផុត៖

**អំណាចត្រួតត្រា** - អំណាចនេះពាក់ព័ន្ធនឹងការអនុវត្តអំណាច ឬសិទ្ធិអំណាច(អាជ្ញា)លើបុគ្គលណាម្នាក់ ឬស្ថានភាពណាមួយ។ គេបង្ហាញអំណាចប្រភេទនេះជាទូទៅនៅក្នុងទម្រង់នៃអំពើពុករលួយ ការគាបសង្កត់ ឬការធ្វើបាប(ធ្វើទុក្ខបុកម្នេញ)ជាដើម។ ការបង្ហាញពីសិទ្ធិអំណាច(អាជ្ញា)នេះគឺជាការរំលោភអំណាចដោយផ្ទាល់ ដោយសារតែគេអនុវត្តវាក្នុងគោលបំណងធ្វើឱ្យមាន ឥទ្ធិពល ឬបង្កឧបសគ្គដល់អ្នកដទៃ។

**អំណាចជាមួយ** - ទម្រង់នៃការអនុវត្តអំណាចប្រភេទនេះពាក់ព័ន្ធនឹងការបង្កើនការប្រើសិទ្ធអំណាច(អាជ្ញា) ដែលបុគ្គលម្នាក់ ឬក្រុមមួយមានក្នុងការធ្វើការងារជាមួយក្រុមបុគ្គលផ្សេងទៀត ឆ្ពោះទៅរកការសម្រេចបាននូវវត្ថុបំណងរួមមួយ។ ប្រភេទនៃថាមវន្តអំណាចនេះជួយប្រមូលផ្តុំអ្នកដែលមានកម្រិតចំណេះដឹង និងសមត្ថភាពផ្សេងៗគ្នា។

**អំណាចចំពោះ** - ទម្រង់នៃអំណាចនេះមានឫសគល់នៅក្នុងវិញ្ញាណស្តីពីខ្លួនឯងរបស់បុគ្គលនានា ហើយវាជួយរៀបចំ និងមានឥទ្ធិពលលើជីវិតផ្ទាល់របស់បុគ្គល។ វាមាននៅក្នុងការបង្ហាញចំពោះការគិត ការវាស់ស្ទង់ ចំណេះដឹង ទ្រព្យសម្បត្តិ និងបច្ចេកទេសទាំងឡាយដែលមនុស្សម្នាក់ប្រើប្រាស់ដើម្បីយល់ពីខ្លួនឯង និងប្រាស័យទាក់ទងយ៉ាងច្បាស់លាស់ជាមួយពិភពលោក។ ប្រសិនបើគេអនុវត្តអំណាចនេះនៅក្នុងបរិបទរបស់ក្រុមបុគ្គលមួយ ពេលនោះទម្រង់នៃការអនុវត្តន៍អំណាចប្រភេទនេះ

[១៥] ICRW (២០១១), *ចលនាសមភាពយេនឌ័រនៅសាលារៀន សៀវភៅមគ្គុទេសក៍បណ្តុះបណ្តាលសម្រាប់អ្នកសម្របសម្រួល។* ICRW ទីក្រុងញូដេលី

អាចក្លាយជាមូលដ្ឋាននៃការបង្កើត «អំណាចជាមួយ»។

**អំណាចនៅក្នុង** - ទម្រង់នៃអំណាចនេះ គេអនុវត្តនៅក្នុងបរិបទស្វ័យប៉ាន់ប្រមាណ និងវាយតម្លៃ។ ទម្រង់នេះរាប់បញ្ចូលទាំងសមត្ថភាពនានាដែលផ្តល់ឱ្យមនុស្សនូវអំណាចក្នុងការប្រមើមើល ឬកសាងអនាគតដែលល្អប្រសើរជាងមុន និងមានបំណងប្រាថ្នាធ្វើឱ្យពិភពលោកមានការផ្លាស់ប្តូរ។ ទម្រង់នៃអំណាចនេះធ្វើឱ្យបុគ្គលម្នាក់ដឹងពីសិទ្ធិ និងទំនួលខុសត្រូវរបស់ខ្លួនដែលធ្វើឱ្យគេយល់ពីមុខតំណែង និងតួនាទីរបស់ខ្លួនតាមរយៈគុណសម្បត្តិនៃសមត្ថភាពដែលគេមាន។

**គ្រាប់ខណ្ឌចំណេះដឹង**

តួនាទីនៃអំណាចមិនមានលក្ខណៈដាច់ខាតទេ។ សិទ្ធិទទួលបាន និងការត្រួតត្រាលើធនធាន និងដើមទុន (សង្គម វប្បធម៌ នយោបាយ និងសេដ្ឋកិច្ច) កំណត់តួនាទីនៃអំណាច ដូច្នេះហើយតួនាទីទាំងនេះអាចមានការផ្លាស់ប្តូរ។ ការផ្តល់ឱកាសស្មើភាពគឺជាចំណុចចាប់ផ្តើមឆ្ពោះទៅរកការផ្លាស់ប្តូរតួនាទីទាំងនេះ និងបង្កើតឱ្យមានសមភាព។

អ្នកដែលចាប់ផ្តើមពីចំណុចដែលបាត់បង់ឱកាស(អំណាចតិច)អាចត្រូវការឱ្យគេផ្តល់ឱកាសជាក់លាក់នានាដើម្បីឱ្យខ្លួនអាចមានលទ្ធភាពដូចគ្នាក្នុងការចាប់យកប្រយោជន៍ពីការមានឱកាសស្មើភាពគ្នា។

នៅពេលដែលអ្នកមានវិសមភាពទទួលបានឱកាសដូចគ្នា ពេលនោះអ្នកដែលមានសមត្ថភាព ឬមានអំណាចជាងនឹងទទួលបានប្រយោជន៍កាន់តែច្រើន។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលអ្នកដែលមានសមត្ថភាពស្មើគ្នាទទួលបានឱកាសឱ្យស្មើៗគ្នា ពេលនោះពួកគេអាចមានផលប្រយោជន៍ដូចគ្នា ឬផលប្រយោជន៍ស្មើភាព ឬមានសមធម៌។

# ជំពូកទី៣ ៖ យេនឌ័រ និងការប្រាស្រ័យទាក់ទង

## ទិដ្ឋភាពទូទៅ

ការប្រាស្រ័យទាក់ទងគឺជាដំណើរការនៃការផ្ញើ និងទទួលព័ត៌មាន ឬគំនិតតាមរយៈពាក្យសម្ដី សកម្មភាព ឬសញ្ញា។ ការប្រាស្រ័យទាក់ទងនេះបង្កើតមូលដ្ឋានគ្រឹះនៃទំនាក់ទំនងទាំងអស់ ហេតុដូច្នេះហើយ វាកំណត់នូវចំណុចសំខាន់ៗមួយចំនួននៅក្នុងជីវិតរបស់យើង។ គុណភាពនៃការប្រាស្រ័យទាក់ទងជារឿយៗកំណត់ពីគុណភាពនៃទំនាក់ទំនង។ ជំពូកស្ដីអំពីការប្រាស្រ័យទាក់ទងនឹងបង្កើតឱកាសមួយឱ្យសិស្សឆ្លុះបញ្ចាំង និងយល់ដឹងពីអ្វីដែលរួមចំណែកបង្កើតការប្រាស្រ័យទាក់ទង ការប្រាស្រ័យទាក់ទងជាពាក្យសម្ដី និងកាយវិការ របៀបដែលឧបសគ្គក្នុងការប្រាស្រ័យទាក់ទង ដំណោះស្រាយ និងមធ្យោបាយកែលម្អការប្រាស្រ័យទាក់ទងឱ្យមានប្រសិទ្ធភាព។ ដោយសារកុមារ និងយុវវ័យមានសក្ដានុពលធ្វើជាភ្នាក់ងារសកម្មនៃការផ្លាស់ប្ដូរ ការប្រាស្រ័យទាក់ទងដើរតួនាទីយ៉ាងសំខាន់មួយមិនត្រឹមតែនៅក្នុងជីវិតរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះអ្នកដែលនៅជុំវិញពួកគេដែរ។ ជាញឹកញាប់ ជំនាញទំនាក់ទំនងរបស់ពួកគេកំណត់ពីរបៀបដែលពួកគេត្រូវឆ្លងកាត់វ័យជំទង់ ដំណាក់កាលដំបូងនៃយុវភាព និងពេញមួយជីវិតជាមនុស្សពេញវ័យ។

ជំពូកមុនផ្ដោតលើយេនឌ័រ និងរបៀបដែលបទដ្ឋានយេនឌ័ររឹតត្បិតលើស្ត្រី ព្រមទាំងកាត់បន្ថយជម្រើសដែលពួកគេអាចធ្វើបាន។ វាមានសារៈសំខាន់ណាស់ដែលក្មេងស្រី និងស្ត្រីក្នុងការទទួលស្គាល់ និងចោទជាសំណួរចំពោះបទដ្ឋានបែបនេះ។ ការដែលមានលទ្ធភាពចរចាប្រកបដោយប្រសិទ្ធភាពគឺជាជំនាញនៃការប្រាស្រ័យទាក់ទងដ៏សំខាន់មួយ។ មេរៀននេះមានគោលបំណង កសាងសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងរបស់ស្ត្រីដែលជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ការចរចាពីសិទ្ធិក្នុងការជ្រើសរើស ការសម្រេចចិត្ត និងជម្រើសថាតើត្រូវ ឬមិនផ្លាស់ប្ដូរ។

🕘 **រយៈពេល ៖** ២ ម៉ោង

❐ **ចំនួនលំនាំបង្រៀនសរុប ៖** ៤

🏆 **វត្ថុបំណង ៖**

- ☺ ដើម្បីឱ្យសិស្សយល់ពីតួនាទី និងគុណតម្លៃនៃការប្រាស្រ័យទាក់ទងនៅក្នុងជីវិតរបស់គេ។
- ☺ ដើម្បីលើកទឹកចិត្តសិស្សឱ្យប្រាស្រ័យទាក់ទងជាមួយមនុស្សពេញវ័យនៅជុំវិញខ្លួនប្រកបដោយទំនុកចិត្ត។
- ☺ ដើម្បីបង្រៀនសិស្សពីសារៈសំខាន់នៃការប្រាស្រ័យទាក់ទងជាពាក្យសម្ដី និងកាយវិការ។

# មេរៀនទី៩ ៖ តើការប្រាស្រ័យទាក់ទងជាពាក្យសម្ដីគឺជាអ្វី?[១៦]

🕒 **រយៈពេល ៖** ៣០ នាទី

➲ **វត្ថុបំណង ៖** ដើម្បីសិក្សាពីសារៈសំខាន់នៃការនិយាយឱ្យបានច្បាស់លាស់ ការដឹង និងការស្ដាប់ដោយយកចិត្តទុកដាក់(ការស្ដាប់យ៉ាងសកម្ម)ដោយសារចំណុចមានភាពចាំបាច់ចំពោះការប្រាស្រ័យទាក់ទងជាពាក្យសម្ដីប្រកបដោយប្រសិទ្ធភាព។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

- សម្រាប់គ្រូ៖ ក្ដារខៀន និងដីស ឬក្រដាសព័ត៌មាន និងហ្វឺតលុបមិនជ្រះ ស្កុត កន្ត្រៃ ក្រដាស A4 និងហ្វឺត / ហ្វឺតពណ៌។
- សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន ៖**

- អានទិដ្ឋភាពទូទៅស្ដីពី ជំពូកទី៣ ៖ យេនឌ័រ និងការប្រាស្រ័យទាក់ទង
- អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- អានឧបសម្ព័ន្ធទី៣ដើម្បីជាជំនួយ។
- ប្រមូលសម្ភារៈចាំបាច់ទាំងអស់ផ្សេងទៀត។
- សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

## ២. ដំណើរការបង្រៀន

📢 **សេចក្ដីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកមេរៀនដែលពួកគេបានរៀនក្នុងជំពូកមុន។

---

[១៦] ICRW,. (២០១៦). *កម្មវិធី តែស ប្រនហ្វ៍ សម្រាប់ក្មេងស្រីពេញវ័យ*។ Gap Inc.

☞ អានចំណងជើងមេរៀន ដោយចង្អុលទៅរកចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្សទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ហៅសិស្សស្ម័គ្រចិត្ត ២-៣ នាក់ ឱ្យចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុម។

☞ រួចហើយបែងចែកសិស្សជា២ក្រុម ពោលគឺក្រុមទី១ និងក្រុមទី២។

☞ ឱ្យសមាជិកមកពីក្រុមមួយចាប់គូជាមួយសមាជិកមកពីក្រុមមួយទៀត។ ដូច្នេះគូនីមួយៗមានមាជិកម្នាក់មកពីក្រុមទី១ និងម្នាក់ទៀតមកពីក្រុមទី២។

☞ ផ្ដល់ក្រដាស(ទំហំA4)១សន្លឹកឱ្យគូនីមួយៗ។

☞ ឱ្យសិស្សមកពីក្រុមទី១ នៅតាមគូនីមួយៗជ្រើសយកក្រដាសតូចៗដែលមានសរសេរពាក្យមួយនៅលើនោះមួយសន្លឹក ហើយដោយមិនបង្ហាញពាក្យនោះឱ្យគេដឹង សិស្សត្រូវពណ៌នាពីពាក្យនោះទៅឱ្យដៃគូរបស់ខ្លួនស្ដាប់។ ដោយផ្អែកលើការពិពណ៌នានេះ ដៃគូដែលកំពុងស្ដាប់ត្រូវគូររូបតាមអ្វីដែលខ្លួនគិតថាមាននៅលើក្រដាសនោះ។ នៅពេលដែលគូររូបរួចរាល់ហើយ សិស្សដែលមានក្រដាសត្រូវបង្ហាញពាក្យនោះឱ្យដៃគូខ្លួនមើល។ (លោកគ្រូ អ្នកគ្រូត្រូវរៀបចំក្រដាសដែលមានសរសេរពាក្យទាំងនេះជាមុន)។

☞ ប្រាប់សិស្សថាគេមានពេលមិនលើសពី ៥-៧ នាទីទេក្នុងការអនុវត្តសកម្មភាពនេះ បន្ទាប់ពីទទួលបានការណែនាំរួចហើយ។

☞ បញ្ជីរាយពាក្យដែលគេស្នើដើម្បីសរសេរនៅលើក្រដាសតូចៗ ៖

- ផ្លែប៉ោម
- ផ្ទះ
- ដើមឈើ
- បក្សី
- ព្រះអាទិត្យ
- ផ្កា

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

◇ តើវត្ថុដែលបានគូរនេះដូចគ្នានឹងវត្ថុដែលគេបានផ្ដល់ឱ្យនៅលើប័ណ្ណដែរ ឬទេ? ប្រសិនបើដូច តើមានចំណុចអ្វីខ្លះដែលជួយសិស្សឱ្យធ្វើបានត្រឹមត្រូវ? ប្រសិនបើមិនដូច តើមកពីហេតុអ្វី?

◇ តើសិស្សនៅតាមគូនីមួយៗបានប្រាស្រ័យទាក់ទងគ្នាពីអ្វីដែលត្រូវគូរដោយរបៀបណា?

- តើសិស្សដែលត្រូវគូររូបភាពបានស្តាប់ការណែនាំរបស់ដៃគូខ្លួនដោយយកចិត្តទុកដាក់ដែរ ឬទេ?
- តើគេអាចកែលម្អការប្រាស្រ័យទាក់ទងរបៀបនេះបានដោយរបៀបណា?




- **ការប្រាស្រ័យទាក់ទង**គឺជាការផ្លាស់ប្តូរនូវការគិត គំនិត ឬអារម្មណ៍គ្នាទៅវិញទៅមក។ ការប្រាស្រ័យទាក់ទងមិនមានដែនកំណត់ត្រឹមការនិយាយគ្នា ឬប្រើប្រាស់ពាក្យពេចន៍នោះទេ។ វាអាចជាការទាក់ទងជា**ពាក្យសម្ដី ឬកាយវិការ**។

- ដើម្បីទំនាក់ទំនងគ្នា យើងប្រើពាក្យពេចន៍និយាយ ឬសរសេរ កាយវិការ ភាសាកាយវិការ និងការសម្តែងទឹកមុខ។ ដូចដែលបានបង្ហាញនៅក្នុងដ្យាក្រាមខាងលើ អ្នកផ្ញើបានផ្ញើសារមួយ ហើយអ្នកទទួលបានទទួលបានសារ ឆ្លើយតប ឬព័ត៌មានត្រលប់។ ការឆ្លើយតប ឬព័ត៌មានត្រលប់មិនចាំបាច់តែជាពាក្យនិយាយទេ។ វាអាចជាកាយវិការ ឬជាការសម្តែងកាយវិការ។ ប្រសិនបើការប្រាស្រ័យទាក់ទងមានប្រសិទ្ធិភាព អ្នកទទួលយល់ច្បាស់ពីសារទៅតាមអ្វីដែលអ្នកផ្ញើចង់បញ្ជូនទៅឱ្យ។

- ជំនាញទំនាក់ទំនងមានសារៈសំខាន់ខ្លាំងណាស់ចំពោះការអភិវឌ្ឍន៍ការបញ្ចេញមតិ បុគ្គលិកលក្ខណៈ និងសក្តានុពលរបស់មនុស្ស។ ការប្រាស្រ័យទាក់ទងល្អនាំឱ្យមានការយល់ដឹងល្អរវាងសមាជិករបស់ក្រុមសង្គមណាមួយ។

- ការប្រាស្រ័យទាក់ទងមានប្រសិទ្ធិភាព និងទទួលជោគជ័យគឺនៅពេលអ្នកទទួលបានទទួល និងយល់អំពីសារដែលអ្នកផ្ញើបានផ្ញើនៅក្នុងលក្ខណៈមួយដែលអ្នកផ្ញើមានបំណងឱ្យគេយល់។

- សមត្ថភាពរបស់មនុស្សម្នាក់ក្នុងការជ្រើសរើស និងធ្វើតាមជម្រើសផ្ទាល់របស់ខ្លួននៅក្នុងជីវិតពឹងផ្អែកយ៉ាងខ្លាំងទៅលើថាតើគេអាចប្រាស្រ័យទាក់ទង និងបញ្ចុះបញ្ចូលក្រុមគ្រួសារ មិត្តភក្តិ សហគមន៍ គ្រូបង្រៀន និងនិយោជករបស់ខ្លួនបានដោយជោគជ័យដែរឬអត់។ ដូច្នេះ ការមានជំនាញទំនាក់ទំនងល្អគឺមានសារៈសំខាន់។

### តើទំនាក់ទំនងជាពាក្យសម្ដីជាអ្វី?

- មនុស្សជាច្រើនប្រើប្រាស់ការប្រាស្រ័យទាក់ទងជាពាក្យសម្ដីជាចម្បងក្នុងការរស់នៅប្រចាំថ្ងៃរបស់គេ និងទាក់ទងគ្នាជាមួយគ្រួសារ មិត្តភក្តិ គ្រូបង្រៀន អ្នកលក់ដូរ មនុស្សប្លែកមុខ និងអ្នកដទៃទៀត។ ការប្រាស្រ័យទាក់ទងជាពាក្យសម្ដីមាននៅជុំវិញខ្លួនយើង។ យើងទទួលបានធាតុចូលដូចជាព័ត៌មាន តន្ត្រី ការជូនដំណឹង និងការកម្សាន្តជាច្រើនតាមរយៈទូរទស្សន៍ វិទ្យុ និងសូម្បីទូរសព្ទដៃ។ ការប្រាស្រ័យទាក់ទងជាពាក្យសម្ដីពាក់ព័ន្ធនឹងការប្រើពាក្យសម្ដី ភាសា និងរបៀបបង្ហាញការសន្ទនា ព្រមទាំងការលើកដាក់សំឡេង ហើយតម្រូវឱ្យអ្នកស្ដាប់យល់ពីអ្វីដែលគេកំពុងនិយាយប្រាប់។

លោកគ្រូ អ្នកគ្រូត្រូវចែកឧបសម្ព័ន្ធទី៣បន្ទាប់ពីអនុវត្តសកម្មភាពនេះរួច។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រៀបចំក្រដាសព័ត៌មានដែលមានសរសេរនៅលើក្រដាសនោះជាមុន សម្រាប់សកម្មភាពនេះ។ លោកគ្រូ អ្នកគ្រូត្រូវជ្រើសរើសវត្ថុដែលមានលក្ខណៈសាមញ្ញ និងងាយស្រួលគូរ។
- ពន្យល់លម្អិតពីការប្រាស្រ័យទាក់ទងដោយកាយវិការ។ វាជាការសំខាន់ក្នុងការបញ្ជាក់ថា ជាញឹកញាប់ យើងមិនសូវដឹងពីការប្រាស្រ័យទាក់ទងដោយកាយវិការរបស់យើងទៅកាន់អ្នកដទៃទេប៉ុន្តែខួរក្បាលរបស់យើងទំនងជាយល់ពីការប្រាស្រ័យទាក់ទងដោយកាយវិការដែលអ្នកដទៃគិតសំដៅមកយើង។ ឧទាហរណ៍ យើងមិនចាំបាច់ឱ្យគេ ប្រាប់យើងជានិច្ចកាលថា នរណាម្នាក់ខឹង ឬរីករាយ ឬគិតថារឿងអ្វីមួយដែលគួរឱ្យអស់សំណើចនោះដោយសារតែយើងដឹងតាម រយៈការបញ្ចេញទឹកមុខដែលបង្ហាញពីរឿងទាំងនោះ។

**សារសំខាន់ៗ ៖**

- ការប្រាស្រ័យទាក់ទងគឺការផ្លាស់ប្ដូរនូវការគិត គំនិត ឬអារម្មណ៍គ្នាទៅវិញទៅមក។
- វាអាចជាពាក្យសម្ដី និងជាកាយវិការ។
- ដើម្បីទាក់ទងគ្នាយើងប្រើពាក្យនិយាយ ឬសរសេរ(សំណេរ) កាយវិការ ភាសាកាយវិការ និង ការសម្ដែងទឹកមុខ។

- ការប្រាស្រ័យទាក់ទងមានប្រសិទ្ធភាពនៅពេលដែលអ្នកទទួលបានទទួលសារដែលអ្នកផ្ញើ បានផ្ញើទៅឱ្យទៅតាមការចង់បានរបស់អ្នកផ្ញើ។
- សមត្ថភាពរបស់មនុស្សម្នាក់ក្នុងការជ្រើសរើស និងធ្វើតាមជម្រើសរបស់ខ្លួននៅក្នុងជីវិតពឹងផ្អែកយ៉ាងខ្លាំងទៅលើសមត្ថភាពរបស់គេក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។

**ឧបសម្ព័ន្ធទី៣**

ជំនាញក្នុងការប្រាស្រ័យទាក់ទងជាពាក្យសម្តីប្រកបដោយប្រសិទ្ធភាព ៖

- ការនិយាយពន្យល់ និងសំឡេងច្បាស់លាស់ ៖ និយាយយ៉ាងសាមញ្ញ និងយឺតៗ ដូច្នេះអ្នកស្តាប់អាចយល់បាន។ ជ្រើសរើសពាក្យរបស់ប្អូនដោយយកចិត្តទុកដាក់(ប្រុងប្រយ័ត្ន) និងបញ្ជាក់ឡើងវិញពីព័ត៌មានសំខាន់ៗ។

- សំឡេងល្មម និងអាចស្តាប់បាន៖ សំឡេងរបស់អ្នកត្រូវឮល្មមដើម្បីឱ្យគេអាចស្តាប់បាន។ ដំឡើង ឬបន្ថយសំឡេងរបស់អ្នកដើម្បីឱ្យសមនឹងបរិយាកាសជុំវិញ និងអ្នកស្តាប់។ អ្នកប្រហែលជាត្រូវនិយាយកាន់តែខ្លាំងនៅពេលដែលមានសំឡេងរំខានពីខាងក្រៅ ដូចជាចរាចរណ៍។ មនុស្សចាស់ប្រហែលជាត្រូវការឱ្យអ្នកនិយាយខ្លាំងៗដើម្បីឱ្យពួកគាត់ងាយស្រួលស្តាប់បាន។ ទោះជាយ៉ាងណាក៏ដោយ សំឡេងនិយាយរបស់អ្នកមិនត្រូវឮខ្លាំងពេកទេដែលវាហាក់ដូចជាអ្នកកំពុងតែស្រែក។

- ការលើកដាក់សំឡេង និងការគួសបញ្ជាក់សមស្រប ៖ ចូរមានសុជីវធម៌ និងមានកិរិយាល្អនៅពេលនិយាយ។ វាបង្កើតទំនាក់ទំនងល្អ និងបង្ហាញពីការគោរពចំពោះមនុស្សដែលអ្នកកំពុងមានអន្តរកម្ម(ទាក់ទង)ជាមួយ។

- ការស្តាប់យ៉ាងសកម្ម(ដោយយកចិត្តទុកដាក់) ៖ ការស្តាប់គឺជាជំនាញ(បំណិន)ដ៏សំខាន់មួយក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃព្រោះអ្នកអាចដឹងពីអ្វីដែលអ្នកដទៃចង់បាន និងមានន័យ។ ដើម្បីយល់ដឹងពេញលេញពីសារដែលគេកំពុងបញ្ជូន វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការសួរសំណួរដើម្បីបញ្ជាក់ពីអត្ថន័យ។ វាក៏មានសារៈសំខាន់ដែរក្នុងការបញ្ជាក់ថាមនុស្សម្នាក់ទៀតយល់អំពីសាររបស់អ្នកឬទេ។ អ្នកអាចធ្វើដូច្នេះបានតាមរយៈការសួរសំណួរ។

- ការសួរសំណួរ ឬរៀបឃ្លាឡើងវិញ ៖ ការសួរសំណួរគឺជាឧបករណ៍(វិធី)ដ៏សំខាន់មួយដែលគេប្រើដើម្បីទទួលបានព័ត៌មាន និងការបញ្ជាក់ពីសារមួយ ព្រមទាំងដើម្បីធានាថា អ្នកទទួលយល់នូវអ្វីដែលអ្នកផ្ញើកំពុងនិយាយ។

- ការបរប្រយោគ(និយាយឡើងវិញនូវអ្វីដែលអ្នកដទៃបាននិយាយដោយប្រើពាក្យពេចន៍ផ្ទាល់ខ្លួនដើម្បីបញ្ជាក់ថាយើងយល់ត្រូវ ឬខុស) គឺធ្វើឡើងនៅពេលដែលយើងរៀបឃ្លាឡើងវិញនូវការសន្ទនាមួយទៅជាសេចក្តីសង្ខេបពីអ្វីដែលយើងគិតថាយើងបានស្តាប់ឮ និងយល់។ ការបរប្រយោគអនុញ្ញាតឱ្យអ្នកនិយាយកែតម្រូវការយល់ច្រឡំណាមួយ។

# មេរៀនទី១០ ៖ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព

🕒 **រយៈពេល** ៖ ១៥ នាទី

➲ **វត្ថុបំណង** ៖ ដើម្បីបង្ហាញអំពីការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

- សម្រាប់គ្រូ៖ ក្ដារខៀន និងហ្វឺត។
- សម្រាប់សិស្ស៖ សន្លឹកកិច្ចការក្នុងថ្នាក់របស់សិស្សទំព័រទី៨៤-៨៥។

**ការរៀបចំទុកជាមុន** ៖

- អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- ប្រមូលសម្ភារៈចាំបាច់ទាំងអស់ផ្សេងទៀត។
- សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

## ២. ដំណើរការបង្រៀន

📢 **សេចក្ដីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកមេរៀនដែលពួកគេបានរៀនក្នុងជំពូកមុន។
- អានចំណងជើងមេរៀន ដោយចង្អុលទៅរកចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្ស ទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ហៅសិស្សស្ម័គ្រចិត្ត ២-៣ នាក់ ឱ្យចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុម។
- ជ្រើសរើសសិស្សស្ម័គ្រចិត្តចំនួន ៦ នាក់សម្រាប់ធ្វើសកម្មភាពនេះ។ បន្ទាប់មក លោកគ្រូ អ្នកគ្រូត្រូវបែងចែកសិស្សស្ម័គ្រចិត្តជា ២ ក្រុមដែលក្រុមនីមួយៗមានគ្នា៣នាក់។
- ឱ្យក្រុមនីមួយៗរៀបចំការសម្ដែងមួយសម្រាប់រយៈពេល ២នាទី (មួយរឿងក្នុងមួយក្រុម)។ ក្រុមមួយត្រូវសម្ដែងរឿងមួយស្ដីពីការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ហើយក្រុមផ្សេងទៀតត្រូវ

សម្តែងរឿងស្តីពីការប្រាស្រ័យទាក់ទងដែលគ្មានប្រសិទ្ធភាព។

☞ បន្ទាប់ពីការសម្តែងរឿងទាំង២ចប់ ឱ្យសិស្សទាំងអស់ពិភាក្សាគ្នានៅក្នុងក្រុមដោយផ្អែកលើការសង្កេត និងការរៀនសូត្ររបស់គេ។

*កិច្ចការក្នុងថ្នាក់៖*

☞ បន្ទាប់ពីពិភាក្សាពីការសម្តែងតួរួច ឱ្យសិស្សបើកសន្លឹកកិច្ចការនៅទំព័រទី ៨៤-៨៥។

☞ អាននូវសេចក្តីណែនាំ ដែលពួកគេត្រូវបំពេញតារាងរៀងៗខ្លួន ដោយផ្អែកលើរបៀបដែលពួកគេត្រូវដាក់ពិន្ទុឱ្យខ្លួនឯងចំពោះប្រយោគនីមួយៗ។

☞ បន្ទាប់មកត្រូវប្រាប់សិស្សថា មិនចាំបាច់ចែករំលែកចម្លើយរបស់ពួកគេទៅអ្នកផ្សេងទេ ព្រោះចម្លើយនេះគ្រាន់តែសម្រាប់ឱ្យពួកគេដឹងពីចំណុចល្អរបស់ខ្លួននៅពេលធ្វើការប្រាស្រ័យទាក់ទង និងពីអ្វីដែលពួកគេអាចកែប្រែបាន។

☞ ប្រាប់សិស្សថា ពួកគេមានពេល៥ ទៅ ៧នាទីក្នុងការបំពេញតារាងនេះ។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

**◇ ដើម្បីក្លាយជាអ្នកដែលមានការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ៖**

- គិត(ឱ្យបានល្អិតល្អន់)មុននឹងនិយាយ ធ្វើសកម្មភាព បង្ហាញអាកប្បកិរិយា ឬធ្វើកាយវិការ។ តើយើងកំពុងព្យាយាមធ្វើការប្រាស្រ័យទាក់ទងពីរឿងអ្វី? តើត្រូវប្រើជាភាសាអ្វីសម្រាប់ការប្រាស្រ័យទាក់ទង? តើយើងកំពុងប្រាស្រ័យទាក់ទងពីអ្វី? តើវិធីសាស្ត្រអ្វីដែលល្អបំផុតសម្រាប់ការប្រាស្រ័យទាក់ទង ឬធ្វើអន្តរកម្មនៅក្នុងស្ថានភាពដែលគេផ្តល់ឱ្យនោះ?

- ភាពច្បាស់លាស់នៃការប្រាស្រ័យទាក់ទង ព្រមទាំងការជ្រើសរើសពាក្យមានសារៈសំខាន់ណាស់។

- ការប្រាស្រ័យទាក់ទងពេញលេញ(ចប់សព្វគ្រប់) ពោលគឺមិនមានអ្វីដែលមិនពេញលេញ ឬនៅសេសសល់ ឬទុកចោលផ្នែកណាមួយ ក៏មានសារៈសំខាន់ដែរ។

**◇ ការប្រាស្រ័យទាក់ទងគឺជាជំនាញមួយដែលគេអាចរៀនសូត្រ និងធ្វើឱ្យប្រសើរឡើង (កែលម្អ) បានហើយវាតម្រូវឱ្យមានការអនុវត្តដើម្បីអភិវឌ្ឍជំនាញនេះដើម្បីក្លាយជាអ្នកដែលមានការប្រាស្រ័យទាក់ទងល្អម្នាក់ៗ**

- ត្រូវដឹងពីទីកន្លែង ពេលវេលា និងស្ថានភាព (ឧទាហរណ៍ ៖ សាលាឃុំ ពេលព្រឹក ជិតដល់រដូវចូលឆ្នាំ)។

- ត្រូវកំណត់វត្ថុបំណង និងមូលហេតុសម្រាប់ការប្រាស្រ័យទាក់ទង។
- ការប្រាស្រ័យទាក់ទងទាមទារភាពច្បាស់លាស់ និងទំនុកចិត្តដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។
- ការអត់ធ្មត់ ភាពនឹងនរ និងការយល់ដឹងថា មនុស្សខុសគ្នាមានទស្សនៈខុសគ្នា ក៏ដូចជាមានសមត្ថភាពខុសគ្នាក្នុងការនិយាយ និងការស្តាប់ មានសារៈសំខាន់ណាស់។
- ត្រូវដឹងពីស្ថានភាពទឹកចិត្តរបស់អ្នកដទៃដែលពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទង និងអន្តរកម្ម។ ឧទាហរណ៍ បុគ្គលម្នាក់ដែលកំពុងមិនសប្បាយចិត្ត ឬខ្វាយខ្វល់ប្រហែលជាស្តាប់មិនបាននូវចំណុចជាច្រើនដែលគេកំពុងប្រាស្រ័យទាក់ទងជាមួយគាត់។

**ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពក៏រួមបញ្ចូលនូវជំនាញស្តាប់ដ៏ល្អដែរ ៖**

- ការស្តាប់យ៉ាងសកម្ម និងដោយយកចិត្តទុកដាក់មានសារៈសំខាន់ដូចជាការនិយាយឱ្យបានច្បាស់លាស់ និងដោយមានទំនុកចិត្តដែរ។
- ជារឿយៗ អ្នកស្តាប់តែងតែរវល់គិតពីអ្វីដែលគេនឹងនិយាយ ហើយប្រហែលជាមិនយកចិត្តទុកដាក់ចំពោះអ្វីដែលគេកំពុងប្រាស្រ័យទាក់ទងជាមួយខ្លួនទេ។ ចំណុចនេះមានន័យថា សារដែលគេកំពុងបញ្ជូនត្រូវបាត់បង់ និងមិនបានទទួលតាមការដែលគេចង់បានឡើយ។ ការណ៍នេះអាចបង្កឱ្យមានការយល់ខុស និងការយល់ច្រឡំ។
- ការឆ្លើយតបទៅនឹងការប្រាស្រ័យទាក់ទងមួយមិនត្រូវធ្វើឡើងតាមរយៈការនិយាយកាត់ អ្នកដទៃឡើយ។ គេចាំបាច់ត្រូវគិតពីការឆ្លើយតប និងបង្ហាញនៅពេលដែលអ្នកដទៃបានត្រៀមខ្លួនស្តាប់រួចហើយ ពោលគឺនៅពេលដែលពួកគេបានបញ្ចប់ការប្រាស្រ័យទាក់ទងរបស់ខ្លួនហើយ។

ទោះបីជាមានផ្នត់គំនិតជាច្រើនពីរបៀបដែលក្មេងស្រី និងស្ត្រីត្រូវប្រព្រឹត្ត និងប្រាស្រ័យទាក់ទងក៏ដោយ ក៏វាមានសារៈសំខាន់ដែរក្នុងការបង្កើតភាពក្លាហាន ការបង្ហាញគំនិតយោបល់នានា និងការប្រាស្រ័យទាក់ទងដោយមានទំនុកចិត្ត និងច្បាស់លាស់។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូ៖

- ក្នុងពេលពិភាក្សា បន្ទាប់ពីសម្តែងរួចត្រូវលើកទឹកចិត្តសិស្សឱ្យអនុវត្តតាមគោលការណ៍ណែនាំ

ស្ដីពីការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពនៅពេលពួកគេពិភាក្សាពីចំណុចផ្សេងៗ។ ដូច្នេះ លោកគ្រូ អ្នកគ្រូត្រូវលើកឧទាហរណ៍មួយចំនួនដើម្បីបញ្ជាក់ពីការនិយាយកាត់ ឬការប្រាស្រ័យទាក់ទងមិនពេញលេញ ឬភាពច្បាស់លាស់ល្អ និងការស្ដាប់យ៉ាងសកម្ម(ដោយយកចិត្តទុកដាក់)។ តាមរយៈការធ្វើបែបនេះ សិស្សអាចអនុវត្តបាននូវអ្វីដែលពួកគេកំពុងសិក្សា ទោះបីជាពួកគេកំពុងសិក្សាក៏ដោយ។

✉ **សារសំខាន់ៗ ៖**

- ការប្រាស្រ័យទាក់ទង គឺជាដំណើរការនៃការផ្ញើ(បញ្ជូន) និងទទួលព័ត៌មាន ឬគំនិតតាមរយៈពាក្យសម្ដី និងកាយវិការ។
- មនុស្សប្រាស្រ័យទាក់គ្នាដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ ផ្ដល់ព័ត៌មាន បង្ហាញអារម្មណ៍ ដោះស្រាយបញ្ហា ជជែកវែកញែក ឬជជែកតវ៉ា ហើយជារឿយៗគ្រាន់តែសម្រាប់ការកម្សាន្តប៉ុណ្ណោះ។
- ការប្រាស្រ័យទាក់ទងគឺជាផ្នែកដ៏សំខាន់នៃជីវិតរបស់យើង ហើយគុណភាពនៃការប្រាស្រ័យទាក់ទងដែលយើងអាចមានជាមួយមនុស្សជុំវិញខ្លួន ជាញឹកញាប់ កំណត់ពីគុណភាពនៃទំនាក់ទំនងដែលយើងមានជាមួយអ្នកទាំងនោះ។

# មេរៀនទី១១ ៖ ការប្រាស្រ័យទាក់ទងដោយកាយវិការ[១៧]

🕒 រយៈពេល ៖ ៣០ នាទី

➲ **វត្ថុបំណង ៖** ដើម្បីទទួលបានការយល់ដឹងពីការប្រាស្រ័យទាក់ទងដោយប្រើកាយវិការ។

## ១.ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

☞ សម្រាប់គ្រូ៖ ក្រដាសព័ត៌មាន (ក្រដាសតូចៗដែលមានសរសេរអក្សរ) ក្រដាសតារាង ក្តារខៀន និងហ្វឺត ឬក្តារខៀន និងដីស និងឯកសារថតចម្លងឧបសម្ព័ន្ធទី៨។

☞ សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន ៖**

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ អាន និងថតចម្លងឧបសម្ព័ន្ធទី៨ សម្រាប់ចែកជូនសិស្ស។

☞ ប្រមូលសម្ភារៈចាំបាច់ទាំងអស់ផ្សេងទៀត។

☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

☞ ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។

☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកមេរៀនដែលពួកគេបានរៀនក្នុងជំពូកមុន។

☞ អានចំណងជើងមេរៀន ដោយចង្អុលទៅរកចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្ស ទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ហៅសិស្សស្ម័គ្រចិត្ត ២-៣ នាក់ ឱ្យចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុម។

☞ បន្ទាប់មកបែងចែកសិស្សជាគូៗ។

---

[១៧] Standard Chartered,. (២០០៩). *គោលការណ៍ណែនាំសកម្មភាពគោលដៅ*។ មូលនិធិ Naz។

☞ ឱ្យសិស្សម្នាក់នៅក្នុងក្រុមនីមួយៗចែករំលែកពីរឿងរ៉ាវជាក់ស្តែងខ្លីៗមួយ (ជារឿងកំប្លែង ឬគួរឱ្យចាប់អារម្មណ៍) ក្នុងជីវិតផ្ទាល់របស់គេ។ ឱ្យពេលសិស្សចំនួន៣នាទីដើម្បីគិតមុនពេលចាប់ផ្តើមអនុវត្តចែករំលែករឿងនោះ។

☞ រៀងរាល់១នាទីម្តង ឱ្យសិស្សផ្លាស់ប្តូរទីតាំងខុសៗគ្នា និងទៅតាមលំដាប់ដូចខាងក្រោម ៖ ឈរទល់មុខគ្នា ឈរទល់ខ្នងគ្នា អ្នកនិយាយឈរនិយាយ ហើយអ្នកស្តាប់អង្គុយស្តាប់ និងស្ថិតនៅក្នុងមុំ៩០ដឺក្រេពីគ្នា។

☞ ចែកឧបសម្ព័ន្ធទី៤ ឱ្យសិស្សនៅចុងបញ្ចប់នៃមេរៀននេះ។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

- តើទីតាំងណាដែលមានភាពងាយស្រួលបំផុតសម្រាប់អ្នកនិយាយ? ហេតុអ្វី?
- តើទីតាំងណាដែលមានភាពងាយស្រួលបំផុតសម្រាប់អ្នកស្តាប់? ហេតុអ្វី?
- គន្លឹះក្នុងការប្រាស្រ័យទាក់ទងជាពាក្យសម្តី ឬជាកាយវិការ (ឧបសម្ព័ន្ធទី៤ នៅចុងបញ្ចប់នៃមេរៀននេះ) ហើយត្រូវចងចាំក្នុងចិត្តនូវបរិបទផ្នែកវប្បធម៌របស់សិស្ស។
- ការប្រាស្រ័យទាក់ទងអាចជាពាក្យសម្តី ឬជាកាយវិការ។ ការប្រាស្រ័យទាក់ទងជាប់ពាក់ព័ន្ធលើសពីពាក្យសម្តីទៅទៀត។ វាក៏រួមបញ្ចូលដែរនូវភាសាកាយវិការ ការលើកដាក់សំឡេង កាយវិការ និងការបង្ហាញទឹកមុខ។ ការប្រើភាសាសញ្ញា និងកាយវិញ្ញាណដើម្បីបង្ហាញ និងប៉ះ(ស្ទាប)ក៏ជារបៀបនៃការប្រាស្រ័យទាក់ទងដ៏សំខាន់ដែរ។

**តើការប្រាស្រ័យទាក់ទងដោយកាយវិការជាអ្វី?**

- ការប្រាស្រ័យទាក់ទងដោយកាយវិការរួមបញ្ចូលនូវលទ្ធភាពជាច្រើនលើសពីការនិយាយពន្យល់ជាពាក្យសម្តី និងប្រយោគទៅទៀត ហើយវារាប់បញ្ចូលទាំងឥរិយាបថ ការបង្ហាញទឹកមុខ សកម្មភាព សំឡេង ការធ្វើត្រាប់តាម ចលនារាងកាយ កាយវិការ និងសកម្មភាពផ្សេងៗជាច្រើនទៀត។ គ្រាន់តែការបង្ហាញទឹកមុខតែម៉្យាងប៉ុណ្ណោះអាចប្រាស្រ័យទាក់ទងនូវរឿងរ៉ាវផ្សេងៗជាច្រើនជាមួយអ្នកដទៃបានដែរមានដូចជាអារម្មណ៍ កម្រិតនៃទំនុកចិត្ត ឥរិយាបថរបស់យើង និងថាតើយើងធុញទ្រាន់ ឬចាប់អារម្មណ៍។ ត្រង់ចំណុចនេះ ភាសាសញ្ញាគឺជាប្រធានបទដែលគួរឱ្យចាប់អារម្មណ៍មួយព្រោះវាមាននៅក្នុងប្រភេទនៃការប្រាស្រ័យទាក់ទងទាំង២ ពោល

គឺ ៖ នៅពេលដែលពាក្យដែលគេត្រូវប្រើដើម្បីប្រាស្រ័យទាក់ទងត្រូវបានគេបង្ហាញតាមរយៈភាសាសញ្ញា និងជាកាយវិការ នៅពេលដែលគេកំពុងប្រាស្រ័យទាក់ទងពីអារម្មណ៍ ឬសកម្មភាព ដូចជាការចង្អុលប្រាប់ទិសដៅជាក់លាក់ណាមួយ។ តន្ត្រី ការរាំ ការគូសវាស និងការគូរគំនូរក៏ជាមធ្យោបាយនៃការប្រាស្រ័យទាក់ទងដោយកាយវិការដែរ។

**គន្លឹះសម្រាប់គ្រូបង្រៀន ៖**

- សារសំខាន់ដែលលោកគ្រូ អ្នកគ្រូត្រូវលើកឡើងតាមរយៈការពិភាក្សាគឺ ការប្រាស្រ័យទាក់ទងកើតមានឡើងតាមមធ្យោបាយជាច្រើន ហើយយើងត្រូវតែដឹងឱ្យបានច្រើនជាងពាក្យសម្ដីដែលយើងផ្លាស់ប្ដូរគ្នានៅក្នុងអន្តរកម្មរបស់យើងជាមួយមនុស្សដទៃទៀត។

**សារសំខាន់ៗ ៖**

- ការប្រាស្រ័យទាក់ទងដោយកាយវិការមានអត្ថន័យដ៏ធំធេងណាស់ ហើយវារាប់បញ្ចូលនូវរឿងរ៉ាវផ្សេងៗជាច្រើនក្នុងចំណោមការលើកដាក់សំឡេង សំឡេងដែលមនុស្សម្នាក់កំពុងនិយាយ (ស្រែក ខ្សឹប សំឡេងធម្មតា) ការបង្ហាញទឹកមុខ (ញញឹម ការចងចិញ្ចើម ។ល។) ក្រសែភ្នែក ឥរិយាបថរបស់រាងកាយ និងការធ្វើចលនា (អង្គុយ ឈរ ដើរចុះឡើង ឱនទៅមុខ ឬផ្អែកខ្នងមកក្រោយ) ការប៉ះ កាយវិការ និងសកម្មភាព។

**ឧបសម្ព័ន្ធទី ៨**

ការណែនាំ ឬគន្លឹះសម្រាប់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ៖

- ការប្រាស្រ័យទាក់ទងច្បាស់លាស់កើតមានឡើងនៅពេលដែលអ្នកទទួលយល់ច្បាស់ពីសារដែលអ្នកផ្ញើចង់ផ្ញើមកឱ្យ។

- មនុស្សប្រាស្រ័យទាក់ទងគ្នាដោយប្រើទាំងពាក្យសម្ដី និងកាយវិការ។

- វាមានសារៈសំខាន់ក្នុងការពិនិត្យមើលថា តើគេយល់ច្បាស់ពីសារ ជាពិសេសនៅពេលដែលសារនោះទាក់ទងនឹងប្រធានបទដែលពិបាក ឬផ្អែកមនោសញ្ចេតនា។

- គ្រប់ស្ថានភាពទាំងអស់ បច្ចេកទេសមួយក្នុងចំណោមបច្ចេកទេសសំខាន់ៗបំផុតសម្រាប់ការប្រាស្រ័យទាក់ទងល្អគឺការស្ដាប់បានល្អ(ច្បាស់លាស់) និងដោយការគោរព។ ទោះជាយ៉ាងណាក៏ដោយ បទដ្ឋានផ្អែកវប្បធម៌មានឥទ្ធិពលទៅលើអ្វីដែលជាប្រភេទនៃការប្រាស្រ័យទាក់ទងដែលគេចាត់ទុកថាសមស្រប។

- ការស្ដាប់ដោយយកចិត្តទុកដាក់(សកម្ម) និងមិនវិនិច្ឆ័យអាចធ្វើឱ្យការប្រាស្រ័យទាក់ទងកាន់តែមានភាពប្រសើរឡើង។ នៅពេលអ្នកកំពុងស្ដាប់ ៖

  ១. ចូរព្យាយាមយល់ពីមនុស្ស(ផ្សេងៗទៀត)។
  ២.ចូរនិយាយពីរឿងផ្សេងៗដែលបញ្ជាក់ពីការយល់របស់អ្នកចំពោះអ្វីមួយដែលអ្នកផ្សេងទៀតនិយាយដូចជា «ខ្ញុំអាចយល់ពីអារម្មណ៍របស់អ្នក» ឬ «ចំណុចល្អ» ។
  ៣. ចូរប្រើក្រសែភ្នែក។
  ៤. ចូរផ្ដល់នូវសញ្ញាវិជ្ជមានដូចជាញញឹម ងក់ក្បាល និងសួរបញ្ជាក់ ឬបំភ្លឺ។

- អាកប្បកិរិយាជាក់លាក់មួយចំនួនអាចធ្វើឱ្យការប្រាស្រ័យទាក់ទងជាពាក្យសម្ដីមានភាពល្អប្រសើរឡើង។ អាកប្បកិរិយាដែលមានលក្ខណៈស្ថាបនាទូទៅរួមមាន ៖ ការទទួលស្គាល់ថាមនុស្សទាំងអស់គ្នាមានសិទ្ធិបង្ហាញអារម្មណ៍ និងបញ្ចេញមតិរបស់ខ្លួន ការបញ្ជាក់យ៉ាងច្បាស់តាមដែលអាចធ្វើទៅបាននូវអ្វីដែលអ្នកចង់បាន ឬធ្វើ ឬអ្វីដែលអ្នកមិនចង់បាន / ធ្វើ និងការជួយរកដំណោះស្រាយដែលអាចធ្វើទៅបានសម្រាប់បញ្ហានានា។

- ចៀសវាងការបង្គាប់បញ្ជា ការវិនិច្ឆ័យ ឬការត្រួតត្រាខ្លាំងពេក។

# មេរៀនទី១២ ៖ យេនឌ័រ និងការប្រាស្រ័យទាក់ទង[១៨]

🕒 រយៈពេល ៖ ៤៥ នាទី

➲ **វត្ថុបំណង** ៖ ដើម្បីស្វែងយល់ពីរបៀបដែលថាមវន្តនៃយេនឌ័រ និងអំណាចមានផលជះដល់សមត្ថភាពប្រាស្រ័យទាក់ទង។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

- ☞ សម្រាប់គ្រូ៖ ក្តារខៀន និងដីស ឬក្រដាសផ្ទាំងធំ និងហ្វឺតលុបមិនជ្រះ ស្កុត និងកន្ត្រៃ។
- ☞ សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន ៖**

- ☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- ☞ រៀបចំតារាងសម្រាប់ការពិភាក្សារបស់សិស្ស។
- ☞ អានន្ធរក្របខណ្ឌចំណេះដឹងនៃមេរៀន។
- ☞ ប្រមូលសម្ភារៈចាំបាច់ទាំងអស់។
- ☞ សរសេរចំណងជើងមេរៀននៅលើក្តារខៀន។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ☞ ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។
- ☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកមេរៀនដែលពួកគេបានរៀនក្នុងជំពូកមុន។
- ☞ អានចំណងជើងមេរៀន ដោយចង្អុលទៅរកចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្ស ទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ហៅសិស្សស្ម័គ្រចិត្ត ២-៣ នាក់ ឱ្យចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុម។
- ☞ បន្ទាប់មកឱ្យសិស្សស្ម័គ្រចិត្ត២នាក់សម្តែងរឿងខ្លីមួយស្តីពីការសន្ទនារវាងបងប្រុស និងប្អូនស្រី។

---

[១៨] CRW,. (២០១៦). *កម្មវិធី តែស ប្រនហ្ស៍ សម្រាប់ក្មេងស្រីពេញវ័យ* Gap Inc

ក្នុងពេលសម្តែង តួអង្គទាំង២ត្រូវនិយាយគ្នាពីប្រធានបទមួយនៃជម្រើសរបស់ពួកគេរយៈពេលប្រហែល២នាទី។ ប្រធានបទស្នើ៖

- ការបែងចែកកិច្ចការផ្ទះ
- ការចរចាអំពីកម្មវិធីទូរទស្សន៍ដែលត្រូវមើល

☞ ឱ្យពេល ៥ នាទីដល់សិស្សស្ម័គ្រចិត្តដើម្បីរៀបចំការសម្តែងរបស់ខ្លួន។ ពួកគេត្រូវរៀបចំការសម្តែងនេះនៅកន្លែងឆ្ងាយពីក្រុមធំ។ ទន្ទឹមនឹងនេះ លោកគ្រូ អ្នកគ្រូអាចសុំឱ្យសិស្សរំឭកពីការរៀនសូត្ររបស់ខ្លួនពីមេរៀនមុនៗ។

☞ ណែនាំសិស្សឱ្យកំណត់ថាតើនរណាដែលពួកគេគិតថា ត្រូវសម្តែងតួជាក្មេងប្រុស និងនរណាជាក្មេងស្រីក្នុងចំណោមអ្នកស្ម័គ្រចិត្តទាំង២ដែលត្រូវសម្តែងតួ។

☞ ដឹកនាំការពិភាក្សាបន្ទាប់ពីការសម្តែងតួចប់ ដោយផ្អែកលើតារាងសង្កេត(ដែលលោកគ្រូ អ្នកគ្រូបានចែកឱ្យសិស្សជាមុន)។ លោកគ្រូ អ្នកគ្រូត្រូវឱ្យសិស្សធ្វើការឆ្លុះបញ្ចាំងពីរបៀបដែលការប្រាស្រ័យទាក់ទងរបស់«ក្មេងប្រុស»នៅក្នុងការសម្តែងមានភាពខុសគ្នាពីប្រាស្រ័យទាក់ទងរបស់«ក្មេងស្រី»។ លោកគ្រូ អ្នកគ្រូត្រូវសរសេរពាក្យគន្លឹះ ឬពាក្យសំខាន់ៗដែលបានពីចម្លើយរបស់សិស្សនៅក្នុងផ្នែកនៃតារាងដែលសមស្រប។

**<u>តារាងសង្កេត ៖</u>**

| ចំណុចសង្កេត | ក្មេងប្រុស | ក្មេងស្រី |
|---|---|---|
| ភាពខុសគ្នាចំពោះសំឡេងក្នុងការប្រាស្រ័យទាក់ទង | | |
| ភាសាកាយវិការ | | |
| ការសួរសំណួរ | | |
| ឥរិយាបថ | | |
| ជម្រើសប្រធានបទ | | |

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

◈ ការសម្តែងបែបនេះមានមូលដ្ឋានគ្រឹះក្នុងការសង្កេតទូទៅ និងអនុវត្តតាមដានតួនាទីយេនឌ័រ ដែលសង្គមអាចទទួលយកបាន។ អាចមានអ្នកដែលបំពានផ្ទត់គំនិតយេនឌ័រ ដោយមានស្ត្រីខ្លះដែលមាន

ភាពក្លាហាន និងកាច និងបុរសខ្លះដែលនិយាយទន់ភ្លន់ និងអៀនខ្មាស។ ការរៀនសូត្រពីដំបូងរបស់មនុស្សម្នាក់ពីការរំពឹងទុកផ្នែកយេនឌ័ររបស់សង្គមមានផលជះដល់ទំនុកចិត្ត និងរបៀបប្រាស្រ័យទាក់ទងរបស់គេ ។

- តើអ្នកគិតថា វាមិនមានបញ្ហាអ្វីទេឬដែលធ្វើខុសប្លែកពីបទដ្ឋាន? តើអ្នកគិតថាវាអាចធ្វើទៅបានទេក្នុងការទទួលយកបុរសដែលខ្មាសអៀន និងស្ត្រីដែលកោងកាច?

- ហេតុអ្វីបានជាមានភាពខុសគ្នាមួយចំពោះរបៀបនិយាយរបស់បុរស និងស្ត្រី ឬរបស់ក្មេងប្រុស និងក្មេងស្រី? ហេតុអ្វីបានជាមានភាពខុសគ្នាមួយចំពោះប្រភេទនៃប្រធានបទដែលពួកគេជជែកគ្នា?

- មានរបៀបប្រាស្រ័យទាក់ទងជាផ្នត់គំនិតផ្នែកយេនឌ័រ ក៏ដូចជាមានអ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ។
  - ដំណើរនៃការបង្រៀនពីសង្គមរំពឹងទុកថា បុរសនឹងមានអាកប្បកិរិយាជាក់លាក់ ហើយជារឿយៗ កំណត់ពីរបៀបដែលពួកគេធ្វើការប្រាស្រ័យទាក់ទង។ ឧទាហរណ៍ គេបង្រៀនបុរសឱ្យបើកចំហរ(ស្មោះត្រង់) និងអង់អាច ហើយតែងតែរំពឹងទុកថាស្ត្រីមានភាពស្ងៀមស្ងាត់ និងស្តាប់បង្គាប់។

- តើមានភាពខុសគ្នាចំពោះភាសាកាយវិការរបស់បុរស និងស្ត្រីដែរឬទេ? ហើយតើភាពខុសគ្នានេះមានផលជះទៅលើប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងដែរឬទេ?

- ការបង្រៀនពីសង្គមមានន័យថា បុរស និងស្ត្រី ជាញឹកញាប់មានលក្ខណៈខុសគ្នាចំពោះរបៀបប្រាស្រ័យទាក់ទងដោយការយវិការ។ ជារឿយៗ បុរសត្រូវមានមោទនភាព និងទំនុកចិត្តដោយពើងទ្រូងហើយត្រូវរក្សាក្រសែភ្នែកឱ្យបានល្អនៅពេលដែលស្ត្រីអាចចៀសវាងការប្រើក្រសែភ្នែក ហើយក៏អាចខ្វះទំនុកចិត្តដែរ។ ប្រសិនបើស្ត្រីម្នាក់និយាយច្រើនពេក នាងនឹងមានភាពលេចធ្លោដោយសារមិនចុះសម្រុងក្នុងសង្គម។ ប្រសិនបើនាងមានភាពខ្មាសអៀន ហើយធ្វើតាមអ្វីដែលគេប្រាប់ឱ្យនាងធ្វើ នោះគេនឹងទទួលស្គាល់នាងថាជាអ្នកគោរពតាមបទដ្ឋានយេនឌ័រ។ ជារឿយៗ ការណ៍នេះជារឿងពិតនៅក្នុងគ្រួសារ ក៏ដូចជានៅខាងក្រៅដែរ ពោលគឺនៅក្នុងសង្គម និងទីសាធារណៈ ព្រមទាំងកន្លែងធ្វើការ។ រឿងរ៉ាវទាំងអស់នេះប៉ះពាល់ដល់ទំនុកចិត្តទូទៅរបស់មនុស្សម្នាក់ៗ។ នៅពេលធំឡើង បុគ្គលនានាអាចទទួលយកបន្តិចម្តងៗនូវឥរិយាបថជាក់លាក់មួយទាក់ទងនឹងការអង្គុយការដើរ និងការនិយាយស្តីដើម្បីឱ្យមានភាពអាចទទួលយកបានច្រើនថែមទៀត។ ឧទាហរណ៍ ក្មេងស្រីជាច្រើនដើរនៅតាមដងផ្លូវដោយសម្លឹងមើលចុះក្រោម ហើយនិយាយសំឡេងខ្សាវៗដើម្បីចៀស

វាងការចាប់អារម្មណ៍ពីអ្វីដែលគេមិនត្រូវការ។ ក្មេងស្រីទាំងនោះនឹងចៀសវាងការប្រើក្រសែភ្នែកក្នុងករណីដែលមានការសួរនាំបែបបៀតបៀន។

- តួនាទីយេនឌ័រមានផលជះទៅលើសេរីភាពដែលតាមរយៈនោះមនុស្សម្នាក់មានលទ្ធភាពប្រាស្រ័យទាក់ទង(បង្ហាញ)ពីគំនិត និងអារម្មណ៍។

- ការរំពឹងទុកផ្នែកយេនឌ័រមានផលប៉ះពាល់អវិជ្ជមានដល់ស្ត្រី និងក្មេងស្រីដែលជារឿយៗ ស្ទាក់ស្ទើរក្នុងការនិយាយស្តី និងបញ្ចេញគំនិត បំណងប្រាថ្នា ជម្រើស ឬការសម្រេចចិត្តសម្រាប់ខ្លួនឯង។ ការអប់រំ ការស្វែងរកអាជីព ការជ្រើសរើសជីវិតអាពាហ៍ពិពាហ៍ គ្រួសារ និងជីវិតក្លាយជាប្រធានបទដែលមនុស្សផ្សេងទៀតធ្វើការសម្រេចចិត្តជំនួសក្មេងស្រី ឬស្ត្រីដោយសារតែការរើសអើងយេនឌ័រ និងអសមត្ថភាពរបស់ក្មេងស្រី និងស្ត្រីជាច្រើនក្នុងការប្រាស្រ័យទាក់ទង និងចរចាប្រកបដោយប្រសិទ្ធភាព។

- ជំនាញប្រាស្រ័យទាក់ទងដ៏រឹងមាំ និងមានប្រសិទ្ធភាពអាចជួយបុគ្គលម្នាក់ៗឱ្យបង្ហាញពីគំនិតតម្រូវការ និងយោបល់របស់ខ្លួនដោយសេរី និងមានទំនុកចិត្ត។

សេចក្តីសង្ខេប ៖

- ការប្រាស្រ័យទាក់ទង គឺជាដំណើរការនៃការបញ្ជូន និងទទួលព័ត៌មានដោយប្រើពាក្យសម្តី និងកាយវិការ។

- មនុស្សប្រាស្រ័យទាក់ទងគ្នាដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍។ ការប្រាស្រ័យទាក់ទងគឺជាជំនាញមួយ ហើយបង្កើតមូលដ្ឋានសម្រាប់ការទំនាក់ទំនងទាំងអស់។ គុណភាពនៃការប្រាស្រ័យទាក់ទង ជាទូទៅកំណត់ពីគុណភាពនៃទំនាក់ទំនង។

- ការប្រាស្រ័យទាក់ទងជាពាក្យសម្តីគឺនៅពេលដែលមនុស្សម្នាក់និយាយ ហើយអ្នកដទៃស្តាប់ និងឆ្លើយតប។ ការយល់ច្រឡំ និងបញ្ហាក្នុងការប្រាស្រ័យទាក់ទងអាចកើតមានឡើង ប្រសិនបើគេមិនដឹង ឬមិនគោរពតាមគោលការណ៍ណែនាំសម្រាប់ការប្រាស្រ័យទាក់ទងល្អ ដូចជាការស្តាប់ដោយយកចិត្តទុកដាក់ ការផ្តល់ព័ត៌មានពេញលេញ ឬប្រតិកម្ម និងការឆ្លើយតបដោយពុំបានគិត។

- កត្តាសំខាន់ៗមួយចំនួនក្នុងចំណោមកត្តាសំខាន់ៗផ្សេងៗទៀតដែលប៉ះពាល់លើការប្រាស្រ័យទាក់ទងមាន ៖ ពេលវេលា ស្ថានភាព កាលៈទេសៈ កត្តាខាងក្នុង ដូចជាភាពតានតឹង ការចប់អារម្មណ៍ និងកត្តាខាងក្រៅ ដូចជាសំឡេង ទីកន្លែង វត្តមានរបស់អ្នកដទៃ ការឆ្លើយតបរបស់អ្នកទទួល។ល។

ដំណើរការនៃការបង្រៀនពីសង្គម បទដ្ឋានយេនឌ័រ និងផ្នត់គំនិត ជារឿយៗក៏បង្រៀនពីរបៀប និងសមត្ថភាពនៃការប្រាស្រ័យទាក់ទងរបស់បុគ្គលម្នាក់ៗដែរ។ ទោះជាយ៉ាងណាក៏ដោយ ជំនាញប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពអាចជួយបង្កើនសមត្ថភាព ពោលគឺពង្រឹងអារម្មណ៍នៃការឱ្យតម្លៃខ្លួនឯង និងភាពជឿទុកចិត្តលើខ្លួនឯងរបស់បុគ្គលម្នាក់ៗ។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- មានតារាងសង្កេតនៅក្នុងដៃ និងបិទវានៅលើក្ដារខៀន។ គំរូចម្លើយមាននៅក្នុងតារាងជាឧទាហរណ៍ខាងក្រោម។ ចំណុចទាំងនេះបង្ហាញពីប្រភេទនៃការឆ្លើយតបរបស់សិស្សដែលគេរំពឹងទុក ឬចាំបាច់ត្រូវតែឲ្យពួកគេឆ្លើយ។

| ចំណុចនៃការសង្កេត | ក្មេងប្រុស | ក្មេងស្រី |
|---|---|---|
| ភាពខុសគ្នាចំពោះសំឡេងក្នុងការប្រាស្រ័យទាក់ទង | មានទំនុកចិត្ត ឮខ្លាំងធ្ងន់ៗ | ទន់ភ្លន់ មានសុជីវធម៌ មិនសូវច្បាស់ |
| ភាសាកាយវិការ | ក្លាហាន កោងកាច | ខ្មាសអៀន ភិតភ័យ មិនតបត |
| ការសួរសំណួរ | សួរសំណួរច្រើន | ផ្តល់តែចម្លើយប៉ុណ្ណោះ មិនសួរសំណួរទេ |
| ឥរិយាបថ | គ្របដណ្តប់លើគេ មិនយកចិត្តទុកដាក់ | យកចិត្តទុកដាក់ ស្តាប់បង្គាប់ |
| ជម្រើសប្រធានបទ | គិតតែពីខ្លួនឯង លុយ នយោបាយ មិត្តភក្តិ | គិតពីគ្រួសារ ឪពុកម្តាយ ការអប់រំរបស់កូន សុខភាព ការងារផ្ទះ |

លោកគ្រូ អ្នកគ្រូត្រូវលើកទឹកចិត្តសិស្សឱ្យចាប់ផ្តើមធ្វើលំហាត់នេះដោយសួរពួកគេនូវសំណួរនានាដូចខាងក្រោម ៖

- តើភាពខុសគ្នាអ្វីខ្លះរវាងភាសាកាយវិការរបស់បុរស និងស្ត្រី?
- តើភាសាកាយវិការរបស់ក្មេងប្រុសមានលក្ខណៈខុសគ្នាពីក្មេងស្រីយ៉ាងដូចម្តេច? ហេតុអ្វីបានជាអ្នកគិតដូច្នេះ?
- តើនរណាជាអ្នកមានយោបល់ច្រើនជាងគេក្នុងការសន្ទនា? ហេតុអ្វីបានជានិយាយច្រើន ឬ

ហេតុអ្វីបានជានិយាយតិច?

- តើបុរស និងស្ត្រីមានចំនួន និងប្រភេទសំណួរដូចគ្នាដែរឬទេ? ហេតុអ្វីដូចគ្នា? ហេតុអ្វីមិនដូចគ្នា?
- តើមានចំណុចអ្វីខ្លះដែលអ្នកធ្លាប់ស្តាប់ឮ ឬត្រូវបានគេប្រាប់ពីរបៀបដែលក្មេងស្រីត្រូវនិយាយ?

**សារសំខាន់ៗ ៖**

- ផ្នត់គំនិតផ្នែកយេនឌ័រប៉ះពាល់ដល់លក្ខណៈដែលគេអនុញ្ញាតឱ្យបុរស និងស្ត្រីជ្រើសរើសការបង្ហាញពីខ្លួនឯង។ វិធីមួយក្នុងការឆ្លងកាត់ឧបសគ្គនេះ គឺត្រូវធ្វើខ្លួនជាអ្នកប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធិភាពនិងមានជំនាញ ព្រមទាំងជាអ្នកដែលច្បាស់លាស់ និងមានទំនុកចិត្ត។
- ឧបសគ្គបែបនេះកើតឡើងដោយសារសង្គមយេនឌ័រ ពោលគឺ វាធ្វើឱ្យវិសមភាពយេនឌ័របន្តកើតមានហើយដែលគេចាំបាច់ត្រូវតែបំបាត់ចោល។
- វាមានប្រយោជន៍ក្នុងការរៀនជំនាញប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពដើម្បីផ្លាស់ប្តូរផ្នត់គំនិតផ្ទាល់ខ្លួនចំពោះសមត្ថភាពរបស់មនុស្សម្នាក់ និងដើម្បីមានលទ្ធភាពចរចាជាមួយអ្នកដទៃបាន។

**ក្របខណ្ឌចំណេះដឹង ៖**

ការប្រាស្រ័យទាក់ទងគឺជាផ្នែកដ៏សំខាន់មួយនៃជីវិត។ ការបង្កើតក្រុមសង្គម និងនយោបាយ ដូចជាគ្រួសារ កន្លែងធ្វើការ សង្កាត់ និងរដ្ឋ អាស្រ័យលើសមត្ថភាពរបស់មនុស្សក្នុងការប្រាស្រ័យទាក់ទងការគិត គំនិត ព័ត៌មាន ការសង្កេត បទពិសោធន៍ និងអារម្មណ៍។

ឱកាស និងលទ្ធភាពក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធិភាពពឹងផ្អែកលើកត្តាមួយចំនួនដែលក្នុងនោះផ្តត់គំនិតផ្នែកយេនឌ័រប្រហែលជាកត្តាមួយដែលធ្ងន់ធ្ងរជាងគេបំផុត។ ការរើសអើងដោយផ្អែកលើយេនឌ័រមានផលជះលើបរិបទរបស់បុគ្គល ឋានៈរបស់គេនៅក្នុងសង្គម ឥទ្ធិពលដែលមនុស្សមាន ឬមិនមាន និងចំណុចសំខាន់ៗផ្សេងៗជាច្រើនទៀត ដូចជាការអប់រំ ឋានានុក្រមក្នុងគ្រួសារ កន្លែងការងារ សហគមន៍ និងទីកន្លែងផ្សេងៗទៀតដែលបង្កើតបានជាបរិស្ថានសង្គមរបស់មនុស្សម្នាក់។ ដូច្នេះ ពេលដែលបុគ្គលម្នាក់ចាប់ផ្តើមកសាងជំនាញប្រាស្រ័យទាក់ទងប្រកបប្រសិទ្ធភាព វាមានសារៈសំខាន់ក្នុងការយល់ដឹងពីបរិស្ថាន និងដើម្បីអភិវឌ្ឍសមត្ថភាពប្រាស្រ័យទាក់ទងឱ្យបានច្បាស់លាស់ មានទំនុកចិត្ត និងមានយុទ្ធសាស្ត្រនៅក្នុងបរិយាកាសនេះដែរ។

# ឧបសម្ព័ន្ធទី១

## សន្លឹកកិច្ចការសិស្ស

# ជំពូកទី១

## មេរៀនទី១ ៖ ខ្ញុំ និងខ្លួនខ្ញុំ

កិច្ចការក្នុងថ្នាក់

សេចក្តីណែនាំ៖

- ចូរបង្កើតដ្យាក្រាមអត្តសញ្ញាណរបស់ប្អូន។
- ប្អូនអាចពិចារណាពីតម្រុយមួយចំនួនដើម្បីជាការណែនាំប្អូន ៖ អាយុ ភេទ ការអប់រំ ភាសានិយាយ ការងារ ចំណង់ចំណូលចិត្ត(សកម្មភាពកម្សាន្ត) ការចូលចិត្ត និងការមិនចូលចិត្ត ចំណុចខ្លាំង។
- ប្អូនអាចបន្ថែមរង្វង់ក្នុងដ្យាក្រាមទៀតបាន ប្រសិនបើចាំបាច់។

១.



បន្ទាប់ពីបំពេញរួច សូមចែករំលែកដ្យាក្រាមអត្តសញ្ញាណរបស់អ្នកជាមួយដៃគូអ្នក។

## កិច្ចការផ្ទះ

**២ (ក) សេចក្តីណែនាំ**

- យកក្រដាសតូចៗដែលសរសេរពីគុណសម្បត្តិ(ចំណុចល្អៗ)របស់ប្អូនមកបិទក្នុងប្រអប់ខាងក្រោម។

**(ខ) សេចក្តីណែនាំ**

- ចូរសរសេររៀបរាប់ពីអារម្មណ៍របស់ប្អូន(តើប្អូនមានអារម្មណ៍ដូចម្តេច?)ចំនួន២បន្ទាត់នៅពេលដែលនរណាម្នាក់បានកត់សម្គាល់ពីគុណសម្បត្តិរបស់ប្អូនដូចទៅនឹងអ្វីដែលប្អូនបានលើកឡើងខាងលើ។ ចូរបង្ហាញពីអារម្មណ៍របស់ប្អូនដែលប្អូនមានគុណសម្បត្តិខាងលើ។
- ចូរសរសេរគុណសម្បត្តិចំនួន២ផ្សេងទៀតដែលប្អូនមានដែរ។

១.........................................................................

២.........................................................................

## មេរៀនទី២ ៖ ខ្ញុំ និងអ្នកជទៃ

កិច្ចការក្នុងថ្នាក់

សេចក្តីណែនាំ ៖

- គូរអ្វីមួយដែលទាក់ទងនឹងប្រធានបទ ៣ ខាងក្រោម ៖

ប្រធានបទទី១ ៖ ខ្ញុំ និងសាលារៀនរបស់ខ្ញុំ

ប្រធានបទទី២ ៖ ខ្ញុំ និងផ្ទះរបស់ខ្ញុំ

ប្រធានបទទី៣ ៖ ខ្ញុំ និងមិត្តភក្តិរបស់ខ្ញុំ

## ជំពូកទី២ ៖ យេនឌ័រ

## មេរៀនទី៣ ៖ ការយល់ដឹងពីយេនឌ័រ

### កិច្ចការផ្ទះ

សេចក្តីណែនាំ ៖

ដោយផ្អែកលើសកម្មភាពដែលបានអនុវត្តទាក់ទងនឹងយេនឌ័រ ចូលកំណត់ថា តើគំនិតទាំង ៦ ខាងក្រោមនេះ ត្រូវ ឬខុស ព្រមទាំងបញ្ជាក់ហេតុផលផង។

| ប្រយោគ | ពិត / មិនពិត | ហេតុអ្វី? |
|---|---|---|
| យេនឌ័រមានតែពីរប៉ុណ្ណោះគឺប្រុស និងស្រី។ | | |
| យេនឌ័រសំដៅទៅលើភាពខុសគ្នាផ្នែកជីវសាស្ត្ររវាងបុរស និងស្ត្រីដោយផ្អែកលើប្រដាប់បន្តពូជ និងហៀន។ | | |
| អ្នកប្តូរយេនឌ័រទាំងអស់ឆ្លងកាត់ការវះកាត់ ឬនីតិវិធីវេជ្ជសាស្ត្រដើម្បីផ្លាស់ប្តូរយេនឌ័ររបស់ខ្លួន។ | | |
| ស្ត្រីមានភាពអៀនខ្មាស និងទន់ខ្សោយជាងបុរស | | |
| បុរសពូកែគណិតវិទ្យាជាងស្ត្រី។ | | |
| យេនឌ័រគឺជាការកំណត់សង្គម។ | | |

# មេរៀនទី៤ ៖ តួនាទីយេនឌ័រ

## សេចក្ដីណែនាំ[9]

ចូរប្អូនគិតឡើងវិញពីតួនាទីយេនឌ័រ និងការរើសអើងយេនឌ័រដែលបានពិភាក្សាគ្នានៅក្នុងថ្នាក់ថ្ងៃនេះ រួចឆ្លើយ និងបំពេញសំណួរខាងក្រោម។ ចូរសួរសំណួរចំនួន២ដំបូងទៅកាន់នរណាដែលប្អូនស្គាល់។

១. សុំឱ្យមនុស្សស្រីពេញវ័យម្នាក់ (ម្ដាយ អ្នកគ្រូ សាច់ញាតិ) រៀបរាប់ប្រាប់ប្អូនពីពេលវេលាដែលគាត់ត្រូវបានគេប្រព្រឹត្តិដាក់យ៉ាងអយុត្តិធម៌នៅសាលារៀន ឬនៅកន្លែងធ្វើការដោយសារតែគាត់ជាមនុស្សស្រី។ ចូររៀបរាប់ពីស្ថានភាពនោះ។

…………………………………………………………………………………………………………………

…………………………………………………………………………………………………………………

…………………………………………………………………………………………………………

២. សុំឱ្យមនុស្សប្រុសពេញវ័យម្នាក់ (ឪពុក លោកគ្រូ សាច់ញាតិ) រៀបរាប់ប្រាប់ប្អូនពីពេលវេលាដែលគាត់ត្រូវបានគេប្រព្រឹត្តិដាក់យ៉ាងអយុត្តិធម៌នៅសាលារៀន ឬនៅកន្លែងធ្វើការ ដោយសារតែគាត់ជាមនុស្សប្រុស។ ចូររៀបរាប់អំពីស្ថានភាពនោះ។

…………………………………………………………………………………………………………………

…………………………………………………………………………………………………………………

…………………………………………………………………………………………………………

៣. ចូររកឧទាហរណ៍ (រឿង កម្មវិធីទូរទស្សន៍ ការផ្សព្វផ្សាយតាមទស្សនាវដ្ដី) ដែលបង្ហាញពីបុរសដែលកំពុងធ្វើកិច្ចការផ្សេងៗដែលជាតួនាទីជាប្រពៃណីរបស់ស្ត្រី និងធ្វើការរៀបរាប់នៅខាងក្រោមនេះ។

…………………………………………………………………………………………………………………

……………………………………………………………………………………………………………

………………………………………………………………………………………………………………

៤. ចូររៀបរាប់ពីការផ្សព្វផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ ឬទស្សនាវដ្ដីដែលសន្មតថាស្ត្រីជាអ្នកធ្វើការងារក្នុងផ្ទះ ចំណែកឯបុរសធ្វើការងារនៅក្រៅផ្ទះ។ តើការសន្មតទាំងនេះបង្ហាញពីភាពលម្អៀងផ្នែកយេនឌ័រចំពោះស្ត្រី និងបុរសយ៉ាងដូចម្ដេច?

…………………………………………………………………………………………………………………

……………………………………………………………………………………………………………

[9] ការបំពេញគម្លាត ការលំបាកក្នុងការបង្រៀនពីប្រធានបទអប់រំផ្លូវភេទ SIECUS ទីក្រុងញូវយ៉ក ឆ្នាំ1998។

## មេរៀនទី៨ ៖ ការចរចារពីតួនាទីយេនឌ័រ

### សេចក្ដីណែនាំ[២]

និយាយជាមួយនរណាម្នាក់ដែលប្អូនស្គាល់ និងស្វែងយល់ពីរឿងរ៉ាវរបស់ក្មេងស្រីម្នាក់នៅក្នុងសហគមន៍របស់ប្អូន ឬនរណាម្នាក់ដែលប្អូន ឬអ្នកនៅក្នុងសហគមន៍របស់ប្អូនស្គាល់ដែលបានធ្វើការចរចារបានដោយជោគជ័យចំពោះការរឹតត្បិតដែលក្មេងស្រីនោះប្រឈមមុខដោយសារខ្លួនជាក្មេងស្រី។ ចូររៀបរាប់រឿងរ៉ាវឱ្យបានលម្អិតតាមដែលអាចធ្វើទៅបាន។

*កំណត់សម្គាល់សម្រាប់គ្រូបង្រៀន ៖* នៅកន្លែងដែលគ្មាន ឬមានការប្រាស្រ័យទាក់ទង(អន្តរកម្ម)ក្នុងសហគមន៍តិចតួចសម្រាប់ក្មេងស្រី ការផ្ដោតទៅលើរបៀបដែលក្មេងស្រីសួរសំណួរនេះមានសារៈសំខាន់ណាស់។ យើងអាចប្រមើលទុកជាមុនថា ពួកគេប្រហែលជាមិនដឹងថា តើនាងមកពីណាទេ? ដូច្នេះលោកគ្រូអ្នកគ្រូអាចប្រែក្លាយលំហាត់នេះទៅជា "ស្វែងរករឿងរ៉ាវរបស់ក្មេងស្រីនៅក្នុងសាលារៀនរបស់លោកគ្រូ អ្នកគ្រូ" វិញ (ឬកន្លែងណាដែលសិស្សមានភាពងាយស្រួលយល់ជាង)។

តើប្អូនមានអារម្មណ៍យ៉ាងណានៅពេលដែលប្អូនដឹងពីរឿងនេះ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

តើប្អូនមានអារម្មណ៍ថាការរឹតត្បិតនោះមានភាពអយុត្តិធម៌ដែរ ឬទេ? ហេតុអ្វី?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

[២] ការបំពេញគម្លាត ការលំបាកក្នុងការបង្រៀនប្រធានបទអប់រំផ្លូវភេទ SIECUS ទីក្រុងញូវយ៉ក ឆ្នាំ១៩៩៨។

# ជំពូកទី៣ ៖ យេនឌ័រ និងការប្រាស្រ័យទាក់ទង

## មេរៀនទី១០ ៖ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព

### កិច្ចការក្នុងថ្នាក់

ចូរបំពេញតារាងខាងក្រោមដោយផ្អែកលើរបៀបដែលប្អូនដាក់ពិន្ទុឱ្យខ្លួនឯងចំពោះប្រយោគខាងក្រោម។ ចូរគូសសញ្ញាធិក(√)ក្នុងប្រអប់សមស្របណាមួយ (ក ខ គ ឬ ឃ) ដោយផ្អែកលើភាពញឹកញាប់នៃអ្វីដែលគេបាន ឬមិនបានលើកឡើងក្នុងប្រយោគទាំងនេះ។

| ប្រយោគ | ក<br>មិនពិត<br>១ | ខ<br>ពិតខ្លះ<br>២ | គ<br>ជាញឹកញាប់គឺពិត<br>៣ | ឃ<br>ពិតជានិច្ច<br>៤ |
|---|---|---|---|---|
| ខ្ញុំមិននិយាយកាត់អ្នកដទៃពេលពួកគេកំពុងនិយាយទេ | | | | |
| ខ្ញុំនិយាយឮល្មម (មិនឮពេក មិនខ្សោយពេក) | | | | |
| ខ្ញុំមិនគ្របដណ្ដប់(និយាយច្រើនតែឯង)ក្នុងពេលសន្ទនាគ្នាទេ (ផ្ដល់ឱកាសឱ្យអ្នកផ្សេងនិយាយ) | | | | |
| ខ្ញុំនិយាយស្មើគ្នានឹងអ្នកផ្សេងទៀតដែលនិយាយដែរ | | | | |
| ខ្ញុំមើលមុខអ្នកដទៃ | | | | |
| នៅពេលស្ដាប់គេនិយាយ ខ្ញុំបង្ហាញពីប្រតិកម្មរបស់ខ្ញុំចំពោះអ្នកនិយាយ ឧទាហរណ៍ ងក់ក្បាល | | | | |
| ខ្ញុំបង្ហាញពីអារម្មណ៍របស់ខ្ញុំ(តើខ្ញុំមានអារម្មណ៍ដូចម្ដេច?) មិនគ្រាន់តែពីអ្វីដែលខ្ញុំគិតនោះទេ | | | | |
| ខ្ញុំមើលមុខអ្នកនិយាយ ហើយចៀសវាងឱបដៃ ឬបែរមុខចេញពីគាត់ | | | | |
| ខ្ញុំស្នើ ឬលើកទឹកចិត្តឱ្យអ្នកផ្សេងនិយាយ | | | | |
| ខ្ញុំឆ្លើយតប និងបង្ហាញចំណាប់អារម្មណ៍ចំពោះអ្នកនិយាយ | | | | |

| | | | | |
|---|---|---|---|---|
| ខ្ញុំមិននិយាយកាត់អ្នកដទៃដើម្បីលើកឡើងពីគំនិតខ្លួនឯងទេ | | | | |
| ខ្ញុំយកចិត្តទុកដាក់ចំពោះអ្នកនិយាយគ្រប់ពេលទាំងអស់(តាំងពីពេលចាប់ផ្តើមរហូតដល់ចប់) | | | | |
| ខ្ញុំសួរសំណួរដើម្បីបង្ហាញចំណាប់អារម្មណ៍ចំពោះអ្វីដែលអ្នកនិយាយកំពុងនិយាយ | | | | |
| ខ្ញុំវាយតម្លៃលើអ្វីដែលអ្នកនិយាយកំពុងនិយាយ និងរបៀបដែលគេនិយាយ ជាជាងការវិនិច្ឆ័យទៅលើអ្នកនិយាយផ្ទាល់ | | | | |

ឥឡូវនេះ ចូរវាយតម្លៃពិន្ទុខ្លួនឯងដោយផ្អែកលើចម្លើយខាងលើរបស់ប្អូន ៖

១៥-២៧ ពិន្ទុ – ខ្សោយ

២៨-៣៩ ពិន្ទុ – មធ្យម

៤០-៤៧ ពិន្ទុ – ល្អបង្គួរ

៤៨-៦0 ពិន្ទុ – ល្អណាស់

ប្អូនមិនចាំបាច់ចែករំលែកចម្លើយរបស់ប្អូនជាមួយអ្នកផ្សេងទេ។ ចម្លើយនេះគ្រាន់តែសម្រាប់ឱ្យប្អូនដឹងពីចំណុចល្អរបស់ប្អូននៅពេលធ្វើការប្រាស្រ័យទាក់ទង និងពីអ្វីដែលប្អូនអាចកែលម្អបាន។ យើងនឹងមិនសិក្សាពីអ្វីដែលជាការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ឬពីគន្លឹះសម្រាប់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពទេ។

# ឧបសម្ព័ន្ធទី២

## ទម្រង់វាយតម្លៃសិស្ស

ពិន្ទុសរុប
........../៥៥

# កម្រងសំណួរការធ្វើតេស្តចំណេះដឹងសិស្ស
## សម្រាប់ក្មេងស្រី វ័យជំទង់ (ម៉ូឌុល ១)

វិទ្យាល័យ/អនុវិទ្យាល័យ........................................ខេត្ត/ក្រុង....................ស្រុក/ខណ្ឌ....................ឃុំ/សង្កាត់..................

ឈ្មោះគ្រូបង្រៀន...........................................ភេទ..............ឈ្មោះសិស្ស..................................ភេទ............ថ្នាក់ទី.........

កាលបរិច្ឆេទការធ្វើតេស្ត: ថ្ងៃទី................ខែ.........................ឆ្នាំ..................

| ខ្លឹមសារ | ពិពណ៌នាសកម្មភាព | ផ្សេងៗ |
|---|---|---|
| **ម៉ូឌុលទី១**: *ខ្ញុំ និងបរិស្ថានជុំវិញខ្ញុំ* | | |
| ជំពូកទី១ ៖ អត្តសញ្ញាណ | | |
| ១.១. ខ្ញុំ និងខ្លួនឯង មានន័យថា...? | ☐ក. គឺជាការស្គាល់អំពីលក្ខណៈ និងអត្តសញ្ញាណផ្ទាល់ខ្លួន។ | |
| | ☐ខ. គឺជាការស្គាល់ពីគោលដៅរបស់ខ្លួនឯង។ | |
| លទ្ធផល | ☐គ. គឺជាការស្គាល់តួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ | |
| ☐ | ☐ឃ. គឺជាការស្គាល់មិត្តភក្តិ គ្រួសារ បងប្អូន និងកន្លែងរស់នៅ។ | |
| | ☐ង. មិនដឹង។ | |
| ១.២. ខ្ញុំ និងអ្នកដទៃ មានន័យថា...? | ☐ក. ជាទំនាក់ទំនងរវាងខ្ញុំនិងបរិស្ថាននៅជុំវិញខ្លួនខ្ញុំ។ | |
| | ☐ខ. ជាទំនាក់ទំនងរវាងខ្ញុំនិងក្រុមគ្រួសារខ្ញុំ។ | |
| លទ្ធផល | ☐គ. ជាទំនាក់ទំនងរវាងខ្ញុំនិងមិត្តភក្តិ។ | |
| ☐ | ☐ឃ. ជាទំនាក់ទំនងរវាងខ្ញុំនិងសាលារៀន។ | |
| | ☐ង. មិនដឹង។ | |
| ជំពូកទី២៖ យេនឌ័រ | | |
| ២.១. ការយល់ដឹងអំពីយេនឌ័រមានន័យថា...? | ☐ក. គឺជាការយល់ដឹងអំពីទស្សនៈទាន របស់យេនឌ័រ។ | |
| | ☐ខ. គឺជាការយល់ដឹងពីទំនួលខុសត្រូវ តួនាទី និងការងារដែលត្រូវធ្វើជាមួយគ្នារវាងភេទប្រុស និងភេទស្រី។ | |
| លទ្ធផល | ☐គ. គឺជាការយល់ដឹងអំពីសារៈសំខាន់របស់ភេទនីមួយៗ។ | |
| ☐ | ☐ឃ. គឺជាការយល់ដឹងពីតួនាទីរបស់ភេទនីមួយៗ។ | |
| | ☐ង. មិនដឹង។ | |
| ២.២. តើអ្វីជាតួនាទីយេនឌ័រ? លទ្ធផល ☐ | ☐ក. គឺជាការរំពឹងទុកដែលផ្អែកលើការអនុវត្តតាមបែបសង្គមវប្បធម៌ ដែលអាចមានភាពមិនស្មើគ្នា និងអយុត្តិធម៌។ | |
| | ☐ខ. គឺជាទំនួលខុសត្រូវ តួនាទី និងការងារដែលត្រូវធ្វើជាមួយគ្នារវាងភេទប្រុស និងភេទស្រី។ | |

| | | |
|---|---|---|
| | ☐គ. គឺជាសិទ្ធនិងអំណាចរបស់ភេទទាំងពីរ។<br>☐ឃ. គឺជាលទ្ធភាពដែលអាចធ្វើអ្វីមួយបានរបស់ក្មេងប្រុស និងក្មេងស្រី។<br>☐ង. មិនដឹង។ | |
| ២.៣. តើអំណាចជាអ្វី?<br><br>លទ្ធផល<br>☐ | ☐ក. គឺជាសិទ្ធសេរីភាពរបស់បុគ្គលម្នាក់ៗក្នុងការសម្រេចចិត្តធ្វើអ្វីមួយ តែស្ថិតក្រោមការគ្រប់គ្រងរបស់ច្បាប់។ | |
| | ☐ខ. គឺជាសិទ្ធិឬអំណាចដែលបុគ្គលម្នាក់ៗអាចធ្វើអ្វីមួយបាន ។ | |
| | ☐គ. គឺជាតួនាទីនិងទំនួលខុសត្រូវរបស់បុគ្គលម្នាក់ៗ។ | |
| | ☐ឃ. គឺជាការបែងចែកឋានៈរវាងអ្នកមាននិងអ្នកក្រ។ | |
| | ☐ង. មិនដឹង។ | |
| ២.៤. អំណាច និងបិតាធិបតេយ្យ មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?<br>លទ្ធផល<br>☐ | ☐ក. មានការរើសអើង និងភាពអយុត្តិធម៌លើយេនឌ័រ។ | |
| | ☐ខ. មានភាពមិនស្មើគ្នារវាងបុរស និងស្ត្រីលើតួនាទី។ | |
| | ☐គ. ការដឹកនាំផ្តោតលើបុរសជាសំខាន់។ | |
| | ☐ឃ. បុរសមានសិទ្ធិអំណាចជាងស្ត្រី។ | |
| | ☐ង. មិនដឹង។ | |
| ២.៥. ភាពជាក្មេងស្រីមានន័យថា...?<br><br>លទ្ធផល<br>☐ | ☐ក. ក្មេងស្រីដែលអាចចូលរួមក្នុងការសម្រេចចិត្ត និងជ្រើសរើសធ្វើអ្វីដែលពួកគេចូលចិត្ត។ | |
| | ☐ខ. ក្មេងស្រីដែលមានសមត្ថភាព និងចំណេះដឹងខ្ពស់ដូចក្មេងប្រុស។ | |
| | ☐គ. ជាក្មេងស្រីដែលពូកែធ្វើកិច្ចការងារផ្ទះ។ | |
| | ☐ឃ. ជាក្មេងស្រីដែលទន់ភ្លន់ សុភាពរាបសា។ | |
| | ☐ង. មិនដឹង។ | |
| ២.៦. ការចរចាអំពីតួនាទីយេនឌ័រគឺ...?<br><br>លទ្ធផល<br>☐ | ☐ក. ជាការស្វែងយល់ពីលទ្ធភាពនៃការចរចាពាក់ព័ន្ធនឹងតួនាទី និងការរំពឹងទុករបស់យេនឌ័រ។ | |
| | ☐ខ. ជាការស្វែងយល់ពីផលប៉ះពាល់នៃការរើសអើងតួនាទីយេនឌ័រ។ | |
| | ☐គ. ជាការស្វែងយល់ពីបញ្ហាដែលកើតមានចំពោះការអនុវត្តន៍តួនាទីយេនឌ័រ។<br>☐ឃ. ជាការស្វែងយល់ពីទំនាក់ទំនងតួនាទីក្មេងប្រុសនិងក្មេងស្រី<br>☐ង. មិនដឹង។ | |

| ជំពូកទី៣៖ យេនឌ័រ និងការប្រាស្រ័យទាក់ទង | | |
|---|---|---|
| ៣.១. ការប្រាស្រ័យទាក់ទងជាពាក្យសម្ដីគឺជាអ្វី?<br><br>លទ្ធផល<br>☐ | ☐ក. ជាការប្រាស្រ័យទាក់ទងដោយប្រើពាក្យនិយាយ ភាសា និងការបញ្ចេញសម្លេង និង ឥរិយាបថ ឬកាយវិការដែលតម្រូវ ឱ្យអ្នកស្ដាប់យល់ពីអ្វីដែលកំពុងនិយាយ។ | |
| | ☐ខ. ជាការផ្លាស់ប្ដូរការគិត គំនិត ឬអារម្មណ៍ទៅវិញទៅមក។ | |
| | ☐គ. ជាវិធីដែលមនុស្សផ្ដល់ និងទទួលព័ត៌មានពីគ្នាទៅវិញទៅមកនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ | |
| | ☐ឃ. ជាជំនាញមួយដែលមនុស្សម្នាក់ៗត្រូវតែមាន។ | |
| | ☐ង. មិនដឹង។ | |
| ៣.២. ការប្រាស្រ័យទាក់ទង ប្រកបដោយប្រសិទ្ធភាពមានន័យថា...?<br><br>លទ្ធផល<br>☐ | ☐ក. ជាដំណើរនៃការផ្ញើ និងទទួលព័ត៌មាន ឬគំនិតតាមរយៈមធ្យោបាយជាពាក្យសម្ដី និងមិនមែនពាក្យសម្ដីដែលអាចសម្រេចការងារអ្វីមួយបានល្អ។ | |
| | ☐ខ. ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអនុវត្តការងារមួយប្រកបដោយប្រសិទ្ធភាព។ | |
| | ☐គ. ជារបៀបនៃការអនុវត្តន៍ការងាររបស់មនុស្សម្នាក់ៗ។ | |
| | ☐ឃ. ជាការបញ្ជាឱ្យនរណាម្នាក់ធ្វើអ្វីមួយ។ | |
| | ☐ង. មិនដឹង។ | |
| ៣.៣. ការប្រាស្រ័យទាក់ទងមិនមែនពាក្យសម្ដីមានន័យថា...?<br><br>លទ្ធផល<br>☐ | ☐ក. ជាសកម្មភាពមួយដែលរួមបញ្ចូលនូវលទ្ធភាពជាច្រើនហួសពីការបញ្ចូលគ្នានៃពាក្យរួមនិងឥរិយាបថ ការបញ្ចេញទឹកមុខ សកម្មភាព សម្លេង ការបន្លំ ចលនារាងកាយ កាយវិការ និងសកម្មភាពជាច្រើនទៀត។ | |
| | ☐ខ. ជាការបញ្ចេញអារម្មណ៍របស់មនុស្សក្នុងការបង្ហាញដល់នរណាម្នាក់ដោយប្រើកាយវិការ។ | |
| | ☐គ. ជាការទំនាក់ទំនងដោយប្រើកាយវិការជំនួសពាក្យសម្ដី។ | |
| | ☐ឃ. ជាការទាក់ទងតាមរយៈការផ្ញើសំបុត្រ។ | |
| | ☐ង. មិនដឹង។ | |